សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et Des Sciences Economiques
Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# ស្ថាប័នអយ្យការអមសាលាដំបូងរាជធានីខេត្ត

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយនិស្សិតឈ្មោះ
**កញ្ញា ហាយសឿន សម្ផស្ស**
**លោក លឹម សុម៉ុនលី**

សាស្ត្រាចារ្យណែនាំ
**លោក ហ៊ាន ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **ហាយសឿន សម្ផស្ស** និងលោក **លឹម សុម៉ុនលី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តឆ្នាំទី៤ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

- លោកឪពុក និងអ្នកម្តាយ ជាអ្នកមានគុណដ៏ឧត្តុងឧត្តមជាទីបំផុត ដែលបានផ្តល់កំណើតដល់យើងខ្ញុំ ព្រមទាំងបានខិតខំប្រឹងប្រែងយ៉ាងលំបាក នៅក្នុងការចិញ្ចឹមបីបាច់ថែរក្សាតាំងពីនៅបាតជើងក្រហម និងបានអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ហើយខិតខំធ្វើការទាំងថ្ងៃទាំងយប់ ទោះបីលឺយ៉ាងយ៉ាងណាក៏នៅតែប្រឹងប្រែងរកប្រាក់ចិញ្ចឹម និងជួយទំនប់បម្រុងយើងខ្ញុំបានសិក្សារៀនសូត្រ ដើម្បីអោយទទួលបាននូវចំណេះដឹង ចំពោះវិជ្ជា តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សា។ សមិទ្ធផលនេះគឺជាគុណបំណាច់ដ៏ធំធេងរបស់លោកអ្នកមានគុណទាងពីរ ធ្វើឱ្យយើងខ្ញុំដែលជាកូនៗ មិនអាចហែលឆ្លងកាត់នូវភាពលំបាកធំជាងមហាសមុទ្រនេះបានឡើយ។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំសូមលំឱនកាយគោរពនូវមហាករុណាទិគុណដ៏ធំធេងទាំងអស់នេះ ដែលធ្វើឲ្យពួកយើងខ្ញុំចងចាំជានិច្ចនូវការលះបង់គ្មានទីបញ្ចប់ និងមហិមា ដើម្បីជ្រោមជ្រែង ជីវិតពួកយើងខ្ញុំឱ្យទទួលបាននូវលទ្ធផលដ៏វិសេសវិសាល សម្រាប់យកទៅប្រឡូកក្នុងរបរចិញ្ចឹមជីវិតដូចជាចូលរួមក្នុងការកសាងអភិវឌ្ឍន៍ប្រទេសជាតិ ស្របតាមកាលានុវត្តភាពនៃសង្គមជាក់ស្តែង។

- លោកសាស្ត្រាចារ្យ **ហ៊ាខ ឡេខ** ជាសាស្រ្តាចារ្យ **ផ្នែកនីតិសាស្រ្ត**នៃសាកលវិទ្យាល័ភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការយកចិត្តទុកដាក់យ៉ាងខ្លាំងដល់យើងខ្ញុំ ហើយថែមទាំងឆ្លៀតពេលវេលា ធ្វើការពន្យល់ណែនាំផ្តល់ដំបូន្មានល្អៗក្នុងការចងក្រង និងតាក់តែងចំពោះសារណាមួយនេះរហូតបានចប់ជាស្ថាពរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរ ដល់លោកឪពុកអ្នកម្តាយឲ្យជួបតែសេចក្តីសុខចម្រើន អាយុវែង និងជួបពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ប្រទេសនីមួយៗចាំបាច់ត្រូវមានច្បាប់ ឬបទបញ្ញាត្តិ ដើម្បីរៀបចំសណ្តាប់ធ្នាប់សង្គម និងដើម្បីគ្រប់គ្រង ដើម្បីការពារផលប្រយោជន៍ សិទ្ធិសេរីភាព ដល់សាធារណៈជនទូទៅ មនុស្សមានចំណងទាក់ទងទាំងទិដ្ឋភាពនយោបាយ និងទិដ្ឋភាពសង្គមក្នុង នៃសង្គមជាតិទាំងមូល ស្របតាមឆន្ទៈរបស់ច្បាប់ ។ ច្បាប់ត្រូវការពារដល់ពួកគេក៏ដូចជាការបង្ក្រាបបទល្មើសផ្សេងៗដែលជនគ្រប់រូបត្រូវការយុត្តិធម៌ មានតែតុលាការទេដែលមានសិទ្ធប្រកាសទោស និងលើកយកមកអនុវត្តបាន។ ដើម្បីឱ្យប្រជាពលរដ្ឋអាចរស់នៅបានដោយសុខសន្តិភាព នោះរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការបង្កើតអោយមានស្ថាប័នតុលាការនៅគ្រប់រាជធានីខេត្តក្រុង ដើម្បីទុកអោយដោះស្រាយនៅបញ្ហានានាដែលប្រជាពលរដ្ឋមាន ដោយនៅក្នុងបណ្តាខេត្តនីមួយៗ គឺតែងតែមាននូវស្ថាប័នតុលាការមួយដែលអមដោយស្ថាប័នយ្យការមួយ ដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញាដើម្បីការពារផលប្រយោជន៍ទូទៅដល់មហាជនគ្រប់ស្រទាប់វណ្ណៈ។

ចាប់តាំងពីប្រទេសកម្ពុជាយើងទទួលបាននូវសិទ្ធសេរីភាពពេញលេញតាំងពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងវិស័យច្បាប់ ដោយបានបង្កើតឱ្យមាននូវរដ្ឋធម្មនុញ្ញ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងបានបង្កើតនូវច្បាប់ផ្សេងៗទៀត ដើម្បីទុកការពារ ទប់ស្កាត់ និងដោះស្រាយនូវបញ្ហាណាមួយ ដែលបានកើតឡើងទៅលើប្រជាជនខ្មែរ ដោយមិនទុកឱ្យប្រជាពលរដ្ឋខ្មែររស់នៅស្ថិតក្រោមភាពអយុត្តិធម៌ ភាពអាណាធិបតេយ្យនៅក្នុងប្រទេសនោះទេ ដោយចង់តែឱ្យរស់នៅប្រកបសុខដមរមនា និងមានសន្តិភាពប៉ុណ្ណោះ។ ជាក់ស្តែង សង្គមខ្មែរមានស្ថេរភាព សុខសន្តិភាព មិនមានសង្គ្រាម និងមានការពារផលប្រយោជន៍ទូទៅជូនប្រជាពលរដ្ឋខ្មែរដោយយុត្តធម៌ និងស្មើរភាព ទាំងនេះក៏ដោយសារតែមានការយកចិត្តទុកដាក់ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកប ដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ ក្នុងក្របខណ្ឌនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានប្រឹងប្រែងអស់កម្លាំងកាយកម្លាំងចិត្ត នៅក្នុងការបង្រៀនដល់និស្សិតបញ្ញាវ័ន្ត ជាច្រើនដែលបានបន្តការសិក្សានៅក្នុងវិស័យច្បាប់ ដោយមិនដែលរអ៊ូហត់នឿយ នៅក្នុងការដែលចែករំលែកចំណេះទៅដល់និស្សិតគ្រប់ជំនាន់នោះទេ នេះជាមហាទិគុណដ៏មិនអាចកាត់ថ្លៃបានចំពោះ លោក លោកស្រី សាស្ត្រាចារ្យទាំងអស់។

អ្វីដែលជម្រុញឱ្យស្នាដៃថ្មីនេះ រឹតតែអាចលេចចេញរូបរាងឡើងបាន ដោយសារតែមាន ការជ្រោមជ្រែងមិនខ្លាចនឿយហត់ពីសំណាក់ លោកសាស្ត្រាចារ្យ **ហ៊ាខ ឡេខ** ដែលជានិច្ចកាល លោកតែងតែដឹកនាំបង្ហាត់

បង្ហាញគំនិតជាមូលដ្ឋានទាក់ទងនឹងលំហូរនៃនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងវិធីសាស្ត្រល្អៗ រួមជាមួយពេលវេលាដ៏មានតម្លៃ ដែលជាកត្តាជម្រុញឲ្យសារណាបញ្ចប់ការសិក្សាទទួលបានជោគជ័យនាឱកាសនេះ។

ជាអវសាន យើងខ្ញុំទាំងពីរ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរជូនចំពោះលោក លោកស្រីសាស្ត្រចារ្យ សូមប្រកបការងារ និងរបរទទួលទានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ...... ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ...... ២

២. ចំណោទបញ្ហានៃការដោះស្រាយ ...... ២

៣. គោលបំណងនៃការស្រាវជ្រាវ ...... ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ...... ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ...... ២

៦. វិធីសាស្ត្រនៃស្រាវជ្រាវ ...... ៣

៧. រចនាសម្ព័ន្ធកាស្រាវជ្រាវ ...... ៣

## ជំពូកទី១

## ស្ថាប័នអយ្យការ

**ផ្នែកទី១ សញ្ញាណនៃស្ថាប័នអយ្យការ** ...... ៤

**កថាខណ្ឌទី១ រចនាសម្ព័ន្ធនៃស្ថាប័នអយ្យការអមសាលាដំបូង** ...... ៤

១. គោលការនៃការរៀបចំស្ថាប័នអយ្យការ ...... ៦

១.១. គោលការណ៍ឋានានុក្រម ...... ៦

១.២. គោលការណ៍អវិភាគ ...... ៧

១.៣. គោលការណ៍ឯករាជ្យរវាងស្ថាប័ន អយ្យការ និងតុលាការ ...... ៨

**កថាខណ្ឌទី២ តំណាងអយ្យការ** ...... ៨

១. ការចូលបម្រើជាតំណាងអយ្យការ ...... ៨

២. ការចុះកម្មសិក្សា និងការទទួលបានអត្ថប្រយោជន៍ ...... ៨

២.១ ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ ...... ១០

៣. ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ ...... ១០

៣.១ កាតព្វកិច្ចត្រូវបំពេញ ...... ១១

៣.២.ទណ្ឌកម្មផ្នែកវិន័យ ...... ១២

# ជំពូកទី២

# តួនាទី និងភារកិច្ចរបស់ស្ថាប័នអយ្យការ

**ផ្នែកទី១ មុខងារនៃស្ថាប័នអយ្យការ**......១៤

**កថាខណ្ឌទី១ ស្ថាប័នការអយ្យការអមសាលាដំបូងរាជធានីខេត្ត**......១៥

១. អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីខេត្ត......១៥

២. សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា......១៥

**កថាខណ្ឌទី២ ការអនុវត្តបណ្តឹងអាជ្ញាដោយតំណាងអយ្យការ**......១៦

១. បណ្តឹងអាជ្ញា......១៧

១.១ ភាពខុសគ្នារវៀងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី......១៨

១.២ ការរំលត់បណ្តឹងអាជ្ញា......១៨

**ផ្នែកទី២ សេចក្តីសម្រេចក្នុងការចោទប្រកាន់របស់តំណាងអយ្យការ**......២១

**កថាខណ្ឌទី១.ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ**......២១

១. ការបើកការស៊ើបសួរ......២២

២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់......២២

៣. នីតិវិធីបង្ហាញខ្លួនភ្លាម......២៣

**កថាខណ្ឌទី២ ការតម្កល់រឿងទុកឥតចាត់ការ**......២៤

១. មូលហេតុការរលត់នៃបណ្តឹងអាជ្ញា......២៥

១.១ មរណភាពនៃជនល្មើស......២៥

១.២ ការផុតអាជ្ញាយុកាលនៃបទល្មើស......២៥

១.៣ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ......២៦

១.៤ អាជ្ញាអស់ជំនុំ......២៦

២. មូលហេតុស្ថានភាពនៃអំពើ......២៦

២.១ អំពើដែលមិនអាចកំណត់បទល្មើស......២៦

២.២ អំពើនៃបទល្មើសដែលបង្ករជាព្យសនកម្មតិចតួច......២៦

២.៣ អំពើដែលកំណត់ជាបទល្មើស តែមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌ......២៧

២.៤ អំពើយុត្តិកម្ម......២៧

## ជំពូកទី៣
## នីតិវិធីរឿងក្ដីព្រហ្មទណ្ឌរបស់ស្ថាប័នអយ្យការ
## និងដំណើរការនៃការអនុវត្តទោស

**ផ្នែកទី១ កិច្ចនីតិវិធីស៊ើបអង្កេត** ........ ២៩

**កថាខណ្ឌទី១ ការស៊ើបអង្កេតករណីជាក់ស្ដែង** ........ ៣០

១. លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្ដែង ........ ៣១

១.១ ដែនអនុវត្ត ........ ៣១

១.២ ស្ថានភាពជាក់ស្ដែង ........ ៣២

២. ការចុះទៅកន្លែងកើតហេតុ ........ ៣៣

៣. ការឆែរឆេរ និងការប្រមូលភស្តុតាង ........ ៣៣

៤. ការស្តាប់ចម្លើយ ........ ៣៥

៥. ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ........ ៣៦

៦.ការឃាត់ខ្លួន ........ ៣៦

៦.១ អំណាចក្នុងការឃាត់ខ្លួន ........ ៣៦

៦.២ កំណត់ហេតុនៃការឃាត់ខ្លួន ........ ៣៨

៦.៣ សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន ........ ៣៩

៧. ការស្តាប់ការសន្ទនាតាមប្រព័ន្ធបច្ចេកវិទ្យា ........ ៤០

**កថាខណ្ឌទី២ ការស៊ើបអង្កេតបឋម** ........ ៤១

១. ការឆែកឆេរ ........ ៤១

២. ការបញ្ជាឲ្យចូលខ្លួន ........ ៤៣

**ផ្នែកទី២ ការចូលរួមក្នុងកិច្ចស៊ើបសួររបស់តំណាងអយ្យការ** ........ ៤៣

**កថាខណ្ឌទី១ ការបើកការស៊ើបសួរ** ........ ៤៤

១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ៤៤

២. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ........ ៤៤

**កថាខណ្ឌទី២ ការស្នើសុំឱ្យបំពេញកិច្ច** ........ ៤៦

១. ការស្រាវជ្រាវក្នុងកិច្ចស៊ើបសួរ ........ ៤៧

២. ការចូលរួមក្នុងវិធានការនិរន្តរាយ ........ ៤៨

២.១ ការបង្គាប់ឱ្យចាប់ខ្លួន ........ ៤៨
២.២ ការឃុំខ្លួនបណ្ដោះអាសន្ន ........ ៤៩
២.២.១ ការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ........ ៤៩
២.២.២ ការសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ........ ៥០
២.២.៣ ការដោះលែងឱ្យនៅក្រៅឃុំ ........ ៥០
២.៣ ការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៥២
**កថាខណ្ឌទី៣ ការបិទ និងមោឃភាពនៃការស៊ើបសួរ** ........ ៥២
១. ការបិទការស៊ើបសួរ ........ ៥២
២. មោឃភាពនៃការស៊ើបសួរ ........ ៥៣
**ផ្នែកទី៣ ស្ថាប័នអយ្យការក្នុងដំណើរការនៃការជំនុំជម្រះ** ........ ៥៤
**កថាខណ្ឌទី១ នីតិវិធីមុនពេលកិច្ចពិភាក្សាដេញដោល** ........ ៥៤
**កថាខណ្ឌទី២ ការបញ្ចប់កិច្ចពិភាក្សាដេញដោល** ........ ៥៥
**ផ្នែកទី៤ ដំណើរការនៃការអនុវត្តទោស** ........ ៥៥
**កថាខណ្ឌទី១.វិធានទាក់ទងនឹងឃុំខ្លួន** ........ ៥៦
១. ការគ្រប់គ្រងពន្ធនាគារ ........ ៥៦
២. ការធ្វើអធិការកិច្ចការពន្ធនាគា ........ ៥៨
**កថាខណ្ឌទី២. ការដោះលែងដោយមានលក្ខខណ្ឌ** ........ ៥៨
១. លក្ខខណ្ឌផ្សេងៗក្នុងការដោះលែងទណ្ឌិត ........ ៥៩
២. សេចក្ដីសម្រេចទាក់ទងទៅនឹងការដោះលែងដោយមានលក្ខខណ្ឌ ........ ៦០
**កថាខណ្ឌទី៣. ការបង្ខំដល់រូបរាងកាយ** ........ ៦០
១. ថិរវេលានៃការបង្ខំដល់រូបរាងកាយ ........ ៦១
២. ការរួចផុតពីការបង្ខំដល់រូបរាងកាយ ........ ៦២
**សេចក្ដីសន្និដ្ឋាន** ........ ៦៣
**អនុសាសន៍** ........ ៦៥
**ឧបសម្ព័ន្ធ**
**ឯកសារយោង**

# សេចក្តីផ្តើម

ចាប់ពីមានវត្តមានមនុស្សរស់នៅលើភពផែនដីយើងនេះ មនុស្សគឺមានភាពវិវត្តន៍បន្តិចម្តងៗ ដោយពីសម័យមុនមនុស្សរស់នៅជាកុលសម្ព័ន្ធ ដោយមិនសូវមានច្បាប់ទម្លាប់នោះទេហើយមនុស្សពីមុនគឺតែងតែជឿទៅលើអាទិទេព ទៅលើធម្មជាតិ ដោយពេលខ្លះមានការសម្រេចចិត្តទៅតាមតែធម្មជាតិ។ ប៉ុន្តែយូរទៅៗការយល់ដឹងរបស់មនុស្សក៏កាន់តែមានការវិវត្តន៍ផ្លាស់ប្តូរ សូម្បីតែការគិតដោយមនុស្សចាប់ផ្តើមចង់រស់នៅដោយមិនចង់មានការបង្កើតជាកុលសម្ព័ន្ធទៀតនោះទេ ហើយចង់បង្កើតឲ្យមានច្បាប់ទម្លាប់មួយដ៏ប្រសិទ្ធភាពច្បាស់លាស់។ ប៉ុន្តែដើម្បីអាចអោយគេបង្កើតបានច្បាប់ទម្លាប់នោះ លុះត្រាតែគេបង្កើតអោយមាននូវរដ្ឋមួយសិន នៅក្នុងរដ្ឋមួយគឺត្រូវបង្កើតឱ្យមានច្បាប់មួយ សម្រាប់ការគ្រប់គ្រងទៅលើពលរដ្ឋនៅក្នុងរដ្ឋ ប្រសិនបើរដ្ឋមួយបង្កើតឡើងដោយគ្មានច្បាប់ នោះគេមិនហៅថារដ្ឋបានឡើយ។

ជាការពិតណាស់ប្រជាពលរដ្ឋគ្រប់រូប គឺតែងរមែងចង់ទទួលបាននូវសិទ្ធសេរីភាពពេញលេញមិនមានការគាបសង្កត់ពីជនណាម្នាក់នោះទេ ដោយចង់រស់នៅប្រកបតាមឆន្ទៈរបស់ខ្លួនទាំងការគិត និងការធ្វើសកម្មភាពផ្សេងៗ។ ហើយអ្វីដែលពិសេសទៀតនោះ គឺចង់បានប្រទេសមួយដែលមានការបង្កើតឲ្យមាននូវច្បាប់យ៉ាងតឹងរឹងមួយសម្រាប់អនុវត្តន៍ទៅលើជនគ្រប់រូប ដោយមិនប្រកាន់ឋានៈ និងមានការរើសអើងនោះទេ។ ហេតុដូចនេះនៅក្នុងសង្គមមួយដើម្បីឲ្យប្រជាពលរដ្ឋរស់នៅដោយមានកក់ក្តៅ និងប្រកបដោយយុត្តិធម៌ នោះគឺត្រូវបង្កើតឲ្យមាននូវសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីទុកសម្រាប់ដោះស្រាយជូនទៅលើប្រជាពលរដ្ឋដែលមានវិវាទ។ ជាក់ស្តែងយើងក្រឡេងមកមើលសង្គមកម្ពុជាយើងសព្វថ្ងៃ គេសង្កេតឃើញនៅគ្រប់បណ្តាខេត្ត គឺតែងតែមាននូវសាលាជម្រះក្តីមួយដោយមិនអាចខ្វះបានដែលគេហៅថា សាលាដំបូងរាជធានីខេត្ត និងមានស្ថាប័នអយ្យការមួយអមជានិច្ច ដោយហេតុថាស្ថាប័ននេះបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការការពារផលប្រយោជន៍ទូទៅដល់សារធារណៈជន ដែលជាអ្នកស្វែងរកយុត្តិធម៌ជូនពលរដ្ឋប្រកបដោយយុត្តិធម៌ ដោយមិនលម្អៀង។

នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ តំណាងអយ្យការគឺជាតួអង្គសំខាន់មួយ ដែលដើរតួនាទីយ៉ាងសំខាន់ដោយមិនអាចខ្វះបាន ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដោយរាល់បទល្មើសទាំងអស់ដែលព្រះរាជអាជ្ញាបានទទួល ពីមន្ត្រីនគរបាលយុត្តិធម៌ ឬបណ្តឹងផ្ទាល់ គឺព្រះរាជអាជ្ញានេះហើយជាអ្នកធ្វើការដាក់បន្ទុកចោទប្រកាន់ទៅលើជនដែលបានប្រព្រឹត្ត ប៉ុន្តែក្នុងនោះផងដែរក៏ព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធនៅក្នុងការចោទ ឬមិនចោទទៅលើជនណាម្នាក់ក៏បានដែរប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាមិនមានធាតុផ្សំគ្រប់គ្រាន់ក្នុងការដាក់បន្ទុក។ ប៉ុន្តែមុន និងឈានក្លាយទៅជាព្រះរាជអាជ្ញា ឬក៏យើងអាចហៅបានថាតំណាងអយ្យការ ក៏ត្រូវឆ្លងកាត់នូវការប្រលងយ៉ាងតឹងរឹង និងមានការចុះកម្មសិក្សាជាមុនសិនផងដែរ ទើបអាចមានសិទ្ធធ្វើជាព្រះរាជអាជ្ញា។

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដ៏សំខាន់ក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ ដោយស្ថាប័ននេះគឺមានការបែងចែងរហូតទៅដល់២ថ្នាក់ ដោយមានស្ថាប័នអយ្យការសាលាដំបូង (តុលាការជាន់ទាប) និងស្ថាប័នអយ្យការសាលាឧទ្ធរណ៍ (តុលាការជាន់ខ្ពស់) ប៉ុន្តែដោយសារតែការយល់ដឹងនៅមានកម្រិតនិងនៅមានចន្លោះខ្វះខាតមួយចំនួន គឺយើងខ្ញុំទាំងពីរលើកយកតែ ស្ថាប័នអយ្យការអមសាលាដំបូងរាជធានីខេត្តមកធ្វើការបកស្រាយជូនប្រិយមិត្តអ្នកអានសិនតែប៉ុណ្ណោះ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដើម្បីងាយស្រួលដល់មិត្តអ្នកអាចយើងខ្ញុំបានបែងចែកជាចំណុចចំណោទបញ្ហាមួយចំនួនដូចខាងក្រោមជាមុនសិនះ

- តើអ្វីជាស្ថាប័នអយ្យការ ?
- តើស្ថាប័នអយ្យការមានតួនាទីអ្វីខ្លះ ?
- តើស្ថាប័នអយ្យការអនុវត្តនីតិវិធីយ៉ាងដូចម្តេច ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះមានគោលបំណងចែករំលែងចំណេះមួយចំនួន តាមរយៈការស្រាវជ្រាវរបស់យើងខ្ញុំទាំងពី ដែលទាក់ទងស្ថាប័នអយ្យការសាលាដំបូងរាជធានីខេត្ត ដើម្បីទុកជាឯកសារសិក្សាបន្ថែមសម្រាប់និស្សិតគ្រប់ជំនាន់ដែលចង់យល់ដឹងកាន់តែច្បាស់ចំពោះស្ថាប័នមួយនេះ។ ថាតើស្ថាប័នអយ្យការសាលាដំបូងរាជធានីខេត្ត មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងរឿងក្តីព្រហ្មទណ្ឌ ?

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ គឺមិនមានការផ្តោតសំខាន់ខ្លាំងទៅលើ ស្ថាប័នអយ្យការអមសាលាឧទ្ធរណ៍នោះទេ គឺផ្តោតតែលើស្ថាប័នអយ្យការអមសាលាដំបូងរាជធានីខេត្តប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ មានអត្ថប្រយោជន៍ ដែលជាជំនួយស្មារតីទៅដល់និស្សិតគ្រប់ជំនាន់ ដើម្បីឱ្យយល់ដឹងពីនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌនៅអយ្យការអមសាលាដំបូងរាជធានីខេត្ត ដោយមិនឱ្យមានការភ័ន្តច្រឡំទៅនិងនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌនៅមហាអយ្យការអមសាលាឧទ្ធរណ៍ឡើយ។

## ៦. វិធីសាស្ត្រនៃស្រាវជ្រាវ

ចំពោះការប្រមូលទន្និន័យ ឯកសារស្រាវនេះគឺបានមកពី តាមប្រព័ន្ធអ៊ិនធឺណេត សៀវភៅច្បាប់ជាច្រើនដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ រដ្ឋធម្មនុញ្ញ និងមានឯកសារច្បាប់ជាច្រើនទៀត ហើយក៏មានសាកសួរដោយមានការណែនាំពី លោក លោកស្រីសាស្ត្រាចារ្យ និងមានការណែនាំពីសិស្សច្បងផងដែរ ដែលជាមូលដ្ឋានគ្រឹះនៅក្នុងការដែលអាចឱ្យយើងខ្ញុំទាំងពីរយល់ដឹង រហូតឈានទៅដល់បានសរសេរ និងចងក្រងរហូតបានបញ្ចប់សារណាមួយនេះ។

## ៧. រចនាសម្ព័ន្ធការស្រាវជ្រាវ

សារណានេះបែងចែកជា ០៣ (បី) ជំពូក៖

**ជំពូកទី១ ស្ថាប័នអយ្យការ**

**ជំពូកទី២ តួនាទី និងភារកិច្ចរបស់ស្ថាប័នអយ្យការ**

**ជំពូកទី៣ នីតិវិធីរឿងក្តីព្រហ្មទណ្ឌរបស់ស្ថាប័នអយ្យការ និងដំណើរការនៃការអនុវត្តទោស**

# ជំពូកទី១
# ស្ថាប័នអយ្យការ

## ផ្នែកទី១ សញ្ញាណនៃស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋសម្រាប់ដំណើរការបណ្ដឹងសាធារណៈ ឬបណ្ដឹងព្រហ្មទណ្ឌ ហើយមានតួនាទីក្នុងការការពារសណ្ដាប់ធ្នាប់សារធារណៈ។ ស្ថាប័នអយ្យការមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[1] មានន័យថា ស្ថាប័នអយ្យការមានសិទ្ធិក្នុងការបង្ក្រាបរាល់បទល្មើសទាំងឡាយណាដែលជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍សាធារណៈ ក៏ដូចជាផលប្រយោជន៍ជាតិផងដែរ។

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលឯករាជ្យ ដែលមិនស្ថិតក្រោមអំណាចនៃសាលាជម្រះក្ដីដែលខ្លួននៅអមនោះទេ ហើយសាលាជម្រះក្ដីនេះទៀតសោតគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ស្ថាប័នអយ្យការឡើយ ក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្ដី មិនត្រូវចុះក្នុងសេចក្ដីសម្រេចរបស់ខ្លួនយកការស្ដីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញានោះទេ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌទាំងរឿងក្ដីផ្សេងៗទៀតផងដែរ។

ការរៀបចំស្ថាប័នអយ្យការ ត្រូវបានរៀបចំឡើងដោយរចនាសម្ព័ន្ធ(កថាខណ្ឌទី១) និង (កថាខណ្ឌទី២) គោលការនៃការរៀបចំស្ថាប័នអយ្យការ។

### កថាខណ្ឌទី១ រចនាសម្ព័ន្ធនៃស្ថាប័នអយ្យការអមសាលាដំបូង

សាលាដំបូងគឺជាសាលាជម្រះក្ដីថ្នាក់ទីមួយ ដែលត្រូវបានបង្កើតឡើងឱ្យមាននៅគ្រប់រាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ ការដាក់ឱ្យដំណើការសាលាដំបូងនានា ត្រូវធ្វើឡើយដោយព្រះរាជក្រឹត្យ សាលាដំបូង ត្រូវបែងចែកជាតុលាការ ជំនាញហើយក៏ជាសាលាជម្រះក្ដីទូទៅដែលមានសមត្ថកិច្ច ជំនុំជម្រះក្ដីទៅលើរឿងក្ដីទាំងអស់ លើកលែងតែរឿងក្ដីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្ដីពិសេស ឬសាលាជម្រះក្ដីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក។

សមាសភាពសាលាដំបូងរួមមាន ៖

-ប្រធាន

-អនុប្រធាន

-ចៅក្រម

-មាត្រា៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[1]

-ក្រឡាបញ្ជី

-មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។

**ក. ការគ្រប់គ្រងរដ្ឋបាល**

នៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មានអង្គភាពរដ្ឋបាលមួយ ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងស្ថាប័នអយ្យការ។ នៅថ្នាក់សាលាដំបូងអង្គភាពរដ្ឋបាលនេះ ហៅថា "**លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង**" មានថ្នាក់ ស្មើរនឹងនាយកដ្ឋាន ។

**ខ. ហិរញ្ញវត្ថុ**

សាលាដំបូង និងស្ថាប័នអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌។ ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាអាណាប័កទទួលសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីត្រូវកំណត់ដោយអនុក្រឹត្យ។

នៅគ្រប់សាលាដំបូងរាជធានីខេត្ត គឺមានស្ថាប័នមួយដែលគេហៅថា " ស្ថាប័នអយ្យការអមសាលាដំបូង " បើយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ស្ថាប័នអយ្យការអមតុលាការដំបូង មានតំណាងអយ្យការដូចជា៖

- ព្រះរាជអាជ្ញា និង
- ព្រះរាជអាជ្ញារង។[2]

យោងទៅតាមច្បាប់ស្តីពីការរៀបចំអង្គការអយ្យការបានកំណត់ថាអយ្យការអមសាលាដំបូងមានសមាសភាពដូចជា ៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមសាលាដំបូង ។[3]

-មាត្រា៣៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[2]

-មាត្រា២៩, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤[3]

## ១. គោលការណ៍នៃការរៀបចំស្ថាប័នអយ្យការ

ដើម្បីធានានូវគោលការណ៍ឯករាជ្យនៃអំណាចតុលាការ តាមរដ្ឋធម្មនុញ្ញ ចៅក្រមអាសនៈ ត្រូវទទួលបានឯករាជ្យភាពពេញលេញពីគ្រប់មជ្ឈដ្ឋាន ក្នុងអំឡុងពេលនៃការវិនិច្ឆ័យរឿងក្តីរបស់ខ្លួន។ **"ចៅក្រមទាំងឡាយត្រូវសម្រេចសេចក្ដីដោយមិនលំអៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្ដី ឬបុគ្គលណាមួយឡើយ។"**[4]

ជាទូទៅ ការរៀបចំនៃស្ថាប័នអយ្យការ ត្រូវគោរពគោលការណ៍ចំនួនបី គឺគោលការណ៍ឋានុក្រម គោលការអវិភាគ និងគោលការណ៍ឯករាជ្យរវាងស្ថាប័នអយ្យការ និងតុលាការ។

### ១.១ គោលការណ៍ឋានានុក្រម

មជ្ឈដ្ឋានមួយចំនួនបានហៅគោលការណ៍ឋានានុក្រមនេះ ទៅតាមការយល់ឃើញរបស់ខ្លួនថា **"គោលការណ៍ឯកភាព។"** ចំពោះគោលការណ៍នេះគឺមានន័យថា ព្រះរាជអាជ្ញារងនៅអមសាលាដំបូងនីមួយៗធ្វើការទទួលខុសត្រូវ និងការណែនាំពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាមានសិទ្ធនៅក្នុងការណែនាំ និងបញ្ជាទៅដល់ព្រះរាជអាជ្ញារងទាំងអស់។ ក្រៅពីនោះទៀតក្នុងក្របខណ្ឌនៃដំណើររឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាទាំងអស់ត្រូវគោរពតាមអធិបញ្ជានៃអំណាចឋានានុក្រមរបស់ខ្លួន មានន័យថា ព្រះរាជអាជ្ញារងត្រូវគោរពទៅតាមបញ្ជារបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាត្រូវគោរពទៅតាមអធិបញ្ជារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះឋានានុក្រមនៅអង្គការអយ្យការសាលាដំបូងរាជធានី-ខេត្ត គឺមានដូចតទៅនេះ

- **អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**
  - ព្រះរាជអាជ្ញាជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
  - ព្រះរាជអាជ្ញារង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

ក្រៅពីនេះ នៅក្នុងក្របខណ្ឌនៃដំណើរការរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវគោរពនូវអធិបញ្ជារបស់នាយឋានុក្រម ដែលមានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្តឹងបរិហារ ឬធ្វើអធិបញ្ជាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជាអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង ដើម្បីឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាមិនចង់ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការយល់ឃើញរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទោះជាអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាមិន

-មាត្រា៨, ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤[4]

ចង់ធ្វើការបើកបណ្តឹងអាជ្ញានៅក្នុងរឿងហេតុនោះក៏ដោយ។ ប៉ុន្តែការធ្វើអធិបញ្ញាទាំងនេះ ពុំអាចមានកម្មវត្ថុក្នុងការបញ្ជាឱ្យអ្នកស្ថិតនៅក្រោមឋានានុក្រមទៅតម្កល់រឿងទុកឥតចាត់ការឡើយ គឺអាចធ្វើអធិបញ្ញា បញ្ជាឱ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានតាមការយល់ឃើញរបស់ខ្លួនតែប៉ុណ្ណោះ។

យោងទៅតាមក្រមព្រហ្មទណ្ឌ បានកំណត់ថា "**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយឡើយ**" ។

ចំពោះព្រះរាជអាជ្ញានៅសាលាដំបូងរាជធានីខេត្ត គឺត្រូវតែស្តាប់តាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញា ប្រសិនបើអគ្គព្រះរាជអាជ្ញាយល់ឃើញថាជាការគួរ។ ដូចនេះព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងទាំងឡាយត្រូវគោរពនូវគោលការណ៍ឋានានុក្រម ឬអធិបញ្ញារបស់ថ្នាក់លើ។ ប៉ុន្តែនៅពេលសវនាការ ចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យ ណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការ ដោយសារតែវាចារបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការឡើយ។[5] ការធ្វើសេចក្តីសន្និដ្ឋាននេះ គឺអាចនិងមានលក្ខណៈមិនស្របទៅនិងអធិបញ្ញារបស់នាយឋានានុក្រម។ គោលការណ៍នេះក៏បានកំណត់ក្នុងនីតិខ្មែរកាលពីសម័យមុនដែរ ដែលគេបានដាក់ឈ្មោះថា "**ប៉ាកកាជាទីសី សម្តីដោយសេរី**" ។

### ១.២ គោលការណ៍អវិភាគ

គោលការណ៍នេះសំដៅដល់ការបំពេញមុខងាររបស់ខ្លួន ចៅក្រមអយ្យការអាចជំនួសគ្នាបានជានិច្ច មានន័យថា ព្រះរាជអាជ្ញាមានភារកិច្ចបំពេញក្នុងស្ថាប័នអយ្យការសាលាជម្រះក្តីណាមួយ ត្រូវមានភារកិច្ចរួមក្នុងមុខងារនោះ និងអាចជំនួសគ្នាទៅវិញទៅមកបានដូចជាករណីមានធុរៈ ឬមានជំងឺ ឬអវត្តមានព្រះរាជអាជ្ញា ត្រូវបានចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន។ តាមគោលការណ៍នេះតំណាងអយ្យការអាច បន្តការងារគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។

ករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឱ្យធ្វើជាស្តីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូងរហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ ។

-មាត្រា៣០, ក្រមនីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០០៧[5]

### ១.៣ គោលការណ៍ឯករាជ្យរវាងស្ថាប័នអយ្យការ និងតុលាការ

ជាគោលការណ៍អំណាចបែកចែកជាបីដាច់ពីគ្នា អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ រវាងស្ថាប័នអយ្យការដែលស្ថិតនៅក្រោមគោលការណ៍ឋានុក្រម នៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងអំណាចនីតិប្រតិបត្តិ ត្រូវតែឯករាជ្យពីគ្នាពីអំណាចតុលាការផងដែរ។

ចំពោះអយ្យការនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺមិនស្ថិតនៅក្រោមចំនុះឱ្យស្ថាប័នជម្រះក្តីដែលខ្លួននៅអមឡើយ ទោះជាខ្លួនស្ថិតក្នុងបរិវេណតែមួយជាមួយនឹងសាលាជម្រះក្តីនោះក៏ដោយ។ ហេតុនេះចៅក្រមអាសនៈ ឬប្រធានតុលាការគ្មានសិទ្ធអំណាច ក្នុងការត្រួតពិនិត្យទៅលើកិច្ចការរបស់ចៅក្រមអយ្យការឡើយ និងគ្មានសិទ្ធក្នុងការស្តីបន្ទោសដោយប្រយោល ឬដោយផ្ទាល់ណាឡើយទោះបីជាមានករណីកំហុសឆ្គងណាមួយ ដែលបង្កឡើងដោយចៅក្រមអយ្យការក្នុងការបំពេញមុខងារជាមួយខ្លួននោះ។ "**ការហាមឃាត់នេះត្រូវអនុវត្តន៍ទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីផ្សេងទៀត**"។[6] ក្នុងករណីចៅអាសនៈយល់ឃើញថា ចៅក្រមអយ្យការបានប្រព្រឹត្តកំហុសណាមួយចៅក្រមអាសនៈ អាចត្រឹមតែលើកសំណើរទៅនាយកឋានានុក្រមណាមួយ នៃចៅក្រមអយ្យការ ដែលប្រព្រឹត្តកំហុសឆ្គងនោះតែប៉ុណ្ណោះ។

## កថាខណ្ឌទី២ តំណាងអយ្យការ

តំណាងអយ្យការ គឺជាមន្ត្រីដែលបានបម្រើការនៅតាមស្ថាប័នអយ្យការនីមួយៗ ចំពោះតំណាងអយ្យការ គឺជាបុគ្គលដែលសំខាន់បំផុតនៅក្នុងស្ថាប័នរបស់ខ្លួន។ ដើម្បីឈានទៅដល់ការបកស្រាយពីតំណាងអយ្យការនោះ យើងត្រូវតែដឹងថា តើតំណាងអយ្យការមានប្រភពមកពីណា ? តើតំណាងអយ្យការមានទទួលខុសត្រូវផ្នែកវិជ្ជាជីវៈអ្វីខ្លះ?

### ១. ការចូលបម្រើជាតំណាងអយ្យការ

មុននឹងឈានទៅធ្វើជាតំណាងអយ្យការគ្រប់ព្រះរាជអាជ្ញាទាំងអស់គឺត្រូវតែ ធ្វើការចុះកម្មសិក្សាជាមុនសិនដើម្បីទទួលយកនូវអត្ថប្រយោជន៍ និងបទពិសោធ៍អំពីការងារដែលទាក់ទងទៅ និងតំណាងអយ្យការមុន និងឈានទៅដល់ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ។

### ២. ការចុះកម្មសិក្សា និងការទទួលបានអត្ថប្រយោជន៍

បន្ទាប់ពីធ្វើការប្រឡងប្រជែងជ្រើសរើស និងមានការទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការហើយ "**សិស្សព្រះរាជអាជ្ញា ដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ ហើយនោះត្រូវបានមានការតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះរាជអាជ្ញាកម្មសិក្សាក្នុងឋានន្តរស័ក្តិជាអនុព្រះរាជ**

---

[6] -មាត្រា៧៥, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤

**អាជ្ញាថ្នាក់ដំបូង**”។ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវធ្វើកម្មសិក្សាតាមរយៈពេលមួយឆ្នាំ ដោយគិតពីកាលបរិច្ឆេទនៃការតែងតាំង។[7]

ការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាកម្មសិក្សាត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការតែងតាំងជាព្រះរាជអាជ្ញាកម្មសិក្សាមានអនុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ។[8]

ចំណែកឯអត្ថប្រយោជន៍ដែលទទួលបានវិញនោះគឺ បន្ទាប់ពីបានបំពេញកម្មសិក្សាចប់ដោយជោគជ័យហើយនោះ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិ ជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។[9] ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះតាមសំណើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប៉ុន្តែចំពោះព្រះអាជ្ញាកម្មសិក្សា ដែលធ្វើកម្មសិក្សាពុំបានជោគជ័យ ឬដោយមានការអាក់ខាន មិនបានធ្វើកម្មសិក្សាសរុបទាំងអស់ លើសពី៣០ថ្ងៃ នោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចឱ្យព្រះរាជអាជ្ញាកម្មសិក្សាបន្តធ្វើកម្មសិក្សាក្នុងរយៈពេល ១ឆ្នាំ បន្ថែមទៀត។ ម៉្យាងវិញទៀត “ប្រសិនបើព្រះរាជអាជ្ញាកម្មសិក្សាឈប់ដោយគ្មានការអនុញ្ញាតច្បាប់លើសពី៣០ថ្ងៃ ឬមិនបានទទួលជោគជ័យជាថ្មីម្តងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែមត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា”[10] ដោយអនុលោមទៅតាមបញ្ញតិមាត្រា ៨៩ នៃច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម និងព្រះអាជ្ញា។[11]

អនុលោមតាមបញ្ញតិមាត្រា ៨៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ព្រះរាជអាជ្ញាចុះកម្មសិក្សាដែលពុំមានសម្បទានគ្រប់គ្រាន់ ឬសុខភាពមិនគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួន តាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុងការបម្រើការងារដោយមិនមានភាពពេញលេញនោះអាច និងត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាបានគ្រប់ពេលវេលា។[12] “ការលុបឈ្មោះចេញ ឬការតាំងស៊ុបក្នុងក្របខណ្ឌព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល ៣ខែ យ៉ាងយូរក្រោយពីការបញ្ចប់កម្មសិក្សា។”[13]

---

-មាត្រា៨៣, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[7]
-មាត្រា៨៣, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[8]
-មាត្រា៨៤, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[9]
-មាត្រា៨៤, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[10]
-មាត្រា៨៤, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[11]
-មាត្រា៨៥, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[12]
-មាត្រា៨៤, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[13]

### ២.១ ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ

បន្ទាប់ពីព្រះរាជអាជ្ញា បានចុះកម្មសិក្សាទៅតាមរយៈពេលដែលបានកំណត់តាមសេចក្តីប្រកាសរបស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ "**ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាព ស្របទៅតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗលក្ខខណ្ឌនៃការតំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើរើសនិងតាមអតីតភាពត្រូវកំណត់យកដោយព្រះរាជក្រឹត្យ។**"[14] ដើម្បីអាចចុះឈ្មោះក្នុងតារាងតំឡើងថ្នាក់បានចៅក្រម ឬព្រះរាជអាជ្ញាត្រូវបំពេញកាតព្វកិច្ចចំនួន ២គឺ ទី១ចៅក្រម ឬព្រះរាជអាជ្ញាត្រូវបម្រើការងារក្រោយបានទទួលការតាំងស៊ប់ក្នុងក្របខណ្ឌ និងទី២ គឺចៅក្រម ឬព្រះរាជអាជ្ញាត្រូវស្ថិតក្នុងឋានន្តរស័ក្តិ ឬថ្នាក់របស់ខ្លួនយ៉ាងតិចពីរឆ្នាំគិតមកទល់ថ្ងៃទី១៣ ខែមេសា នៃឆ្នាំនីមួយៗ។ ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ចៅក្រមត្រូវផ្អែកលើមូលដ្ឋានជាអាទិ៍៖

- គោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចកិច្ចការបានល្អ
- កិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។[15]
- គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិត្រូវរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះដើម្បីដាក់ជូនឯកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរៀបចំតារាងចុះឈ្មោះព្រះរាជអាជ្ញាដែលត្រូវដំឡើងថ្នាក់ និងឋានន្តរស័ក្តិទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ។[16]

### ៣. ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈក្នុងនាមជាតំណាងអយ្យការ

ក្នុងនាមជាជាតំណាងអយ្យការ ព្រះរាជអាជ្ញា ត្រូវមានភារកិច្ចទទួលខុសត្រូវ ចំពោះកិច្ចការដែលបានប្រគល់ឱ្យ និងគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន។[17] មានន័យថា ព្រះរាជអាជ្ញាត្រូវតែអនុវត្តកិច្ចការទាំងឡាយដែលខ្លួនត្រូវបំពេញ ដោយមានទំនួសខុសត្រូវខ្ពស់ចំពោះកិច្ចការទាំងនេះ។ ដើម្បីអោយកាន់តែយល់ច្បាស់ពីការទទួលខុសត្រូវរបស់តំណាងអយ្យការ យើងត្រូវដឹងថាតើព្រះរាជអាជ្ញា ត្រូវបំពេញកាតព្វកិច្ចអ្វីខ្លះ:(១)

---

-មាត្រា២៧, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[14]

-មាត្រា២៨, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤ [15]

-មាត្រា៨៨, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤[16]

-មាត្រា៩៦, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[17]

ជាពិសេស តើទណ្ឌកម្មផ្នែកវិន័យអ្វីខ្លះអាចនិងកើតឡើង ក្នុងករណីគាត់មិនបានបំពេញតាមកាតព្វកិច្ចវិជ្ជាជីវៈអ្វីខ្លះ (២)?

### ៣.១ កាតព្វកិច្ចត្រូវបំពេញ

ព្រះរាជអាជ្ញាត្រូវតែបំពេញតួនាទី ក៏ដូចជាភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវយ៉ាងម៉ឺងម៉ាត់ និងមានភាពឆាប់រហ័ស ដោយស្របទៅតាមច្បាប់កំណត់ និងដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដូចជា ការលើកកម្ពស់សិទ្ធិមនុស្សដោយរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ។

ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ ៖

- អនុវត្តតួនាទីរបស់ខ្លួនដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយឡើយ។
- ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយលំអៀង និងត្រូវមានការប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬអត់ប្រយោជន៍ដល់ជនសង្ស័យក៏ដោយ។
- រក្សារឿងក្តីជាសម្ងាត់ លើកលែងតែក្នុងករណីត្រូវបំពេញភារកិច្ច ឬករណីដើម្បីស្វែងរកយុត្តិធម៌ ។
- ពិនិត្យមើលទៅទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះនៅពេលមានការប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីពីសិទ្ធិរបស់ជនរងគ្រោះដើម្បីឲ្យស្របតាម សេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាន របស់ជនរងគ្រោះនៅក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច ។

លើសពីនេះទៅទៀត ក្នុងនាមជាតំណាងអយ្យការ ព្រះរាជអាជ្ញាមានកាតព្វកិច្ចទាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរដូចជា គាត់មិនត្រូវប្រព្រឹត្តអំពើណាមួយដែលនាំឲ្យអាប់អោនកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គអយ្យការឡើយ។[18] ជាងនេះទៅទៀតព្រះរាជអាជ្ញា ដែលកំពុងតែបំពេញមុខងារ នៅតាមអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដែលមានបំណងផ្សព្វផ្សាយនូវអត្ថបទ ឬការសរសេរសំណេរឯកសារ ក៏ដូចជាមតិផ្សេងៗដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ នោះត្រូវតែសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុនសិន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តឡើយ ចំពោះការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។[19] ក្នុងករណីនេះព្រះរាជអាជ្ញាត្រូវប្រកាន់ជាច់ខាតនូវឥរិយាបទ អព្យាក្រឹតក្នុងវិស័យនយោបាយ។

-មាត្រា៩៦, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[18]
-មាត្រា៩៦, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជាអាជ្ញា ឆ្នាំ២០១៤[19]

ព្រះរាជអាជ្ញាទាំងអស់មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់ខ្លួនជាមុនឡើយ។ ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវធ្វើសំណើរសុំអនុញ្ញាតអវត្តមានជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីធ្វើការសម្រេចអំពីការស្នើសុំនេះ។

ក្រៅពីនេះក្នុងវិជ្ជាជីវៈព្រះរាជអាជ្ញា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈដូចជា មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិកា មុខងារទទួលអាណត្តិដោយបោះឆ្នោតដទៃទៀត ឬមុខងារជាទីប្រឹក្សា គ្រប់ឋានានុក្រមជាដើម។ បន្ថែមពីលើនេះ ព្រះរាជអាជ្ញាមិនអាចបំពេញមុខងារជាមេធាវី មុខរបរពាណិជ្ជកម្ម ឬធ្វើសកម្មភាពណា មួយផ្សេងទៀត ដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ ឬប៉ះពាល់កិត្តិយសនៃអង្គចៅក្រម។

ចំពោះព្រះរាជអាជ្ញាដែលត្រូវអនុញ្ញាតឲ្យនៅទំនេរ ហើយមានបំណងចង់ប្រកបការងារឯកជន នោះត្រូវធ្វើការជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីធ្វើការថ្លឹងថ្លែងថាគួរអនុញ្ញាតឱ្យ ឬយ៉ាងណា។ ក្នុងករណីនេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើការជំទាស់ទៅនឹងការមិនឱ្យប្រកបការងារបាន ប្រសិនបើគាត់យល់ថា សកម្មភាពនៃការប្រកបការងារនេះមានលក្ខណៈផ្ទុយនឹងកិត្តិយស សេចក្ដីទៀងត្រង់ ឬធ្វើឱ្យខូចកិត្យានុភាពនៃមុខងារព្រះរាជអាជ្ញា។

ក្នុងករណីដែលមានការបំពាននូវកាតព្វកិច្ចវិជ្ជាជីវៈណាមួយ ព្រះរាជអាជ្ញានិងត្រូវទទួលទណ្ឌកម្ម វិន័យដែលសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

### ៣.២ ទណ្ឌកម្មផ្នែកវិន័យ

យោងតាមច្បាប់ស្ដីពីលក្ខន្តិកៈ និងព្រះរាជអាជ្ញា នៅពេលដែលព្រះរាជអាជ្ញាបានប្រព្រឹត្តិអំពើដែលផ្ទុយពីកាតព្វកិច្ចវិជ្ជាជីវៈ ព្រះរាជអាជ្ញាត្រូវតែទទួលទណ្ឌកម្មផ្នែកវិន័យដូចនឹងចៅក្រមដែរ។[20] យោងតាមមាត្រា ៥៤ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានបញ្ញាត្តិថា "កំហុសរបស់ចៅក្រមក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើប៉ះពាល់ដល់កិត្តិយសសីលធម៌ស្អាតស្អំ និងសេចក្ដីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញានាំឲ្យមានទណ្ឌកម្មខាងវិន័យតាមបទបញ្ញត្តិនៃច្បាប់នេះ។ ប៉ុន្តែការប្រើប្រាស់ឆន្ទានុសិទ្ធរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ។"[21]

យោងតាមច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានកំណត់ថា "**ទណ្ឌកម្មវិន័យមិនមែនជា**

---

-មាត្រា៩៩, ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤[20]

-មាត្រា៥៤, ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤[21]

**ឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើបទល្មើសណាមួយត្រូវបានប្រព្រឹត្តិ**"[22] ក្នុងន័យនេះប្រសិនបើអំពើដែលព្រះរាជអាជ្ញាបានប្រព្រឹត្តិនោះ គឺជាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌហើយក៏ជាអំពើដែលផ្ទុយប្រាសចាក នឹងកាតព្វកិច្ចវិជ្ជាជីវៈ នោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើការដាក់ទណ្ឌកម្មវិន័យទៅលើព្រះរាជអាជ្ញានោះបាន ប៉ុន្តែការដាក់ទណ្ឌកម្មវិន័យនេះមិនបានធ្វើឲ្យបណ្តឹងអាជ្ញារលត់ឡើយ គឺព្រះរាជអាជ្ញានៅតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌវិន័យវិញ ព្រះរាជអាជ្ញាអាចត្រូវបានផ្អាកពីមុខងារបណ្តោះអាសន្ន ដោយប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពេលដំណើរការនីតិវិធីវិន័យបានចាប់ផ្តើម។

ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, មាត្រា ៥៤ បានកំណត់ទណ្ឌកម្មវិន័យដែលត្រូវបានបែងចែកជា២ ថ្នាក់មានដូចតទៅ ៖

**ក.ទណ្ឌកម្មថ្នាក់ទី១**

- ការស្តីបន្ទោសដោយផ្ទាល់មាត់
- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងតំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឲ្យលើសពី ២ឆ្នាំ ទេ ឬលុបឈ្មោះចេញពីតារាងឡើងថ្នាក់ និងឋានន្តរស័ក្តិវិញក្នុងករណីដែលមានចុះឈ្មោះរួចហើយ។

**ខ.ទណ្ឌកម្មទី២**

- ការផ្លាស់ប្តូរដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម
- ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី ១ឆ្នាំ
- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
- ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ
- ការបណ្តេញចេញពីក្របខណ្ឌ។

ចំពោះទណ្ឌកម្មទី២ នេះត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

-មាត្រា៥៤, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤[22]

# ជំពូកទី២

# តួនាទី និងភារកិច្ចរបស់ស្ថាប័នអយ្យការ

## ផ្នែកទី១ មុខងារនៃស្ថាប័នអយ្យការ

ចំពោះមុខងារនៃស្ថាប័នអយ្យការដែលយើងនិងយកមកសិក្សាលម្អិតនោះ គឺទាក់ទងទងទៅនិងមុខងាររបស់តំណាងអយ្យការសាលាដំបូងរាជធានីខេត្ត។

យោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថា "**មានតែអង្គការអយ្យការទេ ដែលមានសិទ្ធធ្វើបណ្តឹងអាជ្ញា**"[23] និងយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់បន្ថែមទៀតថា "**បណ្តឹងអាជ្ញាត្រូវអនុវត្តន៍ក្នុងនាមជាផលប្រយោជន៍ទូទៅដោយអយ្យការ**។"[24] ដូចនេះព្រះរាជអាជ្ញាគឺជាម្ចាស់នៃបណ្តឹងអាជ្ញាដែលជាភាគីតំណាងឲ្យប្រយោជន៍ទូទៅក្នុងរឿងក្តីព្រហ្មទណ្ឌចំពោះមុខតុលាការ។

ដើម្បីធានារ៉ាប់រងកិច្ចការគ្រប់គ្រប់យ៉ាងនូវដែនអនុវត្តន៍នៃច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាសេចក្តីសម្រេចខាងព្រហ្មទណ្ឌ[25] ប្រកបដោយយុត្តិធម៌ ស្ថាប័នអយ្យការត្រូវប្រត្តិបត្តិនូវគោលការណ៍ច្បាប់ជាមូលដ្ឋានប្រកបដោយចរិតលក្ខណៈគតិយុត្តិ។ ដូចបានដឹងហើយថា នៅក្នុងអយ្យការនីមួយៗ មានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ជាស្ថាប័នអយ្យការអមសាលាដំបូង នៃសមត្ថកិច្ចដែនដីតាំងដែលតុលាការតាំងនៅ។ ដំណើរការនីតិវិធីរឿងក្តីណាមួយត្រូវបានធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដែលមានការកំណត់នូវអត្ថិភាពនៃបទល្មើស[26] ក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញាខាងរឿងក្តីព្រហ្មទណ្ឌ មិនត្រឹមតែកំណត់បទល្មើស ចង្អុលបង្ហាញសកម្មភាពនៃអំពើល្មើសរបស់ជនប្រព្រឹត្តបទល្មើស កំណត់ទោស និងនីតិវិធីនៃការអនុវត្តទោស[27] មានលក្ខណៈស៊ីសង្វាក់គ្នា និងភស្តុតាង ក្នុងការសុំឲ្យអនុវត្តន៍ចំពោះមុខយុត្តាធិកាស៊ើបសួរ យុត្តធិការជំនុំជម្រះ និងធ្វើសេចក្តីសន្និដ្ឋានបង្ហាញពីពិរុទ្ធភាពឲ្យតុលាការអនុវត្តន៍តាមច្បាប់[28] មិនតែប៉ុណ្ណោះទេគឺត្រូវធ្វើសេចក្តីសង្ខេបអង្គហេតុ កំណត់ឈ្មោះបទល្មើស បង្ហាញអត្ថបទច្បាប់ដែលកំណត់បទល្មើស កំណត់ឈ្មោះ ឬអត្តសញ្ញាណ ឬសាវតាជាតិបុគ្គលដែលត្រូវចោទ។[29]

---

-មាត្រា១៣១, រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣[23]
-មាត្រា៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[24]
-មាត្រា១, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[25]
-មាត្រា១និងមាត្រា៤, ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧[26]
-មាត្រា១, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[27]
-មាត្រា៤និងមាត្រា២៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[28]
-មាត្រា៤៤ និងមាត្រា៤៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[29]

## កថាខណ្ឌទី១ ស្ថាប័នការអយ្យការអមសាលាដំបូងរាជធានីខេត្ត

ចំពោះសាលាដំបូងរាជធានីខេត្ត តំណាងស្ថាប័នអយ្យការមានតែ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ប៉ុណ្ណោះ។ ដោយឡែកព្រះរាជអាជ្ញា គឺជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញារង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប៉ុន្តែព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា គឺអាចប្រើប្រាស់នូវសិទ្ធអំណាចដែលខ្លួនមានក្នុងការធ្វើការចោទប្រកាន់ និងធ្វើការស្រាវជ្រាវទៅលើបទល្មើសណាមួយ។

### ១. អំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីខេត្ត

ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីខេត្ត គឺមានអំណាចនៅក្នុងការ បើកការស៊ើបអង្កេតបឋមទៅលើរឿងក្តីព្រហ្មទណ្ឌដែលខ្លួនទទួលពីមន្ត្រីនគរបាលយុត្តិធម៌ ឬពីប្រភពបណ្តឹងផ្ទាល់របស់រូបវន្តបុគ្គល។ នៅក្នុងសមត្ថកិច្ចនៃការស៊ើបអង្កេតនេះ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីដឹកនាំធ្វើការស៊ើបអង្កេតនៅក្នុងសមត្ថកិច្ចដែនដីខ្លួន។ ពេលដែលព្រះរាជអាជ្ញាចុះទៅដល់កន្លែងស៊ើបអង្កេតព្រះរាជអាជ្ញា អាចធ្វើការណែនាំអ្វីដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ណាមួយព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចបានគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌ដោយអាចដកហូតសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលស្ថិតក្រោមអំណាចដែនសមត្ថកិច្ចរបស់ខ្លួន ហើយរៀបចំឲ្យមាននូវភ្នាក់ងារមន្ត្រីថ្មីជំនួសវិញអោយធ្វើការស៊ើបអង្កេតបន្ត។

### ២. សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា

នៅក្នុងសាលាដំបូងមាន ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ជាតំណាងស្ថាប័នអយ្យការអមសាលាដំបូងនៃយុត្តាធិការដែនដីនោះ[30] ដោយមានកាតព្វកិច្ចអនុវត្តតួនាទីរបស់ខ្លួនក្នុងបណ្តឹងព្រហ្មទណ្ឌ។ ដើម្បីអាចដំណើរការនូវនីតិវិធីនៃការស៊ើបអង្កេត(ស៊ើបសួរ) បង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស ធ្វើការចោទប្រកាន់ក្នុងនាមតំណាងអយ្យការ និងបញ្ជូនទៅជំនុំជម្រះ [31] ដោយសម្អាង លើមូលដ្ឋានច្បាស់តាមច្បាប់។

ដូច្នេះហើយទើបគេសន្មត់ថាៈ ព្រះរាជអាជ្ញាជាគូដើមជានិច្ច[32] ដោយសារតែព្រះរាជអាជ្ញាជាអ្នកចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញា សុំអនុវត្តចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ព្រះរាជអាជ្ញាមិនអាចដើរតួជាគូក្តីរណបក្នុងរឿងក្តីព្រហ្មទណ្ឌ ដូចរឿងក្តីរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីបានទេ។ នីតិវិធីតាមផ្លូវតុលាការ ជាហេតុអាចនាំឲ្យមានការភ័យខ្លាចដល់ជនរងគ្រោះ និងអាចនាំឲ្យជនរងគ្រោះបាត់ជំនឿចិត្តលើតុលាការមិនហ៊ានបង្ហាញភស្តុតាង និងជូនសាក្សីជាដើម។

-មាត្រា៣៦ និងមាត្រា២៨៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧, និងមាត្រា ៤៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា ឆ្នាំ១៩៩៣[30]
-មាត្រា២ និងមាត្រា៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[31]
-មាត្រា៤ និងមាត្រា៤៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងមាត្រា ៥២នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា ឆ្នាំ១១៩៣ [32]

- **ព្រះរាជអាជ្ញារង៖** ប្រើប្រាស់អំណាចតាំងអស់ក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើសស្ថិតក្រោមអំណាចព្រះរាជអាជ្ញា គឺប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ។[33]
- **អំណាចព្រះរាជអាជ្ញា៖** ចំពោះភ្នាក់ងារនគបាលយុត្តិធម៌ ព្រះរាជអាជ្ញាមានអំណាចដឹកនាំសម្របសម្រួលសកម្មភាពមន្ត្រីនគបាលយុត្តិធម៌ក្នុងសមត្ថកិច្ចដែនដីនៃតុលាការ ដែលខ្លួនតាំងនៅចុះដល់ទីកន្លែងស៊ើបអង្កេតណែនាំដល់ភ្នាក់ងារមន្ត្រីនគរបាលយុត្តធម៌ ក្នុងការស៊ើបអង្កេតអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគបាលយុត្តិធម៌ និងរៀបចំអ្នកជំនួសក្នុងករណីចាំបាច់។

ករណីមានការឃាត់ខ្លួនជនល្មើស ព្រះរាជអាជ្ញាអាចចូលរួមស្តាប់ចម្លើយអាចត្រួតពិនិត្យ ការអនុវត្តវិធានការឃាត់ខ្លួន ការគោរពទម្រង់ច្បាប់ និងការកាន់កាប់កន្លែងឃាត់ខ្លួន។[34]

### កថាខណ្ឌទី២ ការអនុវត្តបណ្តឹងអាជ្ញាដោយតំណាងអយ្យការ

បណ្តឹងអាជ្ញា ឬជាទូទៅត្រូវបានហៅថា **បណ្តឹងព្រហ្មទណ្ឌ** មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជនដែលបានប្រព្រឹត្តិបទល្មើសតាមកំណត់ច្បាប់។ បណ្តឹងអាជ្ញាត្រូវអនុវត្តលើបុគ្គលគ្រប់រូបទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ [35]

យោងតាមមាត្រា១៣១ ច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា **មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។** ដូច្នេះការធ្វើបណ្តឹងអាជ្ញាគឺជាសិទ្ធិផ្តាច់មុខរបស់ស្ថាប័នអយ្យការ ហើយបណ្តឹងអាជ្ញានឹងត្រូវចាប់ផ្តើមដំណើរការ ដោយការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយដោយអយ្យការ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[36] ដើម្បីអាចចាប់ផ្តើមដំណើរការបណ្តឹងអាជ្ញាបាន ព្រះរាជអាជ្ញាត្រូវតែធ្វើការស៊ើបអង្កេតបឋមដើម្បីប្រមូលពណ៌មាន និងភស្តុតាងដាក់បន្ទុកឲ្យមានលក្ខណៈគ្រប់គ្រាន់ និងអាចជឿជាក់បានថា បទល្មើសនោះពិតជាត្រូវបានប្រព្រឹត្តមែន ហើយជនដែលបានប្រព្រឹត្តបទល្មើស គឺជាអ្នកដែលព្រះរាជអាជ្ញាកំពុងសង្ស័យពិតប្រាកដមែន។ ក្រោយពីធ្វើការស៊ើបអង្កេត ព្រះរាជអាជ្ញាត្រូវធ្វើការសម្រេចថា តើគួរធ្វើការដាក់ឲ្យដំណើរការលើបណ្តឹងអាជ្ញា ឬធ្វើការតម្កល់ទុកឥតចាត់ការ។[37]

---

-មាត្រា៣៨, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[33]

-មាត្រា៣៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[34]

-មាត្រា៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[35]

-មាត្រា៣៨, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[36]

-មាត្រា៤០, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[37]

ដើម្បីអាចសិក្សាឲ្យបានកាន់តែស៊ីជម្រៅថែមទៀតនោះយើងត្រូវដឹងថា តើអ្វីជាបណ្តឹងអាជ្ញា ? (១) តើព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមផ្លូវអ្វីខ្លះក្នុងសំណុំរឿងព្រហ្មទណ្ឌ (២) ?

### ១. បណ្តឹងអាជ្ញា

ជាទូទៅ នៅពេលមានបទល្មើសមួយកើតឡើង អាចមានបណ្តឹងពីរផ្សេងគ្នា តែងតែកើតឡើង គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី។

នៅព្រះរាជាណាចក្រកម្ពុជាយើងគឺ បានទទួលស្គាល់នូវបណ្តឹងពីរប្រភេទនេះដោយបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងមួយប្រភេទ ដែលធ្វើឡើងក្នុងគោលបំណងធ្វើឱ្យ បានជួសជុលការខូចដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។ ចំណែកឯបណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញពីរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។[38] ក្នុងបណ្តឹងទាំងពីរប្រភេទនេះទាក់ទាងទៅនឹងការរំលត់នៃបណ្តឹងគឺមានលក្ខណៈខុសគ្នាទៅ តាមលក្ខខណ្ឌនៃប្រភេទបណ្តឹងដោយបណ្តឹងប្រភេទខ្លះទោះបីជាមានការដកនៅពាក្យបណ្តឹងពីជនរងគ្រោះទៅហើយក្តី ក៏បណ្តឹងនោះមិនមានការរំលត់បានដែរ។ ក្នុងបណ្តឹងដែលរំលត់មិនបាននេះគឺសំដៅទៅលើបណ្តឹងដែលទាក់ទងទៅនិងរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាគឺជាម្ចាស់នៃបណ្តឹងអាជ្ញា ក្នុងករណីដែលជនល្មើសបានសងជាសំណងទៅជនរងគ្រោះផ្នែករដ្ឋប្បវេណីទៅហើយក្តី ក៏ព្រះរាជអាជ្ញានៅតែអាចធ្វើការចោទប្រកាន់ទៅលើជននោះបានដដែល ឬបើកអោយមានការបន្តស៊ើបអង្កេតទៅលើរឿងក្តីនេះដែរ។ **ឧទាហរណ៍៖** មានគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងជនបង្ករបានសងជាសំណងរដ្ឋប្បវេណីទៅឱ្យជនរងគ្រោះហើយ ដោយជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹង និងមិនចង់ប្តឹងតទៅទៀតនោះទេ ប៉ុន្តែត្រង់ចំណុចនេះទោះបីជាជនរងគ្រោះគ្រោះដកពាក្យបណ្តឹងទៅហើយក្តី ក៏ព្រះរាជអាជ្ញានៅតែធ្វើការចោទប្រកាន់ទៅលើជននោះដដែល ព្រោះថាបណ្តឹងអាជ្ញាគឺជាបណ្តឹងមួយដែលធ្វើឡើងសម្រាប់ការពារផលប្រយោជន៍ទូទៅនៅក្នុងសង្គមទាំងមូល។

ដូចនេះក្នុងរឿងក្តីព្រហ្មទណ្ឌមិនអាចដោះស្រាយវិវាទទាំងឡាយតាមរយៈក្រៅប្រព័ន្ធតុលាការហើយចប់រឿងនោះទេ។

-មាត្រា២, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[38]

### ១.១ ភាពខុសគ្នារវាងបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

យោងទៅតាមមាត្រា២ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ផងដែរថា បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងពីរផ្សេងគ្នា។ តាមរយៈមាត្រានេះអាចអោយយើងសម្គាល់បានថាបណ្តឹងទាំងពីរនេះគឺមានចំណុចខុសគ្នាត្រង់

- **គោលបំណង**
- បណ្តឹងអាជ្ញា៖ ជួសជុលព្យសនកម្ម ដែលបានកើតឡើងចេញពីបទល្មើសព្រហ្មទណ្ឌ ដែលបានបង្ករជាផលប៉ះពាល់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ
- បណ្តឹងរដ្ឋប្បវេណី៖ ជួសជុលព្យសនកម្ម ដែលបានកើតឡើងចេញពីបទល្មើសព្រហ្មទណ្ឌ ដែលបានបង្ករជាផលប៉ះពាល់ដល់ជនរងគ្រោះ។
- **មូលដ្ឋានច្បាប់**
- បណ្តឹងអាជ្ញា៖ ផ្អែកទៅលើក្រមព្រហ្មទណ្ឌ ដែលមានកំណត់អំពីគោលការណ៍នីត្យានុកូលភាព
- បណ្តឹងរដ្ឋប្បវេណី៖ ផ្អែកលើអំពើអនីត្យានុកូលដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី។
- **ទណ្ឌកម្ម**
- បណ្តឹងអាជ្ញា៖ ទោសពិន័យជាប្រាក់ និងការដាក់ពន្ធនាគារ
- បណ្តឹងរដ្ឋប្បវេណី៖ សងជាសំណងទៅតាមព្យសនកម្មដែលបានកើតឡើងដោយមិនមានការដាក់ពន្ធនាគារទេ ។
- **ភាគី**
- បណ្តឹងអាជ្ញា៖ អយ្យការ និងជនល្មើស
- បណ្តឹងរដ្ឋប្បវេណី៖ ជនរងគ្រោះផ្នែករដ្ឋប្បវេណី។
- **សាលាជម្រះក្តី**
- បណ្តឹងអាជ្ញា៖ ធ្វើបានតែចំពោះមុខសាលាជម្រះក្តីរឿងព្រហ្មទណ្ឌ
- បណ្តឹងរដ្ឋប្បវេណី៖ជនរងគ្រោះអាចធ្វើការជម្រះក្តីនៅមុខសាលាចម្រះក្តីព្រហ្មទណ្ឌក៏បាន រដ្ឋប្បវេណីក៏បាន ។

### ១.២ ការរំលត់បណ្តឹងអាជ្ញា

នៅពេលដែលបណ្តឹងអាជ្ញាត្រូវបានរំលត់ទៅព្រះរាជអាជ្ញា នឹងលែងមានសិទ្ធនៅក្នុងការអនុវត្តទៅលើរឿងក្តីនោះតទៅទៀតហើយ។

ផ្អែកទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៧ បណ្តឹងអាជ្ញានឹងត្រូវបានរំលត់ក្នុងករណីដូចជា៖

- មរណភាពនៃជនល្មើស

- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ

មរណភាពនៃជនល្មើស

បណ្ដឹងអាជ្ញានឹងត្រូវរលត់នៅពេលដែលជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ បានទទួលមរណភាព បើផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា២៤ នៃក្រមព្រហ្មទណ្ឌ ដែលសំដៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ពោលគឺបុគ្គលណាជាអ្នកប្រព្រឹត្តបទល្មើស បុគ្គលនោះជាអ្នកទទួលខុសត្រូវទោសព្រហ្មទណ្ឌ ដោយមិនអាចឱ្យអ្នកដទៃ ឬសាច់ញាតិរបស់ខ្លួនទទួលទោសជំនួសបានឡើយ។ ដូចនេះដំណាក់កាលនីតិវិធីទាំងអស់នៃសំណុំរឿងព្រហ្មទណ្ឌនឹងត្រូវបញ្ចប់ ប្រសិនបើជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ បានទទួលមរណៈភាពដោយសារតែបណ្ដឹងអាជ្ញាត្រូវបានរលត់។

ការផុតអាជ្ញាយុកាល

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលដែលកំណត់ដោយច្បាប់ ដែលក្នុងករណីដែលផុតរយៈពេលកំណត់នេះ នោះព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ។[39] រយៈពេលនៃអាជ្ញាយុកាលត្រូវប្រែប្រួលទៅតាមប្រភេទនៃបទល្មើសនីមួយៗពោលគឺ ១(មួយ) ឆ្នាំ ចំពោះបទលហុ ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម និង ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ ហើយត្រូវរាប់គិតចាប់ពីពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។

**ឧទាហរណ៍៖** លោក (ក) បានបង្កអំពើហិង្សាដោយចេតនាដែលជាបទមជ្ឈិម លើលោក (ខ) ដែលជាមិត្តភក្តិ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ ហើយធ្វើការរត់គេចខ្លួនទៅក្រៅប្រទេស។ ក្រោយមកជនរងគ្រោះមិនបានដាក់ពាក្យបណ្ដឹង ដើម្បីឱ្យមានការស៊ើបអង្កេតស្វែងរក លោក (ក) នោះឡើយដោយយល់ឃើញថាធ្លាប់ជាមិត្តភក្តិនឹងគ្នា។ ដូចនេះ ប្រសិនបើលោក (ក) ត្រឡប់មកប្រទេសកម្ពុជាវិញនៅរយៈពេល ៥ ឆ្នាំក្រោយ ពោលគឺថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៧ នោះខាងស្ថាប័នអយ្យការមិនអាចធ្វើការចោទប្រកាន់លើបទល្មើសហិង្សាដោយចេតនានេះបានទៀតទេ ដោយសារតែរយៈពេលនៃអាជ្ញាយុកាលត្រូវបានផុតកំណត់។

ដោយឡែកយើងត្រូវកត់សម្គាល់ផងដែរថា រយៈពេលនៃអាជ្ញាយុកាលនឹងត្រូវរាប់សារជាថ្មីម្ដងទៀតនៅពេលដែលបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ មានន័យថា ប្រសិនបើភ្លាមៗ ក្រោយពេលដែលរង

-មាត្រា២, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[39]

របួស លោក (ខ) បានដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ដែលឈានដល់មានកាចោទប្រកាន់ពីស្ថាប័នអយ្យការ ឬ បើកការស៊ើបសួរពីសំណាក់ចៅក្រមស៊ើបសួរនោះរយៈពេលនៃអាជ្ញាយុកាលនឹងត្រូវរាប់សារជាថ្មីម្ដង នៅពេលដែលបញ្ចប់ការចោទប្រកាន់ ឬការស៊ើបសួរនោះ។

**ការលើកលែងទោសទូទៅ**

ការលើកលែងទោសទូទៅ នេះមិនសំដៅទៅលើ ការលើកលែងទោសដោយជារាជានុសិទ្ធិរបស់ព្រះមហាក្សត្រ ដែលជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យជាតិធំៗនោះទេ ។ ការលើកលែងទោសទូទៅដែលធ្វើឱ្យបណ្ដឹងអាជ្ញាមួយរលត់ សំដៅលើការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភា សម្រាប់លើកលែងទោស ឬ លុបចោលនូវប្រភេទបទល្មើសណាមួយដែលនាំឱ្យបណ្ដឹងអាជ្ញាដែលកំពុងដំណើរការក្នុងនីតិវិធីនឹងត្រូវរលត់ ។

**និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**

ដូចបានបញ្ជាក់ជូនខាងលើ ស្ថាប័នអយ្យការអាចធ្វើការចោទប្រកាន់ទៅលើអំពើដែលត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌបានតាមរយៈបណ្ដឹងអាជ្ញា ប៉ុន្តែទោះបីជាមានការចោទប្រកាន់ក៏ដោយ ក៏បណ្ដឹងអាជ្ញាអាចត្រូវបានរលត់ផងដែរ ប្រសិនបើបទល្មើសនោះត្រូវបាននិរាករណ៍ ពោលគឺអំពើដែលបានប្រព្រឹត្តដោយជនល្មើសនោះលែងត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌតទៅទៀត ។

**អាជ្ញាអស់ជំនុំ**

ប្រសិនបើជនជាប់ចោទត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរ តាមរយៈសាលក្រម ឬសាលដីកាណាមួយហើយ ជនជាប់ចោទនោះមិនអាចត្រូវបានចោទប្រកាន់ចំពោះអំពើដដែលទៀតនោះទេ ទោះបីជាការចោទប្រកាន់នោះក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។ ក្រៅពីមូលហេតុដែលបានរៀបរាប់ខាងលើនេះមាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានចែងពីមូលហេតុចំនួន៣ ផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញាផងដែរ៖

- ដោយការសម្របសម្រួលជាមួយរដ្ឋ
- ដោយការដកពាក្យបណ្ដឹង
- ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។

- **ដោយការសម្របសម្រួលជាមួយរដ្ឋ** គឺសំដៅទៅលើការបង់ពិន័យអន្តរកាល ដូចជាបទល្មើសពាក់ព័ន្ធជាមួយនឹងពន្ធ ដូចជាការបង់ប្រាក់ពិន័យអន្តរការណ៍ចំពោះបទល្មើសចរាចរណ៍។
- **ដោយការដកពាក្យបណ្ដឹង** ប្រសិនបើមូលហេតុនៃបណ្ដឹង គឺជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ក្នុងលក្ខខណ្ឌនេះ យើងឃើញបទល្មើសមួយចំនួនជាអាទិ៍ បទរំលោភសេពសន្ថវៈ

និង អំពើហិង្សាក្នុងគ្រួសារជាដើម។ ក្នុងបទរំលោភសេពសន្ថវៈ ប្រសិនបើជនរងគ្រោះដកពាក្យប្តឹងដោយអះអាង ថាខ្លួនបានយល់ព្រមនឹងបុរសនោះនាពេលរួមភេទ ព្រះរាជអាជ្ញានឹងមិនអាចធ្វើការចោទប្រកាន់ បានទៀតទេ ក៏ប៉ុន្តែចំពោះការរួមភេទជាមួយនឹងអនីតិជនក្រោមអាយុ ១៥ឆ្នាំ ទោះបីជាមានការសម្តែង ឆន្ទៈយល់ព្រមក៏ដោយ ក៏អំពើនោះនៅតែជាបទល្មើសព្រហ្មទណ្ឌដែលត្រូវបានជាកម្មវត្ថុនៃការចោទប្រកាន់របស់តំណាងអយ្យការ។ ចំណែកឯ រឿងអំពើហិង្សាក្នុងគ្រួសារវិញ ប្រសិនបើប្រពន្ធ ឬប្តីដែលជាជនរងគ្រោះដកពាក្យបណ្តឹងចំពោះសហព័ទ្ធរបស់ខ្លួនវិញនោះ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានទេ។[40] មួយវិញទៀត ចំពោះករណីទ្វេរពន្ធភាពក៏ដូចគ្នា ប្រសិនបើភរិយាព្រមដកពាក្យបណ្តឹងវិញ រឿងនេះក៏ត្រូវបានបញ្ចប់ដែរ។

- **ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល** ជាគោលការណ៍បទល្មើសព្រហ្មទណ្ឌមិនអាចសម្របសម្រួលបានឡើយ។ ប៉ុន្តែច្បាប់ពិសេសអាចសម្របសម្រួលបាន ជាក់ស្តែងចំពោះបទល្មើសដែលប៉ះពាល់ផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទមជ្ឈិមស្រាល ឬលហុ គូភាគីអាចផ្សះផ្សា ឬសម្របសម្រួលគ្នាដើម្បីបញ្ចប់វិវាទបាន។[41]

សរុបមក មូលហេតុនៃការរលត់នៃបណ្តឹងអាជ្ញា គឺជាមូលហេតុដែលបានកំណត់នៅក្នុងច្បាប់ជាធរមាន ហើយកាលណាបណ្តឹងអាជ្ញាត្រូវបានរលត់ដោយផ្អែកលើមូលហេតុណាមួយដូចមានរៀបរាប់ខាងលើនេះ នោះរាល់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។

## ផ្នែកទី២ សេចក្តីសម្រេចក្នុងការចោទប្រកាន់របស់តំណាងអយ្យការ

នៅក្នុងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមានសិទ្ធក្នុងការសម្រេចថា គួរចោទប្រកាន់(១) ឬតម្កល់ទុកឥតចាត់ការ(២)។

### កថាខណ្ឌទី១ ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ

ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ គឺជាការធ្វើបណ្តឹងអាជ្ញារបស់តំណាងអយ្យការ ហើយមុននឹងឈានទៅទៅរកការចោទប្រកាន់បាន លុះត្រាតែពិនិត្យទៅមើលឃើញថាបទល្មើសនោះពិតជាមានធាតុផ្សំគ្រប់គ្រាន់ដូចជា៖

- គោលការនីត្យានុគោល
- គោលការណ៍សត្យានុម័ត
- គោលការណ៍អត្តនោម័ត

-មាត្រា៣៦, ច្បាប់ស្តីពីការទប់ស្កាត់គ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥[40]

-មាត្រា២៦, ច្បាប់ស្តីពីការទប់ស្កាត់ អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជន រងគ្រោះ ឆ្នាំ២០០៥[41]

ការចោទប្រកាន់របស់ព្រះរាជអាជ្ញាអាចធ្វើទៅបានលុះត្រាតែមានការទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌តាមរយៈជនរងគ្រោះដាក់ពាក្យបណ្តឹងមក និងពាក្យបរិហារដែលខ្លួនបានទួលដោយផ្ទាល់។ ដោយយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីការចោទប្រកាន់របស់តំណាងអយ្យការមានដូចជា ៖

១.ការបើកការស៊ើបសួរ

២.ការបញ្ជូនជំនុំជម្រះផ្ទាល់

៣.ការបង្ហាញខ្លួនភ្លាមៗ ។

### ១. ការបើកការស៊ើបសួរ

ព្រះរាជអាជ្ញាអាចការបើកការស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរជាដាច់ខាត។ ចំពោះបទមជ្ឈិម ព្រះរាជអាជ្ញាក៏អាចធ្វើការចោទប្រកាន់បាន តាមរយៈដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរផងដែរ។ ហើយចំពោះដីការសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរត្រូវផ្អែកទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ចំពោះទម្រង់នេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះ ត្រូវទុកជាមោឃៈ។

### ២ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលព្រះរាជអាជ្ញា យល់ឃើញថាសំណុំរឿងដែលខ្លួនទទួលបាន មិនមានភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែមទេ ព្រះរាជអាជ្ញាត្រូវធ្វើការបញ្ជូនរឿងក្តីទៅតុលាការជំនុំជម្រះតែម្តងតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ចំពោះការជំនុំជម្រះផ្ទាល់នេះគឺធ្វើទៅបានក្នុងករណីបទមជ្ឈិម និងបទលហុប៉ុណ្ណោះដែលជាបទល្មើសមានលក្ខណៈស្រាលមិនសូវបង្ករជាភាពអសន្តិសុខដល់សង្គមខ្លាំង មានន័យថាព្រះរាជអាជ្ញាមានសិទ្ធិជ្រើសរើសវិធីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់បាន នៅពេលយល់ឃើញថានីតិវិធីនេះផ្តល់សារៈប្រយោជន៍ដើម្បីពន្លឿននីតិវិធី។ ក៏ប៉ុន្តែអត្តសញ្ញាណរបស់ជនល្មើសជាលក្ខខណ្ឌចាំបាច់នៅក្នុងនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែលទាមទារការកំណត់ឲ្យបាននូវអត្តសញ្ញាណរបស់ជនល្មើសដោយខានមិន

បាន។[42] ករណីប្រសិនបើចៅក្រមជំនុំជម្រះដែលបានទទួលសំណុំរឿងពីព្រះរាជអាជ្ញា តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានពិនិត្យឃើញថា សំណុំរឿងនេះមិនអាចជំនុំជម្រះបានដោយសារតែមានភាពស្មុគស្មាញ ឬភស្តុតាងមិនគ្រប់គ្រាន់ ឬមានការពាក់ព័ន្ធនឹងបុគ្គលស្វែងរកក្នុងការបញ្ជាក់អត្តិភាពនៃបទល្មើស ចៅក្រមជំនុំជម្រះអាចនឹងបង្វិលសំណុំរឿងនេះទៅព្រះរាជអាជ្ញា។ មានន័យថាប្រសិន បើជនល្មើសជាអញ្ញាតជន នោះព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានឡើយ។ ដីកាកោះហៅ មានថេរវេលា និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅចំពោះមុខតុលាការះ

- រយៈពេល ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- មានរយៈពេល ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀត នៃព្រះរាជាណាចក្រកម្ពុជា ។
- មានរយៈពេល ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅកន្លែងផ្សេង ក្រៅពីខាងលើ ។[43]

ចំពោះការប្រគល់ដីការកោះហៅបញ្ជូនទៅជំនុំជម្រះនេះ ព្រះរាជអាជ្ញា ឬអាជ្ញាសាលាក៏អាចប្រគល់ឲ្យជនជាប់ចោទផ្ទាល់ផងដែរ។[44] ក្រៅពីអាជ្ញាសាលានិងព្រះរាជអាជ្ញា ដីកាកោះនេះក៏អាចប្រគល់ជូនប្រធានពន្ធនាគារ ឬប្រធានមណ្ឌលឃុំខ្លួន ដោយក្រឡាបញ្ជី ដោយនគរបាលយុត្តិធម៌ ឬតាមផ្នែករដ្ឋបាល។[45]

### ៣. នីតិវិធីបង្ហាញខ្លួនភ្លាម

ក្រៅពីការបើកការស៊ើបសួរ និងការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាអាចចោទប្រកាន់តាមនីតិវិធីបង្ហាញខ្លួនភ្លាម ដោយសារនីតិវិធីនេះមានលក្ខណៈលឿនជាង និងដើម្បីជួយជម្រុញដល់ដំណើររឿងក្តីព្រហ្មទណ្ឌឱ្យបានឆាប់រហ័ស កុំឱ្យមានការកកស្ទះសំណុំរឿង។ មុននឹងព្រះរាជអាជ្ញាសម្រេចថា ប្រើប្រាសនីតិវិធីនេះ នេះព្រះរាជអាជ្ញាត្រូវ ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលបញ្ជូនមកឲ្យខ្លួន
- ឲ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលខ្លួនបង្ហាញភ្លាមៗ [46]

ចំពោះការបញ្ជូនសំណុំរឿងក្តីដែលធ្វើឡើងតាមរយៈ **នីតិវិធីបង្ហាញខ្លួនភ្លាម** ដោយត្រូវបំពេញលក្ខខណ្ឌដូចជាះ

---

-មាត្រា៤៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[42]

-មាត្រា៤៥៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[43]

-មាត្រា៤៥៨និង៤៥៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[44]

-មាត្រា៤៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[45]

-មាត្រា៤៧និង៤៨, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[46]

- បទមជ្ឈិមជាក់ស្តែង
- បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចមួយឆ្នាំ និងជាអតិបរមាប្រាំឆ្នាំនៃទោសដែលច្បាប់សារធាតុបានកំណត់
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ផ្តួនល្មមជំនុំជម្រះបាន។

បន្ទាប់ពីលក្ខខណ្ឌទាំងបួននេះបានបំពេញរួចហើយ នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមអាចអនុវត្តបានលុះត្រាតែមានវត្តមានរបស់ជនល្មើស (រឿងមានខ្លួន)។ មូលហេតុនេះហើយបានជាក្រមនីតិវិធីព្រហ្មទណ្ឌប្រើពាក្យថា "**កំណត់ហេតុ**" មានន័យថា កាលណាជនល្មើសមានវត្តមានក្នុងនីតិវិធីព្រះរាជអាជ្ញានឹងបញ្ជូនទៅជំនុំជម្រះនៅមុខចៅក្រមជំនុំជម្រះហើយ គឺមិនចាំបាច់អ្វីក្នុងការប្រើប្រាស់ដីកាដែលជាកម្មវត្ថុនៃការជូនដំណឹងទៀតទេ។

ដូច្នេះ ព្រះរាជអាជ្ញាអាចធ្វើនីតិវិធីនេះដោយបញ្ជូនជនជាប់ចោទជាមួយនឹងសំណុំរឿងទៅចៅក្រមជំនុំជម្រះ តាមរយៈកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមៗ ដើម្បីធ្វើការជំនុំជម្រះនៅថ្ងៃដែលបង្ហាញខ្លួនភ្លាមនេះតែម្តង។ ប៉ុន្តែប្រសិនបើជនជាប់ចោទត្រូវការរយៈពេលដើម្បីរៀបចំការពារខ្លួន ការជនុំជម្រះ(សវនាការ)[47] សំណុំរឿងនេះនឹងត្រូវលើកទៅពេលសវនាការជំនុំជម្រះលើកក្រោយ តែចៅក្រមជំនុំជម្រះនឹងសម្រេចជំនុំជម្រះមុនអង្គសេចក្តីពាក់ព័ន្ធនឹងការឃុំខ្លួនជាមុនសិន ហើយសវនាការជំនុំជម្រះលើកក្រោយ គឺមិនឲ្យលើសរយៈពេលពីរ(០២) សប្តាហ៍នោះទេ។

**កថាខណ្ឌទី២ ការតម្កល់រឿងទុកឥតចាត់ការ**

ព្រះរាជអាជ្ញា ត្រូវបានកំណត់ថាជាម្ចាស់បណ្តឹងអាជ្ញា និងអាចចោទប្រកាន់។ មុននឹងក្លាយជាម្ចាស់បណ្តឹងអាជ្ញា ជាដំបូងព្រះរាជអាជ្ញាអាចទទួលបណ្តឹងដោយពាក្យប្តឹង ឬបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ជាទូទៅក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា ព្រះរាជអាជ្ញាតែងតែប្រកាន់ភ្ជាប់តួនាទីរបស់ខ្លួន ដើម្បីធានានូវសណ្តាប់ធ្នាប់សាធារណៈ ដោយមិនអាចព្រងើយកន្តើយបានឡើយ ចំពោះសំណុំរឿងទាំងឡាយណាដែលខ្លួនបានទទួល គឺត្រូវតែចាត់វិធានការលើសំណុំរឿង ដោយមិនត្រូវទុកចោលដោយឥតចាត់ការនោះទេ ជាមួយគ្នានេះដែរព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់គ្រប់រឿងហេតុដែលទទួលបាន និងអាចសម្រេចតម្កល់ទុកឥតចាត់ការលើសំណុំរឿងផងដែរ ប្រសិនបើព្រះរាជអាជ្ញាពិនិត្យ

-មាត្រា ៤៨ បានចែងស្តីពី " ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនេះមិនទាន់អាចជំនុំជម្រះបានភ្លាមៗបានទេនោះ សុំណុំរឿងនេះត្រូវលើកទៅសាវនាកានៅពេលក្រោយ ", ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[47]

ទៅមើលឃើញថាសំណុំរឿងនោះ មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីចោទប្រកាន់ទៅលើជនណាម្នាក់ ឬក៏អាចបណ្តាលមកពីមូលហេតុផ្សេងច្រើន។[48]

### ១ មូលហេតុការរលត់នៃបណ្តឹងអាជ្ញា

#### ១.១ មរណភាពនៃជនល្មើស

កាលណាជនល្មើសបានបាត់បង់ជីវិត មានន័យថាជននោះបានបាត់បង់អ្វីៗទាំងអស់ដោយលែងមានសិទ្ធ និងកាតព្វកិច្ចបន្តក្នុងសកម្មភាពគតិយុទ្ធណាមួយ ឬបង្កបទល្មើសក្នុងសង្គមទៀតឡើយ ដោយហេតុថារាល់បុគ្គលទាំងឡាយណាដែលបានបាត់បង់ជីវិតទៅ ហើយប្រធាននៃនីតិក៏លែងកើតមានទៀតដែរ។ ករណីរឿងព្រហ្មទណ្ឌ ទោះបីជាមានការកំណត់យ៉ាងជាក់លាក់ទៅលើការដាក់ទោសលើបុគ្គលណាម្នាក់ក៏ដោយ ប៉ុន្តែក៏នៅតែមានការលើកលែងទៅលើករណីដែលមិនសមស្របតាមលក្ខខណ្ឌច្បាប់ ដូចជាគេមិនអាចប្តឹងទៅនឹងសាកសពដែលបានស្លាប់ទៅហើយនោះឱ្យមកទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ដោយហេតុថាការប្តឹងនេះ វាមិនមែនជាផលចំណេញអ្វីដល់សង្គមនោះទេ ប្រសិនបើជនល្មើសបានបាត់បង់ជីវិតទៅហើយ នោះក៏មិនអាចមានជនណាម្នាក់មកទទួលទណ្ឌកម្មព្រហ្មទណ្ឌ ហើយក៏មិនអាចឱ្យជនណាម្នាក់មកទទួលខុសត្រូវជំនួសសពដែលបានប្រព្រឹត្តអំពើល្មសនោះបានឡើយ។[49] ដូចនេះ បណ្តឹងទាំងមូលក៏ត្រូវបានរលត់ទៅតាមមរណៈភាពរបស់ជនល្មើសផងដែរ ។

#### ១.២ ការផុតអាជ្ញាយុកាលនៃបទល្មើស

អាជ្ញាយុកាលនៃបទល្មើល សំដៅដល់អំឡុងពេលណាមួយដែលបានកំណត់ចំពោះប្រភេទនៃបទល្មើសដែលបានប្រព្រឹត្ត ដោយប្រភេទបទល្មើសនីមួយៗត្រូវបានកំណត់អាជ្ញាយុកាលខុសគ្នាទាំងអស់ ដោយករណីបទឧក្រិដ្ឋ មានអាជ្ញាយុកាល ១៥ឆ្នាំ ករណីបទមជ្ឈិមមានអាជ្ញាយុកាល៥ឆ្នាំ និងករណីបទលហុមានអាជ្ញាយុកាល ១ឆ្នាំ។ ផ្ទុយទៅវិញបទល្មើសមួយចំនួនពុំបានកំណត់នូវអាជ្ញាយុកាលនោះទេ ដោយហេតុថាបទល្មើសទាំងនោះ បានបង្ករជាព្យសនកម្មយ៉ាងធ្ងន់ធ្ងរទៅដល់សង្គម និងមនុស្សជាតិទាំងមូល ជាក់ស្តែងបទល្មើសដែលមិនត្រូវបានកំណត់នូវអាជ្ញាយុកាលមានដូចជា៖

- បទឧក្រិដ្ឋប្រល័យពូជសាសន៍[50]
- បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[51]

---

-មាត្រា៩១, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[48]

-មាត្រា២៤, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[49]

-មាត្រា១៨៣, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[50]

-មាត្រា១៨៨, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[51]

- និងបទឧក្រិដ្ឋសង្គ្រាម ។[52]

### ១.៣ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

និរាករណ៍ព្រហ្មទណ្ឌ ឬគោលការមិនប្រតិសកម្ម គឺជាគោលការណ៍មួយមិនអនុវត្តច្បាប់ថយក្រោយ ដោយបទបញ្ញត្តិថ្មីប្រានចោលនូវបញ្ញត្តិចាស់ នៅពេលដែលច្បាប់ថ្មីបានចូលជាធរមាន។ ចំពោះអត្ថន័យនេះគឺហាក់បីដូចជាមានការពាក់ព័ន្ធទៅនឹងគោលការណ៍និត្យានុគោលភាពផងដែរ ដោយគោលការណ៍នេះបានកំណត់យ៉ាងជាក់លាក់នូវអំពើណាមួយ ឬទោសព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្តដោយជនល្មើស ហើយជននោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើដែលខ្លួនបានធ្វើចំពោះមុខច្បាប់ ប្រសិនបើអំពើនោះ មិនមានកំណត់នៅក្នុងច្បាប់នោះទេ ការចោទប្រកាន់ទៅលើជននោះមិនអាចកើតឡើងបានឡើយ។ ចំពោះអនុភាពនៃបទបញ្ញត្តិថ្មីដែលលុបចោលបទល្មើសនេះ ក៏មានកំណត់ដាច់ខាតនៅក្នុងការហាមប្រាមមិនឱ្យមានការចោទប្រកាន់ផងដែរ។[53]

### ១.៤ អាជ្ញាអស់ជំនុំ

ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់បានទៀតនោះទេ ប្រសិនបើជននោះត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរទៅហើយនោះ ។[54]

## ២. មូលហេតុស្ថានភាពនៃអំពើ

### ២.១ អំពើដែលមិនអាចកំណត់បទល្មើស

ជាគោលការណ៍នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាចោទប្រកាន់ជនណាម្នាក់បាន លុះត្រាតែបានជននោះបានប្រព្រឹត្តិផ្ទុយពីច្បាប់។ ចំពោះ ការចោទប្រកាន់ជនណាមួយ ជាទូទៅព្រះរាជអាជ្ញាត្រូវពិនិត្យទៅលើធាតុផ្សំទាំង០៣(បី) មានដូចជា ធាតុនីត្យានុគោល[55] ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ដែលមាននៅក្នុងអង្គហេតុនៃបទល្មើស។[56] ប៉ុន្តែប្រសិនបើអំពើរបស់ជននោះ មិនមានចូលក្នុងធាតុផ្សំទាំងបីនោះទេ ព្រះរាជអាជ្ញានឹងមិនអាចធ្វើការចោទប្រកាន់ទៅលើជននោះបានទេ និងសំណុំរឿងអាចត្រូវបានសម្រេចតម្កល់ទុកដោយឥតចាត់ការ។

### ២.២ អំពើនៃបទល្មើសដែលបង្ករដោយសនកម្មតិចតួច

ជាទូទៅ ទោះបីជាក្នុងរឿងព្រហ្មទណ្ឌផ្តល់សិទ្ធឱ្យព្រះរាជអាជ្ញាជាអ្នកមានសិទ្ធចោទប្រកាន់យ៉ាងពេញទំហឹងទៅហើយក្តី ក៏មិនមែនមែនមានន័យថាព្រះរាជអាជ្ញាចេះតែចោទគ្រប់ទម្រង់នៃបទល្មើសដោយមិនគិត

-មាត្រា១៩៣, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[52]
-មាត្រា៩, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[53]
-មាត្រា១២, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[54]
-មាត្រា៣, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[55]
-មាត្រា៤, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[56]

មើលលើទំហំនៃព្យសនកម្មនោះទេ។ ករណីដែលព្រះរាជអាជ្ញាពិនិត្យទៅមើលឃើញថា រឿងក្តីនោះបង្ករជាព្យសនកម្មតិចតួច មិនបង្ករជាផលប៉ះពាល់ដល់សង្គមខ្លាំង នោះគាត់អាចតម្កល់មិនចាត់ទៅលើរឿងក្តីនោះបាន។ មួយវិញទៀតប្រសិនបើនៅបន្តការចោទប្រកាន់ទៅលើរឿងក្តី ដែលមានលក្ខណៈបង្ករជាព្យសនកម្មតិចតួច ក៏វាមិនមានផ្តល់ផលចំណេញដល់សង្គមជាតិនោះទេ គឺមានបង្ករអោយមានកាកកស្ទះនៅសំណុំរឿងដែលឥតប្រយោជន៍ទៅនោះទ ។

## ២.៣ អំពើដែលកំណត់ជាបទល្មើស តែមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌ

ជាការពិតណាស់ នៅក្នុងរឿងព្រហ្មទណ្ឌត្បិតថាជាច្បាប់មួយដ៏តឹងរឹងម៉ឺងម៉ាត់ មិនមានការលើកលែងបុគ្គលណាដែលប្រព្រឹត្តិខុសសូម្បីតែម្តង ហើយមានចែងយ៉ាងច្បាស់លាស់ សូម្បីតែការទទួលទោសជំនួសក៏មិនមានការអនុញ្ញាតផងដែរ។ ប៉ុន្តែទន្ទឹមនឹងភាពច្បាស់លាស់ដែលមានកំណត់នៅនូវក្នុងច្បាប់ ក៏យើងអាចសង្កេតមើលឃើញថា មានបទល្មើសមួយចំនួនផងដែរ ដោយពិនិត្យទៅឃើញមានធាតុផ្សំគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ ប៉ុន្តែបែរជាមានការលើកលែងទៅវិញ។ តើបទល្មើសទាំងនោះជាបទល្មើសបែបណាទើបមានលើកលែងទោសទៅលើជនដែលបានប្រព្រឹត្តផ្ទុយទៅនិងក្រមព្រហ្មទណ្ឌទៅវិញ ?

- **ហេតុផលដែលមិនចោទប្រកាន់**

- សមត្ថភាពយល់ដឹងនៃអំពើរបស់បុគ្គលដែលប្រព្រឹត្តចំពោះអនីតិជនក្រោមអាយុ១៨ឆ្នាំ ត្រង់ចំណុចនេះសំដៅទៅលើ រាល់អនីតិជនក្រោម១៨ឆ្នាំ គឺគេបានយល់ឃើញថាគាត់មិនមានសមត្ថភាពនៅក្នុងការដែលអាចយល់ដឹងបានជ្រៅជ្រះនោះទេ ដោយសារតែគាត់នៅក្មេងពេក នោះនាំឲ្យរាល់សកម្មភាពដែលគាត់បានប្រព្រឹត្តិគឺសុទ្ធសឹងតែជាអំពើដោយអចេតនា ដោយសារតែការមិនចេះគិតគូរបានវែងឆ្ងាយដូចនិងមនុស្សទូទៅដែលចូលដល់វ័យនីតិជន ចំពោះអនីតិជនយើងមិនអាចយកមកអនុវត្តចំពោះការទទួលខុសត្រូវ។
- អសម្ថភាពខាងការយល់ដឹង កាលបើជនណាម្នាក់ប្រព្រឹត្តល្មើសនោះពេលដែលជននោះ កើតវិបល្លាសស្មារតីដែលធ្វើអោយបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួនជននោះ និងមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[57]

## ២.៤.អំពើយុត្តិកម្ម

- **ការអនុញ្ញាតិដោយច្បាប់ ឬអជ្ញាធរ**

បុគ្គលណាដែល ប្រព្រឹត្តិអំពើដែលបានបញ្ញាតិ ឬអនុញ្ញាតិតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តិបទល្មើសទេ ឬប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។[58]

---

-មាត្រា៣១, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[57]

-មាត្រា៣២, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[58]

- **ការការពារស្របច្បាប់**

បុគ្គលណាដែលប្រព្រឹត្តបទល្មើសនៅក្នុងសភាពការពារស្របច្បាប់មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[59] ការការពារស្រមច្បាប់ត្រូវបានកំណត់ដូចលក្ខខណ្ឌខាងក្រោម៖

- បទល្មើស ត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ដើម្បីការពារខ្លួន ការពាអ្នកដទៃ ការពារទ្រព្យសម្បត្តិ ប្រឈមមុខនិងការឈានពានមួយ ដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើង ក្នុងពេលជាមួយគ្នា និងគ្មានសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និង ទម្ងន់នៃការឈ្លានពាន។

- **សច្ចាធារណ៍ នៃការការពារស្របច្បាប់**

បទល្មើសត្រូវបានប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយក្នុងពេលយប់ដោយហិង្សា រឺ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។ បទល្មើសដែលបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនិងការលួច រឺ ការប្លន់ ដែលអនុវត្តន៍ដោយហិង្សា។[60]

- **ស្ថានភាពចាំបាច់**

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើសពីទទួលខុសត្រូវព្រហ្មទេ។ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ការចាំបាច់ដើម្បីការពារខ្លួន អ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឆាំង និងគ្រោះថ្នាក់ដែលកំពុងកើតមានឡើង
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

- **អានុភាពកម្លាំង ឬការបង្ខំ**

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអនុភាពនៃកម្លាំងរឺការបង្ខំដែលបុគ្គលនោះមិនអាច ទប់ទល់បានបុគ្គលនេះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំងនៃការបង្ខំអាចចេញពីព្រឹត្តការណ៍ក្រៅឆន្ទៈរបស់មនុស្សប៉ុណ្ណោះ ។ កម្លាំងនិងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុខបាននិងមិនអាចជៀសវាងបាន។

---

-មាត្រា៣៣, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[59]

-មាត្រា៣៤, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[60]

# ជំពូកទី៣
# នីតិវិធីរឿងក្តីព្រហ្មទណ្ឌរបស់ស្ថាប័នអយ្យការ
# និងដំណើរការនៃការអនុវត្តទោស

ស្ថាប័នអយ្យការ មានតួនាទីចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ហើយ ធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួនក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ជាពិសេសព្រះរាជអាជ្ញាមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ មានន័យថាមិនចាំបាច់សុំការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួនឡើយ។ ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាក៏អាចចូលរួមគ្រប់កិច្ចស៊ើបសួរផងដែរ ទោះកិច្ចស៊ើបសួរជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរយ៉ាងណាក្តី ដោយហេតុថាតំណាងអយ្យការមានតួនាទីកំណត់នូវដែន ឬទំហំនៃការអនុវត្ត ដើម្បីឱ្យចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរបានតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។

ចំពោះនីតិវិធីជំនុំជម្រះ តំណាងអយ្យការត្រូវចូលរួមក្នុងសវនាការ ដើម្បីធ្វើការស្នើសុំឱ្យមានការអនុវត្តច្បាប់ ឬទោសតាមរយៈសេចក្តីសន្និដ្ឋានរបស់ខ្លួនចំពោះមុខយុត្តាធិការជំនុំជម្រះ ប៉ុន្តែអំណាចក្នុងការវិនិច្ឆ័យសម្រេចទោសផ្អែកតាមឆន្ទានុសិទ្ធិរបស់តុលាការ។ ចុងក្រោយស្ថាប័នអយ្យការជាអ្នកអនុវត្តសេចក្តីសម្រេចស្ថាពររបស់តុលាការជាអ្នកធានាដល់ការអនុវត្តទោសឲ្យបានជោគជ័យ។

## ផ្នែកទី១ កិច្ចនីតិវិធីស៊ើបអង្កេត

នៅក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត គោលការណ៍នៃភាពអាថ៌កំបាំងត្រូវបានយកមកអនុវត្ត មានន័យថា "**ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់**"[61] សំដៅដល់រាល់ព័ត៌មានដែលតំណាងអយ្យការទទួលបានពីការស៊ើបអង្កេតត្រូវតែថែរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ជាដាច់ខាតដោយជៀសវាងឱ្យបានរាល់ការផ្សព្វផ្សាយនូវព័ត៌មានទាំងនោះទៅដល់សាធារណៈ។ ប៉ុន្តែការគោរពនូវការរក្សាការសម្ងាត់ មិនមែនជាឧបសគ្គសម្រាប់តំណាងអយ្យការក្នុងការការពារខ្លួនប្រកាន់ចំពោះខ្លួនឡើយ។ នៅពេលមានការចោទប្រកាន់ការស៊ើបអង្កេតគឺជានីតិវិធីមួយដែលត្រូវបានដឹកនាំដោយតំណាងអយ្យការ។ ក្នុងដំណាក់កាលស៊ើបអង្កេត ជនល្មើសមានឈ្មោះត្រឹមជាជនសង្ស័យក្នុងការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ ដូចនេះតំណាងអយ្យការត្រូវស្វែងរកភស្តុតាងដាក់បន្ទុកឲ្យបានគ្រប់គ្រាន់តាមរយៈការស៊ើបអង្កេត ដើម្បីចោទប្រកាន់ទៅលើជនសង្ស័យ ហើយបញ្ជូនសំណុំរឿងទៅតុលាការ។ ការស៊ើបអង្កេតត្រូវបានចែកចេញជាពីរប្រភេទ គឺការស៊ើបអង្កេតករណីជាក់ស្តែង(**កថាខណ្ឌទី១**) និងការស៊ើបអង្កេតបឋម(**កថាខណ្ឌទី២**)។

---

[61] -មាត្រា៨៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## កថាខណ្ឌទី១ ការស៊ើបអង្កេតករណីជាក់ស្តែង

ការស៊ើបអង្កេតករណីជាក់ស្តែង ត្រូវបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីមាត្រា៨៥ ដល់ មាត្រា ១១០ ។[62] ការស៊ើបអង្កេតករណីជាក់ស្តែង អនុវត្តក្នុងគោលបំណងដើម្បីប្រមូលភស្តុតាងក្នុងស្ថានភាពបន្ទាន់ណាមួយ និងចំពោះបទល្មើសដែលទើបប្រព្រឹត្តរួច និងប្រព្រឹត្តរួចបន្តិចមក។ ការស៊ើបអង្កេតនេះអាចត្រូវបានយកទៅអនុវត្តចំពោះករណីបទមជ្ឈិម និងបទឧក្រដ្ឋ(ជាក់ស្តែង) ។

- **ករណីបទឧក្រិដ្ឋ**

យោងតាមមាត្រា៤៦ នៃក្រមព្រហ្មទណ្ឌ បានកំណត់និយមន័យថាបទឧក្រិដ្ឋ គឺជាបទល្មើសដែលមានអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥ឆ្នាំ និងក្រោម ឬស្មើនឹង៣០ឆ្នាំ និងទោសដាក់ ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ មាត្រានេះបញ្ជាក់ឱ្យឃើញថាបទឧក្រិដ្ឋ គឺជាបទល្មើសដែលមានស្ថានភាពធ្ងន់ធ្ងរមានផលប៉ះពាល់ខ្លាំងដល់សង្គម និងមានរយៈពេលវែងក្នុងការដកហូតសិទ្ធិសេរីភាពរបស់បុគ្គល ដូច្នេះតម្រូវឱ្យត្រូវពិនិត្យឱ្យបានល្អិតល្អន់បំផុតមុននឹងធ្វើការសម្រេចអំពីទោស ដោយហេតុថាស្ថានភាពធ្ងន់ធ្ងរដែលកើតឡើងពីបទល្មើសនោះ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិជាកាតព្វកិច្ចជាចាំបាច់ថា ក្នុងករណីបទល្មើសជាបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរជាដាច់ខាត។

- **ករណីបទមជ្ឈិម(ជាក់ស្តែង)**

ចំណែកឯ បទមជ្ឈិមវិញមិនមែនជាល័ក្ខខ័ណ្ឌចាំបាច់ ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែប្តឹងសុំចោទប្រកាន់ឱ្យបើកការស៊ើបសួរឡើយ។ ព្រះរាជអាជ្ញាមានជម្រើសផ្សេងៗដូចជាប្រើនីតិវីធីប្តឹងសុំទៅយុត្តាធិកាជំនុំជម្រះដោយបញ្ជូនជនសង្ស័យទៅជំនុំជម្រះតែម្តង ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ ។

ករណីដែលបទមជ្ឈិមតម្រូវឱ្យបើកការស៊ើបសួរ គឺលុះត្រាតែភស្តុតាងដែលប្រមូលបាន នោះពុំទាន់គ្រប់គ្រាន់ដើម្បីប្តឹងទៅយុត្តាធិការជំនុំជម្រះបាន ហើយភស្តុតាងដែលខ្វះខាតមិនអាចប្រមូលបានដោយការស៊ើបអង្កេតបឋម ប៉ុន្តែអាចប្រមូលបានក្នុងករណីដែលត្រូវប្រើអំណាចដោយបង្ខំ ក្នុងស្ថានភាពជាក់ស្តែងណាមួយដែលជាបទល្មើសមានលក្ខណៈស្មុគស្មាញ ដែលតម្រូវអោយមានការស្រាវជ្រាវយូរ និងមានការលំបាកក្នុងការស្រាវជ្រាវ។

ហេតុដូច្នេះហើយ ទើបការស៊ើបអង្កេតករណីជាក់ស្តែងត្រូវបង្កើតឡើង និងជាវិធានផ្លូវច្បាប់ និងមានអំណាចទូលំទូលាយសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស្វែងរកជនល្មើស និងប្រមូលភស្តុតាងឲ្យបានឆាប់

-មាត្រា៨៤ និងមាត្រា១១០, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[62]

រហ័ស។ លើសពីនេះការស៊ើបអង្កេតបទល្មើសជាក់ស្តែងក៏អាចត្រូវអនុវត្តដើម្បីធានាឱ្យមានការការពារ បង្ការ និងស្តារឡើងវិញឱ្យបានឆាប់រហ័សនូវការខូចខាតនូវសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ អាយុជីវិតមនុស្ស និងទ្រព្យសម្បត្តិដែលបានបាត់បងឱ្យត្រលប់មកវិញ ឬបង្កឡើងដោយជនល្មើស។ លើសពីនេះកងកម្លាំងនគរបាលយុត្តិធម៌ត្រូវធ្វើការឱ្យលឿនបំផុត តាមដែលអាចធ្វើបាន និងប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុតដើម្បីធានាដល់ការប្រមូលភស្តុតាង។

## ១. លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតករណីជាក់ស្តែង

### ១.១ ដែនអនុវត្ត

ការស៊ើបអង្កេតករណីជាក់ស្តែងត្រូវបើកក្នុងករណីមានបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ( មាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

បទល្មើសជាក់ស្តែងជាបទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ចាត់ទុកជាបទល្មើសជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យ ត្រូវបានសាធារណជន ស្រែកដេញប្រជាប់ចាប់ប្រភីង ឬបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ( មាត្រា ៨៦) ។

មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាត់ទុកដូចជាបទល្មើសជាក់ស្តែងដែរ បើទោះបីជាស្ថិតនៅក្នុងករណីដែលមានចែងនៅមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។

ការស៊ើបអង្កេតករណីជាក់ស្តែង មិនមែនអាចអនុវត្តបានដោយសារអំណាចនៃការស៊ើបអង្កេតជាក់ស្តែងឡើយ ប៉ុន្តែដោយសារមានតែការកើតឡើងនូវស្ថានភាពជាក់ស្តែងណាមួយ ដែលអនុញ្ញាតឱ្យនគរបាលយុត្តិធម៌ ឬតំណាងអយ្យការអាចប្រើប្រាស់អំណាចស៊ើបអង្កេតជាក់ស្តែង។ ដូចនេះ ការស៊ើបអង្កេតករណីជាក់ស្តែងនេះ គឺកើតឡើងតាមរយៈស្ថានភាពជាក់ស្តែងមួយដែលបានកើតឡើងទើបបណ្តាលឱ្យមានការបើកការស៊ើបអង្កេតករណីជាក់ស្តែងនេះ។

ក្នុងករណីបទលហុ ច្បាប់ពុំបានកំណត់ឱ្យបានច្បាស់លាស់អំពីការស៊ើបអង្កេតករណីជាក់ស្តែងដែលត្រូវយកមកអនុវត្ត ជាមួយគ្នានេះដែរការស៊ើបអង្កេតនេះ ត្រូវបានកំណត់ដាក់ឱ្យអនុវត្តតែក្នុងករណីបទឧក្រិដ្ឋ និងបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ។[63]

### ១.២ ស្ថានភាពជាក់ស្តែង

ស្ថានភាពជាក់ស្តែង សំដៅដល់សកម្មភាពដែលកំពុងតែប្រព្រឹត្ត និងបានប្រព្រឹត្តរួចភ្លាម។ ស្ថានភាពជាក់ស្តែងមួយកើតឡើងបាន លុះត្រាតែស្ថានភាពនោះវាស្តែងឡើងមានលក្ខណៈសត្យានុម័ត ទើបមានអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចក្នុងការស្ថានភាពជាក់ស្តែងនោះបាន និងអាចធ្វើការស៊ើបអង្កេតក្នុងករណីជាក់ស្តែងស្របតាមច្បាប់។

ក្នុងស្ថានភាពមួយចំនួន អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការបើកការស៊ើបអង្កេតបឋមមុនសិន ដើម្បីអាចឈានទៅកំណត់ស្ថានភាពជាក់ស្តែង និងបន្ទាប់មកទើបធ្វើការបើកការស៊ើបអង្កេតជាក់ស្តែងក៏បាន។ ការស៊ើបអង្កេតបទល្មើសជាក់ស្តែងមិនអាចអនុវត្តលើសពី ៧ ថ្ងៃ នោះទេគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។[64] ប្រសិនបើក្រោយការបើកការស៊ើបអង្កេតជាក់ស្តែងហើយ នៅតែពុំអាចស្វែងរកពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ពីតំណាងអយ្យការ ដោយតំណាងអយ្យការអាចសម្រេចបិទការធ្វើស៊ើបអង្កេត ឬបើកការស៊ើបអង្កេតបឋមវិញក៏បាន។

ជាក់ស្តែង ការស៊ើបអង្កេតបឋមត្រូវបានយកមកអនុវត្តជាមុនសិន បន្ទាប់ពីរកឃើញកន្លែងដែលសង្ស័យហើយ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតជាក់ស្តែងវិញ ដើម្បីធានាដល់ការប្រមូលភស្តុតាងនៅកន្លែងកើតហេតុ ទោះបីជាពេលចូលទៅដល់កន្លែងកើតហេតុភស្តុតាងត្រូវបានកំទេចចោលអស់ក៏ដោយ។ ក្នុងករណីនេះ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌នៅតែអាចបើកការស៊ើបអង្កេតបឋមជាថ្មីម្តងទៀត ដើម្បីស្វែងរកប្រមូលភស្តុតាងទាំងនោះឱ្យបាន។

ក្រៅពីស្ថានភាពខាងលើនេះ ការបើកការស៊ើបអង្កេតជាក់ស្តែងក៏ប្រព្រឹត្តទៅបានដែរ ដោយយោងតាមក្រមនីតិវិធីបានចែងថា "**គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។**"[65] ក្នុងស្ថានភាពនេះ អាជ្ញាធរមានសមត្ថកិច្ចក៏អាចបើកការស៊ើបអង្កេតជាក់ស្តែង ដើម្បីឈានទៅប្រមូលភស្តុតាងសម្រាប់បង្ហាញពីអត្ថិភាពនៃបទល្មើសទោះបីជា

---

-មាត្រា៨៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[63]

-មាត្រា៨៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[64]

-មាត្រា៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[65]

បទល្មើសជាអញ្ញាតជនក៏ដោយ។ មន្ត្រីនគរបាលយុត្តិធម៌អាចបំពេញភារកិច្ចត្រឹមសិទ្ធិអំណាចដែលច្បាប់ប្រគល់ឱ្យប៉ុណ្ណោះ ហើយភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចមានសិទ្ធិអំណាច ដូចមន្ត្រីនគរបាលយុត្តិធម៌ឡើយ។

### ២. ការចុះទៅកន្លែងកើតហេតុ

ការចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ក្រោយពីរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ គឺអ្នកធានារ៉ាប់រងរក្សាទុកតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ហើយមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការហាមឃាត់គ្រប់បុគ្គលកុំឱ្យទៅណាឆ្ងាយពីកន្លែងកើតហេតុរហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។[66]

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងពិនិត្យ កត់ត្រា និងកំណត់អង្គហេតុនៃបទល្មើសឱ្យបានច្បាស់លាស់ ដែលជាប្រយោជន៍សម្រាប់ដល់ការប្រមូលយកភស្តុតាងឲ្យលឿនបំផុតតាមដែលអាចធ្វើបាន។[67] មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន[68] បើពុំដូច្នេះទេ នីតិវិធីត្រូវមោឃភាព។[69] ព្រះរាជអាជ្ញាអាចចុះទៅកន្លែងកើតហេតុតាមការយល់ឃើញរបស់ខ្លួនបាន និងក្នុងករណីបទល្មើសធ្ងន់ធ្ងរតែប៉ុណ្ណោះ ដើម្បីដឹកនាំនីតិវិធីដោយផ្ទាល់។ ព្រះរាជអាជ្ញា គឺជាអ្នកដឹកនាំ និងសម្របសម្រួលមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតលើវិសាលភាពទាំងមូលលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចត្រូវបានអនុញ្ញាតដោយផ្ទាល់ដោយព្រះរាជអាជ្ញាក្នុងករណីចាំបាច់ និងបន្ទាន់។

### ៣. ការឆែកឆេរ និងការប្រមូលភស្តុតាង

ការឆែកឆេរ សំដៅដល់ការរុករកតម្រុយភស្តុតាងក្នុងកន្លែងបិទជិត ដើម្បីកំណត់អំពីអត្ថិភាពនៃបទល្មើស ឬចង្អុលបង្ហាញជនល្មើស។ ការឆែកឆេរ គឺជាវិធានការបង្ខំមួយដ៏សំខាន់ដើម្បីចាប់យកភស្តុតាងក្នុងការស៊ើបអង្កេតប៉ុន្តែការឆែកឆេរក៏ហាក់បីដូចជាវិធានដែលត្រូវប្រុងប្រយ័ត្នផងដែរ ព្រោះការរំលោភបំពានសិទ្ធិលំនៅឋានរបស់អ្នកដទៃអាចកើតមាន ប្រសិនជាការឆែកឆេរនោះធ្វើខុសនឹងនីតិវិធី ដែលកំណត់ដោយច្បាប់។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន តាមមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយទទួលនូវការអនុញ្ញាតពីព្រះរាជអាជ្ញា (ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់) ។

---

-មាត្រា៨៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[66]

-មាត្រា៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[67]

-មាត្រា៩០, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[68]

-មាត្រា១០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[69]

ការឆែកឆេរត្រូវប្រព្រឹត្តទៅនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។

ការឆែកឆេរមិនអាចផ្តើមធ្វើមុនម៉ោង ៦ព្រឹក ក្រោយម៉ោង ១៨ ឡើយ លើកលែងតែករណីដែលមានចែងនៅមាត្រា ៩១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺ :

-ករណីដែលបទល្មើសជាក់ស្តែង ។

–ករណីដែលមានសម្រែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង ។

–ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន។

-ករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ។

ក្នុងករណីដែលការឆែកឆេរត្រូវធ្វើនៅក្នុងការិយាល័យមេធាវី មន្ត្រីនគរបាលយុត្តិធម៌ពុំអាចធ្វើការឆែកឆេរបានឡើយ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរប៉ុណ្ណោះដែលអាចឆែកឆេរបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។ ចំពោះអាគារសារព័ត៌មានវិញ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន តែត្រូវធ្វើនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វ ផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ (មាត្រា ៩១ កថាខណ្ឌ ទី៤ និងទី ៥) ។ ការឆែកឆេរអាចអនុវត្តបាន ដោយមន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះដែលមិនមែន ជាភ្នាក់ងារនគរបាលយុត្តិធម៌ហើយការឆែកឆេរនោះត្រូវទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុនសិន។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា "**ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិតតាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា**"។[70] និង "**ការឆែកឆេរលំនៅឋាន សម្ភារៈ វត្ថុ និង លើរូបបុគ្គល ត្រូវធ្វើស្របនឹងបញ្ញត្តិច្បាប់**"។[71] លើសពីនេះ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ ដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញតាមរយៈមាត្រា៣១ ក៏បានកំណត់ដែរថា "**គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋានសំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ**"។[72] ហើយជនគ្រប់រូបមាន សិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀត

-មាត្រា៤០, រដ្ឋធម្មនុញ ឆ្នាំ១៩៩៣[70]

-មាត្រា៤០, រដ្ឋធម្មនុញ ឆ្នាំ១៩៩៣ [71]

-មាត្រា១៧, កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦[72]

ជ្រែក ឬការប៉ះពាល់បែបនេះ។[73] ចំពោះការរំលោភបំពានសិទ្ធិលំនៅឋានក៏ត្រូវបានការពារដោយច្បាប់ព្រហ្មទណ្ឌកម្ពុជាដែរ ដោយក្រមព្រហ្មទណ្ឌបានកំណត់ថា "**អំពើប្រព្រឹត្តទៅដោយមានហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឧបាយកលចូលទៅក្នុងលំនៅឋានអ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ ឆ្នាំ [...]**។"[74] ដូចនេះ សិទ្ធិលំនៅឋានត្រូវបានធានាយ៉ាងរឹតរឹង ដែលជាហេតុធ្វើឱ្យការឆែកឆេរត្រូវអនុវត្តយ៉ាងរឹតរឹងផងដែរ ដើម្បីជៀសវាងការរំលោភបំពានដោយប្រការណាមួយ។

### ៤. ការស្តាប់ចម្លើយ

ការស្តាប់ចម្លើយ គឺជានីតិវិធីមួយដែលត្រូវអនុវត្ត ដើម្បីឈានដល់ការទទួលព័ត៌មានទាក់ទងនឹងរឿងហេតុតាមរយៈការកោះហៅឱ្យចូលបង្ហាញខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបាន។ ក្នុងន័យនេះ ជនសង្ស័យក៏អាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្តាប់ចម្លើយបានដែរ។ ប្រសិនបើ មានការរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន។ បញ្ជាឱ្យចូលខ្លួន (**ដីកាបញ្ជាឱ្យចូលខ្លួន**) អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួនបាន ។

ក្រៅពីការស្តាប់ចម្លើយបុគ្គលដែលអាចផ្តល់ព័ត៌មាន មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួនតែម្តងដើម្បីធ្វើការស្តាប់ចម្លើយចំពោះគ្រប់បុគ្គលណាដែល ស្ថិតនៅក្នុងការសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស។ ការស្តាប់ចម្លើយនេះ គឺត្រូវមានការធ្វើកំណត់ហេតុមួយ ដោយដកស្រង់នូវសេចក្តីរាយការណ៍របស់បុគ្គលផ្តល់ចម្លើយនោះ។ បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានឱ្យខ្លាំងៗ ឬឱ្យបុគ្គលផ្តល់ចម្លើយនោះអានដោយខ្លួនឯងនូវខ្លឹមសារនៃកំណត់ហេតុ ដើម្បីឱ្យបុគ្គលផ្តល់ចម្លើយធ្វើការចុះហត្ថលេខា ឬផ្តិតម្រាមដៃលើគ្រប់ទំព័រនៃកំណត់ហេតុ អ្នកបកប្រែអាចត្រូវបានហៅ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអានកំណត់ហេតុ។ ទោះជាយ៉ាងណាក៏ដោយបុគ្គលផ្តល់ចម្លើយ នោះក៏នៅមានសិទ្ធិក្នុងការមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃ ហើយក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុអំពីបញ្ហានេះ។[75] សូមបញ្ជាក់បន្ថែមផងថា ក្នុងនីតិវិធីនៃការស្តាប់ចម្លើយនេះ អ្នកបកប្រែដែលអញ្ជើញដោយ មន្ត្រីនគរបាលយុត្តិធម៌ មិនមែនជាបុគ្គលជ្រើសរើសចេញពីនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលទាក់ទិននឹងរឿងហេតុឡើយ។[76] ចំពោះអ្នកបកប្រែនោះត្រូវស្បថថា និយាយពាក្យពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន។

---

-មាត្រា១៧, កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦[73]

-មាត្រា២៩៩, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[74]

-មាត្រា៩៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[75]

-មាត្រា៩៣ និងមាត្រា១៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[76]

## ៥. ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ជានីតិវិធីមួយដូចការធ្វើកោសលវិច្ឆ័យដែលធ្វើឡើងដោយអ្នកជំនាញដែលមានចែងក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។ បញ្ជីនេះត្រូវរៀបចំឡើង ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ អ្នកជំនាញទាំងនោះ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹង ស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។ [77] ប៉ុន្តែជាក់ស្តែង បញ្ជីនេះមិនទាន់បានបង្កើតនៅឡើយទេនាពេលបច្ចុប្បន្ន។

ជាការអនុវត្តជាក់ស្តែង ការពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ឬការធ្វើកោសលវិច្ឆ័យត្រូវបានធ្វើដោយអ្នកជំនាញដែលមិនទាន់ចុះបញ្ជី តាមការពឹងពីមន្ត្រីនគរបាលយុត្តិធម៌។ អ្នកជំនាញដែលមិនទាន់ចុះបញ្ជីទាំងនោះ ត្រូវធ្វើសម្បថ តាមសាសនា ឬជំនឿរបស់ខ្លួននឹងជួយ ដោយភក្តីភាពដល់តុលាការ។[78]

ក្នុងចំណុចនេះអាចបញ្ជាក់បានថា ច្បាប់ព្រហ្មទណ្ឌមិនជឿជាក់ទៅលើការធ្វើសម្បថអ្វីនោះឡើយ ព្រោះខ្លួនជាអ្នកកំណត់ឲ្យមានការពិនិត្យតាមបែបវិទ្យាសាស្ត្រ ដើម្បីបង្ហាញរឿងហេតុពិតប្រាកដ។ ប៉ុន្តែការកំណត់ឲ្យអ្នកដទៃធ្វើសម្បថ ឬកំណត់ឲ្យសាក្សីធ្វើសម្បថ គឺគ្រាន់តែជាការបន្លាច ឬបំភ័យផ្នែក សតិអារម្មណ៍តែប៉ុណ្ណោះ។

## ៦. ការឃាត់ខ្លួន

### ៦.១ អំណាចក្នុងការឃាត់ខ្លួន

ការឃាត់ខ្លួន សំដៅដល់វិធានមួយដែលបង្ខិតបង្ខំក្នុងការដកហូតសេរីភាពបុគ្គលណាមួយដោយផ្អែកទៅលើមូលដ្ឋានច្បាប់ណាមួយ។ ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់និងការពារនូវសិទ្ធិសេរីភាពនេះ ដោយបានបញ្ញត្តិថា "**ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ ខ្លួន ឬការឃុំខ្លួនណាមួយអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមច្បាប់។ ដូចគ្នាផងដែរ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានកំណត់ថាគ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួនឃុំខ្លួន ឬនិរទេសខ្លួនដោយបំពានឡើយ**"[79]។ ហើយកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏បានចែងដែរថា "**ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវ ចាប់ខ្លួន ឬឃុំខ្លួន តាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់**"[80]។ ជាពិសេសក្រមព្រហ្មទណ្ឌបានបញ្ញត្តិថា "**បុគ្គលដែលចាប់ ដែលឃុំ**

---

-មាត្រា១៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[77]

-មាត្រា៩៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[78]

-មាត្រា៣៨, រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣[79]

-មាត្រា៩, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦[80]

**ឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាតត្រូវផ្តន្ទាទោស[...]"។**[81]

ដូចនេះ ការឃាត់ខ្លួនបុគ្គលណាមួយត្រូវអនុវត្តដោយបំពេញនូវលក្ខខណ្ឌទាំងឡាយដែលច្បាប់បានបញ្ញត្តិ បើពុំដូច្នេះទេ សិទ្ធិជាមូលដ្ឋាននៃបុគ្គលដែលត្រូវបានគេឃាត់ខ្លួននឹងត្រូវបានបំពាន ព្រោះគ្រប់បុគ្គលត្រូវមានសេរីភាពក្នុងការធ្វើដំណើរទៅវិញទៅមក។

ក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត មាត្រា ៨៧)។

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស និងបុគ្គលដែលគេអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុ។ ក្នុងករណីខាងក្រោយនេះ ការឃាត់ខ្លួនអាចធ្វើទៅបានលុះត្រាតែបុគ្គលនោះប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា (មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នៅពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

រយៈពេលនៃការឃាត់ខ្លួនគឺ ៤៨ ម៉ោង គិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល កងរាជអាវុធហត្ថ។ ការពន្យារពេលនៃការឃាត់ខ្លួនចំនួន ២៤ ម៉ោងទៀតអាចធ្វើទៅបានលុះត្រាតែមានលក្ខខណ្ឌដូចតទៅៈ

-មានតម្រុយបង្ហាញឲ្យឃើញថាមានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួនជានីតិជន ក្នុងបទល្មើសបទឧក្រិដ្ឋ។

-ការពន្យារពេលជាវិធានការចំបាច់ ដើម្បីឲ្យស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។

-ការអនុញ្ញាតដោយព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

ចំពោះការឃាត់ខ្លួនអនីតិជនអាចធ្វើបានចំពោះតែអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងប៉ុណ្ណោះ។ រយៈពេលនៃការឃាត់ខ្លួន ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសៈ

**-ចំពោះបទល្មើសឧក្រិដ្ឋ**

-អនីតិជនដែលមានអាយុពី១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនហួសពី ៣៦ ម៉ោង។

-អនីតិជនដែលមានអាយុពី១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនហួសពី ៤៨ ម៉ោង។

**-ចំពោះបទល្មើសមជ្ឈិម**

-អនីតិជនដែលមានអាយុពី១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនហួសពី ២៤ ម៉ោង។

- មាត្រា២៥៩, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[81]

-អនីតិជនដែលមានអាយុពី១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនហួសពី ៣៦ ម៉ោង។

ក្នុងរយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនសិទ្ធិសុំសន្ទនាជាមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឲ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ។ ទំនាក់ទំនងអាចធ្វើបាន ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមក។ ការសន្ទនាមានរយៈពេល ៣០ នាទី (មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រៅពីនេះ ការទទួលជំនួយពីគ្រូពេទ្យក្នុងរយៈពេលឃាត់ខ្លួន ក៏អាចធ្វើបានដែរ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌។

ដូចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវអំណាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការឃាត់ខ្លួនក្នុងលក្ខខណ្ឌជាកំហិតមួយ ហើយការឃាត់ខ្លួននេះត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា។[82] មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនគ្រប់បុគ្គលដែលសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ ការឃាត់ខ្លួននេះគឺ "**ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត**"[83] គឺដើម្បីធានាឱ្យបាននូវការចាប់ខ្លួនជនល្មើសជាដើម។ ក្រៅពីសិទ្ធិអំណាចក្នុងការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនគ្រប់បុគ្គលដែលអាចផ្តល់ជាព័ត៌មានអំពីរឿងហេតុសម្រាប់ការបំភ្លឺការពិតផងដែរ តែការឃាត់ខ្លួននេះអាចអនុវត្ត លុះត្រាតែបានបំពេញនូវក្នុងលក្ខខណ្ឌចំនួន ២ គឺ៖

ទី១ បុគ្គលនោះមិនព្រមផ្តល់ព័ត៌មាន និង

ទី២ មន្ត្រីនគរបាលយុត្តិធម៌ទទួលបានការអនុញ្ញាតយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។[84]

### ៦.២ កំណត់ហេតុនៃការឃាត់ខ្លួន

ចំពោះកំណត់នៃការឃាតខ្លួនមន្ត្រីនគរបាលយុត្តិធម៌ត្រូវផ្តល់ព័ត៌មានភ្លាមៗទៅព្រះរាជអាជ្ញា និងត្រូវបញ្ជូនជនសង្ស័យព្រមទាំងភស្តុតាងដែលជាហេតុនាំឲ្យមានការឃាត់ខ្លួន។ ដើម្បីធានាដល់ការឃាត់ខ្លួន នោះក្រៅពីនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតាក់តែងនូវកំណត់ហេតុមួយទៅតាមលក្ខខណ្ឌមួយចំនួន ដែលបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌដែលមានដូចជា៖[85]

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន

-មាត្រា៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[82]
-មាត្រា៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[83]
-មាត្រា៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[84]
-មាត្រា១០៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[85]

- អត្តសញ្ញាណ និងអាយុនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃខែឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិរកជំនួយពីមេធាវី
- ឈ្មោះអ្នកបកប្រែ ។

បុគ្គលដែលឃាត់ខ្លួនត្រូវអានកំណត់ហេតុនេះ ឬមន្ត្រីនគរបាលយុត្តិធម៌អានឲ្យស្តាប់ បើបុគ្គលដែលឃាត់ខ្លួនមិនចេះអក្សរ ដើម្បីឲ្យបុគ្គលដែលឃាត់ខ្លួននោះចុះហត្ថលេខា ឬផ្តិតម្រាមដៃ តែបើក្នុងករណីគាត់បដិសេធអំពីការចុះហត្ថលេខាឬផ្តិតម្រាមមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសអំពីការបដិសេធនេះ។

ក្នុងករណីមានការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុនូវរបបបទនៃការផ្តល់ព័ត៌មានទៅព្រះរាជអាជ្ញា និងបែបបទនៃការផ្តល់ដំណឹងទៅឪពុកម្តាយ អ្នកតំណាងស្របច្បាប់ និងបុគ្គលដែលទទួលបន្ទុកអនីតិជន។ ក្រៅពីនេះរាល់កិច្ចដែលបានកើតឡើង ក្នុងអំឡុងពេលនៃការឃាត់ខ្លួនត្រូវតែចុះក្នុងកំណត់ហេតុទាំងអស់ ដូចជាអំឡុងពេលឃាត់ខ្លួន ការពិនិត្យរបស់គ្រូពេទ្យការជួបជាមួយមេធាវីឬបុគ្គលណាមួយ ការពន្យាពេលនិងឈ្មោះតំណាង អយ្យការដែលអនុញ្ញាតការពន្យារពេលនេះ រយៈពេលសម្រាកពេលស្តាប់ចម្លើយ និងហេតុការណ៍ផ្សេងៗជាដើម។

## ៦.៣ សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន

នៅក្នុងអំឡុងពេលនៃការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនអាចទទួលបាននូវជំនួយពីមេធាវី និងគ្រូពេទ្យ។ នៅក្នុងករណីការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់ ដោយប្រាប់ពីមូលហេតុនៃការឃាត់ខ្លួនទៅបុគ្គលដែលត្រូវឃាត់ខ្លួននោះ។ ក្នុងការជូនដំណឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ពីសិទ្ធិរកជំនួយពីមេធាវីក្នុងអំឡុងពេលនៃការឃាត់ខ្លួន។ បើមានការចាំបាច់ណាមួយ នោះមន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែបាន។ សិទ្ធិក្នុងការជួបជាមួយមេធាវី អាចអនុវត្តបានក្រោយពីការឃាត់ខ្លួនបានរយៈពេល ២៤ ម៉ោង។ ការធ្វើដូចនេះដើម្បីអាចឲ្យមន្ត្រីនគរបាល យុត្តិធម៌ធ្វើការរបស់ខ្លួនជាមុនសិនក្នុងការស្តាប់ចម្លើយរបស់បុគ្គលដែលឃាត់ខ្លួន។ ក្រោយពីរយៈពេលនេះ បុគ្គលដែលឃាត់ខ្លួនអាចសន្ទនាជាមួយមេធាវី ឬបុគ្គលណាមួយតាមការជ្រើសរើសរបស់ខ្លួនលើកលែងតែបុគ្គលដែលជាប់ទាក់ទិននឹងរឿងក្តី ព្រោះដើម្បីជៀសវាងនូវការរួមគំនិតបង្កផលលំបាកក្នុងកិច្ចស៊ើបអង្កេត។ ការសន្ទនានេះ អាចធ្វើបានតែរយៈពេល ៣០ នាទី ដោយគោរពលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ។

ការទទួលបាននូវជំនួយពីគ្រូពេទ្យអាចត្រូវបានធ្វើឡើងតាមរយៈ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌បានគ្រប់ពេលវេលា។ កម្មវត្ថុនៃការទទួលបានជំនួយនេះគឺដើម្បីផ្ទៀងផ្ទាត់ពីស្ថានភាពសុខភាពនៃបុគ្គលឃាត់

ខ្លួនសមស្របនឹងការឃាត់ខ្លួន[86] គ្រូពេទ្យត្រូវចេញវិញ្ញាបនបត្របញ្ជាក់សុខភាពដើម្បីភ្ជាប់ក្នុងសំណុំរឿង ហើយឈ្មោះគ្រូពេទ្យ ថ្ងៃ ខែ ឆ្នាំនិង ម៉ោងនៃការពិនិត្យសុខភាពត្រូវចុះនិទ្ទេស។ លើសពីនេះដើម្បីធានានៃការឃាត់ខ្លួនឲ្យមានប្រសទ្ធភាព ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងនៃការឃាត់ខ្លួន ដើម្បីផ្ទៀងផ្ទាត់ពីលក្ខខណ្ឌនៃការឃាត់ខ្លួននេះផងដែរ។

## ៧. ការស្តាប់ការសន្ទនាតាមប្រព័ន្ធបច្ចេកវិទ្យា

ការស្តាប់ការសន្ទនាជាលក្ខណៈឯកជនរបស់អ្នកដទៃដោយឯកឯង ហាក់ដូចជាស្តែងនូវរូបភាពនៃការរំលោភបំពានជ្រៀតជ្រែកទៅក្នុងជីវិតឯកជនរបស់អ្នកដទៃ ។ ការស្តាប់ការសន្ទនានេះ ត្រូវបានទទួលការគាំពារការពារពីច្បាប់។ យោងតាមរដ្ឋធម្មនុញ្ញបានកំណត់ថា "**ការរក្សាសិទ្ធិ [....] តាមទូរស័ព្ទត្រូវបានធានា។**"[87] ដូចគ្នានេះដែរ យោងតាមកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏បានទទួលស្គាល់ផងដែរនូវការការពារការរំលោភបំពានតាមរយៈស្តាប់ការសន្ទនា តាមទូរស័ព្ទនេះដែរ "**គ្មានជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន។**"[88] យោងតាមក្រមព្រហ្មទណ្ឌបានកំណត់ថា "**អំពើប្រព្រឹត្តដោយគំនិតទុច្ចរិតស្តាប់ ឬធ្វើឲ្យប្រែប្រួកប្រែបល់ការសន្ទនាតាមទូរស័ព្ទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ ១ឆ្នាំ [...] ។**"[89]

មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឲ្យស្តាប់ និងថតសំលេងការសន្ទនាតាមទូរស័ព្ទឡើយ ហើយក៏គ្មានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លង ដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍សារតាមទូរសារ ឬសារតាមអិនធើណែត។[90] ដូចនេះការស្តាប់ការសន្ទនារបស់អ្នកដទៃត្រូវបានកម្រិតការពារយ៉ាងរឹតរ៉ឹងដោយច្បាប់ព្រហ្មទណ្ឌ។ ការស្តាប់ការសន្ទនានេះ គឺមានតែអាជ្ញាធរដែលច្បាប់បានប្រគល់សិទ្ធិអំណាចឱ្យនោះទេ ទើបមានសិទ្ធិស្តាប់បាន ហើយការស្តាប់ទាំងនោះត្រូវអនុវត្តក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ផងដែរ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យមន្ត្រីនគរបាលយុត្តិធម៌អាចថត និងស្តាប់ការឆ្លើយឆ្លងគ្នាតាមគ្រប់មធ្យោបាយទូរគមនាគមន៍។[91] នេះជាការធ្វើនិយតកម្ម នៃការស្តាប់ការសន្ទនាដោយច្បាប់ព្រហ្មទណ្ឌ ដើម្បីធានាដល់ការស្វែងរកការពិតរបស់ចៅក្រម ក្នុងនាមជាអំណាចតុលាការដែលជាអំណាចឯករាជ្យខុសពីស្ថាប័នដែលត្រូវគោរពនូវគោលការណ៍ឋានានុក្រម។

---

-មាត្រា៩៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[86]

-មាត្រា៤០, រដ្ឋធម្មនុញ ឆ្នាំ១៩៩៣[87]

-មាត្រា១៧, កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦[88]

-មាត្រា៣១៨, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[89]

-មាត្រា១០៥, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[90]

-មាត្រា១៧២, ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[91]

ជាក់ស្ដែងការស្ដាប់ទូរស័ព្ទជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ (មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ), ការតាមដាន (មាត្រា ៨៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន) និងការតាមដាន (មាត្រា ៨៨ នៃច្បាប់ស្ដីពីការប្រឆាំងនឹងភេរវកម្ម) ជាដើម។

**កថាខណ្ឌទី២ ការស៊ើបអង្កេតបឋម**

ការស៊ើបអង្កេតបឋមអាចដំណើរការបានដោយការផ្ដួចផ្ដើមរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬតាមការសុំរបស់ព្រះរាជអាជ្ញា ក្នុងករណីដែលមានបទឧក្រិដ្ឋ មជ្ឈិម ឬបទលហុ។ ការស៊ើបអង្កេតបឋមដំណើរការ នៅក្នុងករណីដែលបទឧក្រិដ្ឋ ឬមជ្ឈិម មិនជាក់ស្ដែង ឬក៏ក្នុងករណីដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្ដែងបានកន្លងផុត ។ ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្ដែងតែ ៧ ថ្ងៃ ប៉ុណ្ណោះ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ប្រសិនបើនៅតែមិនអាចកំណត់នូវអត្តិភាពនៃបទល្មើសបាន នោះមន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំព្រះរាជអាជ្ញាឱ្យបើកការស៊ើបអង្កេតបឋមបាន។

អំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋមមានលក្ខណៈ ប្រហាក់ប្រហែល និងអំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្ដែង ដោយគ្រាន់តែបទបញ្ញត្តិយោងមានភាពខុសគ្នា។ វិធានទាក់ទិននឹងការស៊ើបអង្កេតបឋមមានចែងចាប់ ពីមាត្រា ១១១ ដល់មាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំណុចដែលខុសប្លែកគ្នាខ្លាំងគឺ ទាក់ទិននឹងអំណាចនៃការឆែកឆេរ ដែលមានចែងនៅមាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**១. ការឆែកឆេរ**

ការឆែកឆេរ និងចាប់យកវត្ថុតាងអាចអនុវត្តបានក្នុងការស៊ើបអង្កេតបឋមចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម។[92] សូមបញ្ជាក់ផងថា ការឆែកឆេរក្នុងការស៊ើបអង្កេតបឋមមានគោលដៅចាប់យក តែវត្ថុតាងដែលមានដូចជាគ្រាប់កាំភ្លើង ឬកាំបិត ជាដើម។ ដោយហេតុថាការឆែរឆេរក្នុងការស៊ើបអង្កេតបឋមមិនបានប្រព្រឹត្តទៅក្រោយរយៈពេលកើតហេតុថ្មីៗទេ។ ក្នុងករណីនេះ ភស្តុតាងដែល មានដូចជា ស្លាកស្នាម ឬឈាម ដែលបន្សល់ទុកនៅកន្លែងកើតហេតុអាចនឹងត្រូវបាត់បង់ដោយ ប្រការណាមួយ។ ផ្ទុយទៅវិញ ការឆែកឆេរក្នុងការស៊ើបអង្កេតករណីជាក់ស្ដែងមានគោលដៅ ប្រមូលយកភស្តុតាងទាំងអស់រួមទាំងការចាប់យកវត្ថុតាង ព្រោះការឆែរឆេរនេះត្រូវអនុវត្តភ្លាមៗ ក្រោយការប្រព្រឹត្តបទល្មើស។

ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរបានប៉ុន្តែត្រូវមាន៖

-មាត្រា១១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[92]

-ការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ជាលាយលក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ប៉ុន្តែប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ ត្រូវសរសេរពីការយល់ព្រមរបស់អ្នកកាន់កាប់ទីកន្លែង និងការដែលជននេះពុំចេះសសេរអក្សរ ។

-ដីកាអនុញ្ញាតឱ្យឆែកឆេរ ពីប្រធានសាលាដំបូង តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ប្រសិនបើអ្នកដែលកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ហើយមិនអាចផ្តើមមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ឡើយ ។

ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ពុំបានអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ហើយមានការបំពានទៅលើសិទ្ធិបុគ្គល មន្ត្រីនគរបាលអាចត្រូវផ្តន្ទាទោសពីបទ រំលោភលើលំនៅឋាន តាមមាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬក្នុងឱកាស។

ចំពោះព្រមច្បាស់លាស់ ត្រូវសរសេរដោយផ្ទាល់ដៃដោយ អ្នកកាន់កាប់ទីកន្លែងនោះ ដោយពុំអាចឲ្យបុគ្គលណាមួយសរសេរជំនួសបានឡើយ។ ក្នុងករណី អ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុថា "**អ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរហើយយល់ព្រមឲ្យឆែកឆេរ។**"[93] ដូចនេះ ការឆែកឆេរក្នុងករណីការស៊ើបអង្កេតបឋម ពុំសូវផ្តល់អំណាចបង្ខិតបង្ខំដល់មន្ត្រីនគរបាលយុត្តិធម៌ ដូចការឆែកឆេរក្នុងករណីការស៊ើបអង្កេតជាក់ស្តែងឡើយ។

ផ្ទុយទៅវិញ បើសិនជាមានការបដិសេធ ឬមិនយល់ព្រមឲ្យឆែកឆេរពីអ្នកកាន់កាប់ទីកន្លែង ឬអវត្តមាននៃអ្នកកាន់កាប់ទីកន្លែងនោះ " **ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីអាចចេញដីកាអនុញ្ញាតឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា។**"[94] ដីកានេះជាប្រភេទដីកាសម្រេចដែលតម្រូវឱ្យមានសំអាងហេតុ និងសំអាងច្បាប់ជាលាយលក្ខណ៍អក្សរ ទោះបីជាមិនមានសរសេរក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ។ ក្រោយការសុំរបស់ព្រះរាជអាជ្ញា នោះព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ ហើយការឆែកឆេរនេះត្រូវប្រព្រឹត្តទៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ដែលចាត់ដោយព្រះរាជអាជ្ញាចំពោះការឆែកឆេរអំឡុងពេលអវត្តមានអ្នកកាន់កាប់ទីកន្លែង។ សាក្សីទាំងនោះមិនអាចជ្រើសរើសចេញពីនគរបាល ឬកងរាជអាវុធហត្ថ ដែលចូលរួមក្នុងការឆែកឆេរឡើយ។

-មាត្រា១១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[93]

-មាត្រា១១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[94]

លើសពីនេះ ការឆែកឆេរក្នុងករណីស៊ើបអង្កេតបឋមនេះ មិនអាចប្រព្រឹត្ត ទៅមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាច ឡើយ។ និងការបិទស្លាកបោះត្រាលើវត្ថុតាងក្នុងមាត្រា ៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាងក្នុងការស៊ើបអង្កេតបឋមដែរ។[95]

### ២. ការបញ្ជាឱ្យចូលខ្លួន

ការបញ្ជាឱ្យចូលខ្លួនអាចត្រូវបានអនុវត្តចំពោះបុគ្គលគ្រប់រូប ដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុតាមរយៈការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌អាចស្តាប់ចម្លើយបុគ្គលទាំងនោះ និងធ្វើកំណត់ហេតុរាល់ការស្តាប់ចម្លើយ។ ចំពោះអ្នកបកប្រែអាចត្រូវបានហៅដោយមន្ត្រីនគរបាលយុត្តិធម៌ បើមានការចាំបាច់ និងអ្នកបកប្រែមិនអាចជ្រើសចេញពីនគរបាល ឬកងរាជអាវុធហត្ថបានឡើយ។

គ្រប់បុគ្គលដែលបានទទួលការកោះហៅ ត្រូវតែចូលមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹង ព្រះរាជអាជ្ញាអាចចេញបញ្ជាតាមការជូនដំណឹងរបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយការបញ្ជានេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា និងបោះត្រាព្រះរាជអាជ្ញា ដើម្បីបញ្ជាក់អំពីឆន្ទៈក្នុងការអនុញ្ញាត។ ដូចនេះការបញ្ជាឲ្យចូលខ្លួនលើកនេះ អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំឲ្យមានការបង្ហាញខ្លួនបុគ្គលដែលបានកោះហៅនោះ។

## ផ្នែកទី២ ការចូលរួមក្នុងកិច្ចស៊ើបសួររបស់តំណាងអយ្យការ

កិច្ចស៊ើបសួរ គឺជានីតិវិធី ឬវិធានមួយដែលស្ថិតក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ការស៊ើបសួរគឺតម្រូវឱ្យមានការចូលរួមពីតំណាងអយ្យការចំពោះកិច្ចនីតិវិធីមួយចំនួន ហើយកិច្ចស៊ើបសួរត្រូវធ្វើឡើងក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ និងស្មុគស្មាញប៉ុណ្ណោះ ដូចជាករណីបទឧក្រិដ្ឋ ដោយក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថាត្រូវតែធ្វើការស៊ើបសួរជាដាច់ខាត។ ចំពោះបទលហុ ឬបទមជ្ឈិម ពុំតម្រូវឱ្យមានការស៊ើបសួរជាលក្ខណៈដាច់ខាតដូចបទឧក្រិដ្ឋឡើយ។

គោលការណ៍នៃភាពអាថ៌កំបាំង ក៏ត្រូវបានយកមកអនុវត្តក្នុងកិច្ចស៊ើបសួរដូចការស៊ើបអង្កេតផងដែរ។ ដូចនេះ រាល់ព័ត៌មានដែលចៅក្រមទទួលបាន ចៅក្រមត្រូវតែថែរក្សាការសម្ងាត់នៃវិជ្ជាជីវៈជាដាច់ខាត ដោយជៀសវាងឱ្យបានរាល់ការផ្សព្វផ្សាយនូវព័ត៌មានទាំងនោះទៅដល់សាធារណៈ។ ប៉ុន្តែការគោរពនូវការរក្សាការសម្ងាត់ មិនមែនជាឧបសគ្គក្នុងការការពារខ្លួននៅពេលមានការចោទប្រកាន់ណាមួយឡើយ។[96]

-មាត្រា១១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[95]

-មាត្រា១២១, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[96]

ដូចនេះ ការធានានូវសន្តិសុខ និងការទទួលបាននូវប្រសិទ្ធភាពនៃការស៊ើបសួរព្រមទាំងសេចក្តីថ្លៃថ្នូរការអនុវត្តវិជ្ជាជីវៈប្រកបដោយគុណភាព និងការទទួលខុសត្រូវខ្ពស់ ចៅក្រមស៊ើបសួរត្រូវតែរក្សាឱ្យបានដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈនៃការស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួរដែលបានស្រាវជ្រាវ។

**កថាខណ្ឌទី១ ការបើកការស៊ើបសួរ**

ការបើកការស៊ើបសួរអាចត្រូវបានធ្វើតាម ២ របៀបគឺ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

**១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ គឺជានីតិវិធីធម្មតាមួយនៃការបើកការស៊ើបសួរ។ ចៅក្រមស៊ើបសួរជាអ្នកស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ដើម្បីស្វែងរកយុត្តិធម៌ពិតប្រាកដក្នុងនាមជាអំណាចវិនិច្ឆ័យ ដែលខុសគ្នាពីព្រះរាជអាជ្ញាដែលជាអ្នកតំណាងឱ្យផលប្រយោជន៍សមូហភាព។ ដូចនេះចៅក្រមស៊ើបសួរត្រូវតែអព្យាក្រឹតឯករាជ្យ ក្នុងតួនាទីភារកិច្ចរបស់ខ្លួនក្នុងការស្វែងរកភស្តុតាងទាំងឡាយណាដែលពាក់ព័ន្ធនឹងបទល្មើស ដើម្បីជាប្រយោជន៍បង្ហាញការពិត ។

ជាគោលការណ៍ ចៅក្រមស៊ើបសួរមិនអាចបើកការស៊ើបសួរណាមួយដោយគ្មានដីកាបញ្ជូនរឿងឱ្យស៊ើបសួរពីតំណាងអយ្យការឡើយ។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចស៊ើបសួរត្រឹមតែអង្គហេតុដែលបានចង្អុលបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដែលបានចង្អុលបង្ហាញក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ឬអាចប្រឆាំងចំពោះជនដែលមិនស្គាល់អត្តសញ្ញាណដែលជាអញ្ញាតជន។ ក្នុងករណីមានការលេចឡើងនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅកាន់តំណាងអយ្យការដើម្បីពិនិត្យសិក្សា និងផ្តើមធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ចំពោះការស៊ើបសួរលើអង្គហេតុថ្មីនេះ ពុំអាចប្រព្រឹត្តទៅបានឡើយ ប្រសិនជាគ្មានដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ប្រសិនបើជាអង្គហេតុថ្មីនោះ គ្រាន់តែជាស្ថានទម្ងន់ទោសនៃអង្គហេតុ ដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីមុននោះ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរតាមផ្លូវច្បាប់ដោយពុំចាំបាច់ជូនដំណឹងទៅតំណាងអយ្យការឡើយ ។

**២. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ការស៊ើបសួរដែលបើកតាមរយៈជនរងគ្រោះគឺជានីតិវិធីថ្មីមួយ ដែលក្រមនីតិវិធីយើងបានបញ្ជូនហើយមានហេតុផលមួយចំនួនថាមូលហេតុអ្វី បានជាជនរងគ្រោះត្រូវបានផ្តល់សិទ្ធិដើម្បីបើកការស៊ើបសួរបានផងដែរ។ ការបើកការស៊ើបសួរដោយជនរងគ្រោះនេះ មានតែផ្លូវមួយប៉ុណ្ណោះ គឺការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ករណីជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយហេតុថាជនរងគ្រោះគឺ

ជាអ្នកទទួលរងនូវព្យសនកម្មដោយផ្ទាល់ពីបទល្មើស។ កាលណាបទល្មើសមួយកើតឡើង បុគ្គលឯកជនគឺជាអ្នកទទួលរងព្យសនកម្មដោយផ្ទាល់ហើយសង្គមក៏ជាជនរងគ្រោះប្រយោលដែរ។ ដូចនេះហើយ ទើបសង្គមជាអ្នកដើរតួនាទីសំខាន់ក្នុងការធ្វើបណ្តឹងអាជ្ញា តែពេលខ្លះជនរងគ្រោះ មិនពេញចិត្តនឹងការអនុវត្តណាមួយ ហេតុនេះក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់សិទ្ធិឲ្យគាត់អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឱ្យបណ្តឹងអាជ្ញាមានចលនា។

ដូចនេះ ជនរងគ្រោះអាចធ្វើបណ្តឹងបានពីរប្រភេទ គឺបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងអាជ្ញា ហើយយើងសង្កេតឃើញថាការធ្វើបណ្តឹងរដ្ឋប្បវេណីតែងតែលេចឡើង ប៉ុន្តែក្នុងករណីពិសេសបណ្តឹងអាជ្ញាក៏ត្រូវកើតឡើងជាមួយគ្នាផងដែរ ដោយហេតុថានេះជាយន្តការថ្មីរបស់ក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីផ្សេងទៀត កាលណាជនរងគ្រោះអាចដាក់ពាក្យប្តឹងទៅស្ថាប័នអយ្យការ ហើយតំណាងអយ្យការថ្លឹងថ្លែងពាក្យបណ្តឹង និងយល់ឃើញថាមានហេតុផល និងភស្តុតាងគ្រប់គ្រាន់ ឬគ្មាននោះទេ តំណាងអយ្យការនឹងធ្វើការចោទប្រកាន់ ឬសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះរឿងហេតុ។ ជនរងគ្រោះអាចប្តឹងតវ៉ាចំពោះសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ ខែចាប់ពីពេលដែលខ្លួនបានទទួលការជូនដំណឹងពីការសម្រេចតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាមានតួនាទីត្រូវជូនដំណឹងនេះក្នុងរយៈ ពេលដ៏ខ្លីបំផុត និងយ៉ាងយូរ២ខែ ចាប់តាំងពីថ្ងៃសម្រេច។ ជាគោលការណ៍សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាមិនមានអាជ្ញាអស់ជំនុំទេ មានន័យថានៅពេលព្រះរាជអាជ្ញាសម្រេចហើយ ក៏នៅតែអាចយករឿងនោះមកសើរើ និងកែប្រែនៅថ្ងៃក្រោយក៏បាន ប្រសិនបើបណ្តឹងអាជ្ញា មិនទាន់ផុតរលត់។

ដូចបានបញ្ជាក់ពីខាងលើក្នុង គោលការណ៍ឋានានុក្រម គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិបញ្ញាជាលាយលក្ខណ៍អក្សរបញ្ជាឱ្យព្រះរាជអាជ្ញាសើរើរឿងក្តីមកចោទប្រកាន់វិញបាន។ ប៉ុន្តែនៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទទួលបានពាក្យប្តឹង អគ្គព្រះរាជអាជ្ញាយល់ស្របនឹងពាក្យប្តឹងរបស់ជនរងគ្រោះ ដោយធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាចោទប្រកាន់ ក៏ប៉ុន្តែអគ្គព្រះរាជអាជ្ញាក៏អាចយល់ស្របនឹងព្រះរាជអាជ្ញានឹងអាចតម្កល់ដីតម្កល់រឿងទុកឥតចាត់ការទុកជាបានការផងដែរ។ ដូចនេះក្នុងករណីដែលអគ្គព្រះរាជអាជ្ញាយល់ស្របនឹងព្រះរាជអាជ្ញា ជនរងគ្រោះនៅមានផ្លូវមួយទៀត គឺការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់ឲ្យបណ្តឹងអាជ្ញាអាចដំណើរការបាន។

នៅពេលដែលចៅក្រមស៊ើបសួរទទួលបានបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាត់ត្រូវបញ្ជូនសំណុំរឿងនោះទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ និងផ្តល់យោបល ប្រសិនជាព្រះរាជអាជ្ញាយល់ឃើញថាមានទំនាក់ទំនងហេតុផល និងភស្តុតាងគ្រប់គ្រាន់ ឬគ្មាននោះ ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាសន្និដ្ឋាន

បញ្ជូនរឿងឲ្យស៊ើបសួរ ហើយប្រសិនបើព្រះរាជអាជ្ញាមិនឯកភាព ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំមកចៅក្រមស៊ើបសួរដើម្បីកុំឱ្យស៊ើបសួរបាន។ ដូចនេះ ចៅក្រមស៊ើបសួរមានជម្រើសក្នុងការសម្រេចមិនបើកការស៊ើបសួរ ឬបើកការស៊ើបសួរ តាមបណ្តឹងជនរងគ្រោះដោយហេតុថាចៅក្រមស៊ើបសួរមានឯករាជ្យ ដោយមិនស្ថិតនៅក្រោមការបញ្ជា ឬនាយឋានានុក្រមរបស់ព្រះរាជអាជ្ញាទេ។ ក្នុងករណីនេះ ការស៊ើបសួរត្រូវបានចាប់ផ្តើម ប្រសិនបើចៅក្រមស៊ើបសួរសម្រេចបើកការស៊ើបសួរ។ ប៉ុន្តែដើម្បីជាការការពារផលប្រយោជន៍មួយចំនួនដល់បុគ្គលដែលពាក់ព័ន្ធក្នុងសំណុំរឿង និងជៀសវាងការធ្វើបណ្តឹងដោយមានការរំលោភបំពាន ចៅក្រមស៊ើបសួរអាចតម្រូវឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុកក្នុងចំនួនណាមួយ តាមការកំណត់របស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរក៏អាចលើកលែងការបង់ប្រាក់តម្កល់ទុកបានដែរ ប្រសិនជាចៅក្រមស៊ើបសួរពិនិត្យឃើញថាជនរងគ្រោះពុំមានលទ្ធភាព។

ការបង់ប្រាក់តម្កល់ទុក គឺមានអត្ថប្រយោជន៍របស់វាក្នុងកិច្ចស៊ើបសួរនេះ ព្រោះនៅពេលដែលចៅក្រមស៊ើបសួរទទួលបណ្តឹងហើយ ប្រសិនបើចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ និងសម្រេចបិទការស៊ើបសួរវិញហើយនៅតែមិនឃើញវត្តមាននៃបទល្មើសកើតឡើង ដូចបណ្តឹងរបស់ជនរងគ្រោះនោះ ការធ្វើបណ្តឹងនោះ គឺធ្វើឡើងដោយបំពានដែលធ្វើឲ្យប៉ះពាល់ដល់អ្នកដទៃ។ ដើម្បីធានាការពារកុំឱ្យមានការធ្វើបណ្តឹងតាមចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចឱ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណីដែលមានតម្លៃមិនលើសពីទឹកប្រាក់តម្កល់ទុកនោះ ។

ការសម្រេចឱ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណី គឺជាទណ្ឌកម្មពិន័យស៊ីវិល។ ចំណែកឯបុគ្គលដែលមានឈ្មោះនៅក្នុងសំណុំរឿងដែលត្រូវគេប្តឹងទទួលរងការប៉ះពាល់ដល់កិត្តិយសមានសិទ្ធិប្តឹងបកដើម្បីទាមទារសំណងជម្ងឺចិត្តវិញបាន។ ចំពោះជនរងគ្រោះត្រូវតែធ្វើការថ្លឹងថ្លែង និងពិចារណាឱ្យច្បាស់លាស់មុននឹងធ្វើការដាក់ពាក្យប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវមានការជឿជាក់ថាបទល្មើសពិតជាបានកើតឡើងមែន ហើយបើមានភស្តុតាងមកធ្វើជាសក្ខីភាពទៀតកាន់តែល្អ។

**កថាខណ្ឌទី២ ការស្នើសុំឱ្យបំពេញកិច្ច**

ការស្នើសុំបំពេញកិច្ច អាចត្រូវបានធ្វើគ្រប់ពេលវេលា តាមរយៈការស្នើសុំរបស់ព្រះរាជអាជ្ញាដែលយល់ឃើញថាការបំពេញកិច្ចនោះមានប្រយោជន៍ ។ ចំណែកឯជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីវិញក៏អាចស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយ និងស្តាប់ចម្លើយខ្លួន ឬសាក្សីព្រមទាំងអាចសុំសួរតទល់ ឬចុះដល់ទីកន្លែងកើតហេតុ ហើយពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ ។

ប្រសិនបើការស្នើសុំនេះមិនត្រូវបានយល់ព្រមដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរត្រូវចេញសេចក្តីសម្រេចបដិសេធចំពោះពាក្យសុំនេះ នៅក្នុងរយៈពេល ១៥ ថ្ងៃចំពោះព្រះរាជអាជ្ញា និងរយៈពេល ១ ខែ ចំពោះ

ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីបានទទួលពាក្យសុំ។ សេចក្តីសម្រេចបដិសេធរបស់ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុត្រឹមត្រូវតាមច្បាប់។

បន្ទាប់មកចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួន ទៅអ្នកប្តឹងសុំដែលមានព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ប្រសិនបើអ្នកមានសិទ្ធិប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ ពួកគាត់អាចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចសម្រេចជំនួសចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរក្នុងរយៈពេល ១៥ ថ្ងៃបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ ថ្ងៃ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណអាចធ្វើបណ្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរក្នុងរយៈពេល ១ ខែ បើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល១ ខែ។

### ១. ការស្រាវជ្រាវក្នុងកិច្ចស៊ើបសួរ

ចៅក្រមស៊ើបសួរ គឺជាអ្នកទទួលបន្ទុកក្នុងការស៊ើបសួរដោយសេរី និងឯករាជ្យ។ ការស៊ើបសួរ គឺស្ថិតនៅក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវសិទ្ធិមួយចំនួនឲ្យព្រះរាជាអាជ្ញាក្នុងចូលរួមកិច្ចស៊ើបសួរដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរផងដែរដូចជា ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងការធ្វើកោសលវិច័យជាដើម។ ជាក់ស្តែងបង្ហាញឱ្យឃើញពីការសហប្រតិបត្តិការរវាងចៅក្រមស៊ើបសួរ និងព្រះរាជាអាជ្ញាផងដែរ។

យោងតាមមាត្រា ១៤៦ និងមាត្រា ១៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការសួរចម្លើយជនត្រូវចោទត្រូវអនុវត្តតាមការពិភាក្សាដេញដោលនៅក្នុងបន្ទប់មួយ ដែលដឹកនាំដោយចៅក្រមស៊ើបសួរ។ នៅក្នុងការពិភាក្សាដេញដោលនេះ ព្រះរាជអាជ្ញាអាចលើកជាសំណួរបាន ប្រសិនជាបានទទួលការអនុញ្ញាតពីចៅក្រមស៊ើបសួរដែលជាអ្នកដឹកនាំការពិភាក្សាដេញដោលនោះ។ ក្នុងករណីដែលមានការមិនអនុញ្ញាតឲ្យលើកជាសំណួររបស់ព្រះរាជាអាជ្ញាដោយចៅក្រមស៊ើបសួរ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសអំពីចំណុចនេះនៅក្នុងកំណត់ហេតុសួរចម្លើយ។ ដូចគ្នានេះដែរ ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដូចការរៀបរាប់ខាងលើនេះដែរ ។

ក្រៅពីការសួរចម្លើយ និងការស្តាប់ចម្លើយខាងលើ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំធ្វើកោសលវិច័យអំពីបញ្ហាបច្ចេកទេសដែលចោទឡើង។ ចៅក្រមស៊ើបសួរអាចធ្វើការបដិសេធនូវពាក្យសុំនោះ ដោយដីកាមានសំអាងហេតុក្នុងរយៈពេល ៥ថ្ងៃ។ ប្រសិនមានការយល់ព្រមពីការធ្វើកោសលវិច្ឆ័យចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា។ កាលណារបាយការណ៍នៃការធ្វើកោសលវិច័យត្រូវបានធ្វើរួចហើយ និងព្រះរាជអាជ្ញាត្រូវដាក់របាយការណ៍នោះ ក្នុងសំណុំរឿង និងបញ្ជូនទៅចៅក្រមស៊ើបសួរវិញ។

## ២. ការចូលរួមក្នុងវិធានការនិរន្តរាយ

### ២.១ ការបង្គាប់ឱ្យចាប់ខ្លួន

ជាគោលការណ៍ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ដើម្បីបង្ខិតបង្ខំឱ្យជនត្រូវចោទមានវត្តមានចំពោះមុខតុលាការ។[97] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាលិខិតបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល ឬឃុំខ្លួនបុគ្គលនោះ។[98]

ដីកាបង្គាប់ឱ្យចាប់ខ្លួននេះ អាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពក្នុងការប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ដោយព្រះរាជអាជ្ញា។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបានលុះត្រាតែ៖[99]

១.បទល្មើសដែលចោទប្រកាន់នោះជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

២.បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងជាស្ថិតនៅកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ជាលក្ខខណ្ឌច្បាប់ មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួនចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងអំពីការចាប់ខ្លួននេះទៅព្រះរាជអាជ្ញាជាមុនសិន ដើម្បីឱ្យព្រះរាជអាជ្ញាពិនិត្យ និងផ្តល់យោបល់។ ក្រោយពីទទួលបានដំណឹងនៃការចាប់ខ្លួន ព្រះរាជអាជ្ញាត្រូវពិនិត្យ និងផ្តល់យោបល់តាមការយល់ ឃើញរបស់ខ្លួន ហើយចៅក្រមត្រូវពិនិត្យ និងពិចារណាលើយោបល់របស់ព្រះរាជអាជ្ញា។ ចំពោះយោបល់របស់ព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួននោះឡើយ ហើយចៅក្រមស៊ើបសួរនៅតែអាចសម្រេចចាប់ខ្លួនជនត្រូវចោទបានដដែល ទោះបីជាព្រះរាជអាជ្ញាមានយោបល់ជំទាស់ទៅនឹងការចាប់ខ្លួនជនត្រូវចោទនោះក៏ដោយ ដោយហេតុថាយោបល់ទាំងនោះ មានតម្លៃត្រឹមតែជាមូលវិចារណ៍ប៉ុណ្ណោះ សម្រាប់ចៅក្រមស៊ើបសួរធ្វើការពិចារណាតាមផ្លូវច្បាប់តែប៉ុណ្ណោះ។ ដូចនេះចៅក្រមស៊ើបសួរ នៅតែអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនតាមការយល់ឃើញរបស់ខ្លួន។ ការសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវធ្វើឡើងដោយផ្អែកទៅលើភាពចាំបាច់ និងប្រយោជន៍ដល់នីតិវិធីនៃការស៊ើបសួរដោយមានបញ្ជាក់ឲ្យច្បាស់លាស់ពីមូលហេតុនៃការចាប់ខ្លួន។

---

-មាត្រា១៩៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[97]

-មាត្រា១៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[98]

-មាត្រា១៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[99]

ក្នុងករណីចាប់ខ្លួនជនត្រូវចោទបានសម្រេចជនត្រូវចោទត្រូវបានបញ្ជូនទៅបង្ហាញមុខ ចំពោះចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើកិច្ចនីតិវិធីស្ថិតនៅដំណាក់កាលស៊ើបសួរ ការចាប់ខ្លួនកើតឡើងព្រះរាជអាជ្ញានៃកន្លែងចាប់ខ្លួនជនត្រូវចោទនោះនឹងធ្វើការស្តាប់ចម្លើយ និងកំណត់ហេតុស្តីពីការស្តាប់ចម្លើយដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន បើសិនមានការឃុំខ្លួនថិរវេលានៃការឃុំខ្លួននេះនឹងត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។[100] ជាតួយ៉ាង ការចាប់ខ្លួនជនត្រូវចោទនៅតាមបណ្តាខេត្តឆ្ងាយៗ ហើយមានឧបសគ្គមួយចំនួនដែលនាំឱ្យមានការពន្យារពេលនៃការបញ្ជូនខ្លួននោះព្រះរាជអាជ្ញានៅតាមបណ្តាខេត្តនោះអាចធ្វើការស្តាប់ចម្លើយ និងធ្វើកំណត់ហេតុហើយថិរវេលានៃការពន្យារពេលត្រូវបានកំណត់ក្នុងសំណុំរឿងដែលបញ្ជូនទៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន។

### ២.២ ការឃុំខ្លួនជាបណ្តោះអាសន្ន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នដើម្បីឃុំខ្លួនជនត្រូវចោទ។ ប៉ុន្តែជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។[101] គោលការណ៍នេះ ជាគោលការណ៍ចម្បងដែលបានបញ្ញត្តិដើម្បីធានាការលើកស្ទួយសិទ្ធិបុគ្គល នៅក្នុងទម្រង់នៃការអនុវត្តប្រព័ន្ធគតិយុត្តិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាច្បាប់កំណត់ក្នុងការឃុំខ្លួនតែប៉ុណ្ណោះ។

#### ២.២.១ ការសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានធ្វើឡើងតាមគំនិតផ្តើមរបស់ចៅក្រមស៊ើបសួរផ្ទាល់ ឬតាមរយៈសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ នេះមានន័យថា ព្រះរាជអាជ្ញាអាចសរសេរសេចក្តីសន្និដ្ឋានអំពីការឃុំខ្លួនក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចឃុំខ្លួន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីដីកាបង្គាប់ឱ្យឃុំខ្លួននេះទៅព្រះរាជអាជ្ញា អំពីការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានតែក្នុងករណីមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់បានកំណត់ដាក់ទោសពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ ប៉ុណ្ណោះ។[102]

ការឃុំខ្លួនបណ្តោះអាសន្នត្រូវមានលក្ខខណ្ឌដូចតទៅ៖[103]

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតឡើងជាថ្មី។

-មាត្រា២០២, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[100]
-មាត្រា២០៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[101]
-មាត្រា២០៤, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[102]
-មាត្រា២០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[103]

- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

### ២.២.២ ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការស្នើសុំឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន។[104] ពេលសំណុំរឿងត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរបន្ទាប់ពីការស៊ើបអង្កេត ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំឲ្យមានការឃុំខ្លួនបណ្តោះអាសន្នតាមសេចក្តីសន្និដ្ឋានរបស់ខ្លួន ប្រសិនជាព្រះរាជអាជ្ញាយល់ឃើញថា លក្ខខណ្ឌនៃការឃុំខ្លួនត្រូវបានបំពេញ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចមិនឃុំខ្លួន តាមរយៈការចេញដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នដោយមិនចាំបាច់មានសំអាងហេតុទេ ហើយដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវចេញក្នុងរយៈពេល ៥ ថ្ងៃ[105]។ ក្នុងករណីចៅក្រមស៊ើបសួរសម្រេច មិនឃុំខ្លួនបណ្តោះអាសន្ននេះត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញា។ ប្រសិនជាក្នុងរយៈពេល៥ថ្ងៃ ហើយចៅក្រមស៊ើបសួរ នៅតែមិនបានសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននេះ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ២.២.៣ ការដោះលែងឱ្យនៅក្រៅឃុំ

ការដោះលែងឱ្យនៅក្រៅឃុំអាចអនុវត្តបាន ប្រសិនបើការដោះលែងនោះមិនប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ ការដោះលែងឱ្យនៅក្រៅឃុំត្រូវយកទៅអនុវត្តក្នុងកិច្ចស៊ើបសួរ ចំពោះករណីបទល្មើសដែលត្រូវបានចោទប្រកាន់ ហើយត្រូវរកឃើញតែគ្មានតម្រុយសោះទៅលើជនល្មើស ចំពោះករណីព្យសនកម្មដែលកើតចេញពីបទល្មើសមានទំហំតិចតួច ឬក៏ការប្រមូលភស្តុតាងមិនគ្រប់គ្រាន់ និងលក្ខខណ្ឌផ្សេងទៀតដែលច្បាប់កំណត់។

ជាគោលការណ៍ ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំបណ្តោះអាសន្នមិនមែនមានន័យថា ការដោះលែងជនត្រូវចោទនោះឱ្យរួចខ្លួនពីការជំនុំជម្រះឡើយ តែជាការដោះលែងបណ្តោះអាសន្នប៉ុណ្ណោះ មិនមែនជាការដោះលែងស្ថាពរឡើយ។ ដូចនេះ ជនត្រូវចោទនេះមានកាតព្វកិច្ចមកបង្ហាញខ្លួនចំពោះមុខតុលាការទៅតាមការកោះហៅរបស់តុលាការ ។

-មាត្រា២០៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[104]

-មាត្រា២០៧, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[105]

ការដោះលែងឲ្យនៅក្រៅឃុំអាចត្រូវបានធ្វើឡើងតាមៈ

- ការបង្គាប់របស់ចៅក្រមស៊ើបសួរ
- បណ្ដឹងរបស់ព្រះរាជអាជ្ញា
- បណ្ដឹងរបស់ជនត្រូវចោទ។

ការដោះលែងឲ្យនៅក្រៅឃុំ តាមការបង្គាប់របស់ចៅក្រមស៊ើបសួរអាចធ្វើបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់ពីព្រះរាជអាជ្ញា ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ និងពិនិត្យក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥ ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ប៉ុន្តែចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់ពីមូលហេតុនៃការបន្ទាន់នេះ ។

- ព្រះរាជអាជ្ញាអាចធ្វើបណ្ដឹងសុំឲ្យមានការដោះលែងឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា។ ក្នុងករណីនេះ ចៅក្រមត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ បើក្នុងរយៈពេលនោះចៅក្រមមិនបានសម្រេចទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់ពីសំអាងហេតុសម្រាប់ការមិនដោះលែង។
- ជនត្រូវចោទអាចដាក់បណ្ដឹងសុំឲ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។

ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវបញ្ជូននូវពាក្យសុំនោះភ្លាមទៅតំណាងអយ្យការ ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅតំណាងអយ្យការពិនិត្យ និងផ្ដល់យោបល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតជូនចៅក្រមស៊ើបសួរវិញ ហើយចៅក្រមស៊ើបសួរអាចសម្រេចសេចក្ដីយ៉ាងយូរបំផុត ៥ ថ្ងៃបន្ទាប់ពីថ្ងៃបញ្ជូនសំណុំរឿងទៅតំណាងអយ្យការ។ ជាគោលការណ៍ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្ដងទៀតទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១ ខែ បន្ទាប់ពីមានសេចក្ដីសម្រេចបដិសេធពាក្យសុំលើកមុន។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំ។ ការសម្រេចមិនព្រមដោះលែងរបស់ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវមានសំអាងហេតុត្រឹមត្រូវច្បាស់លាស់។

ដូចនេះ ពេលចៅក្រមស៊ើបសួរសម្រេចដោះលែង ជនត្រូវចោទឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬប្រធាន មណ្ឌលឃុំខ្លួន ដើម្បីចាត់ការនីតិវិធី។ តែបើចៅក្រមស៊ើបសួរមិនព្រមដោះលែងទេ ព្រះរាជអាជ្ញាក៏ដូចជាជនត្រូវចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរដើម្បីប្រឆាំងនឹងសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ។ កាលណាចៅក្រមស៊ើបសួរសម្រេច

ឲ្យដោះលែង នៅក្រៅឃុំបណ្ដោះអាសន្នចៅក្រមនេះក៏នៅតែអាចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

### ២.៣ ការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការអនុវត្តទៅលើជនត្រូវចោទ ដែលនៅក្រៅឃុំឲ្យគោរពនូវកាតព្វកិច្ចមួយ ឬច្រើន តាមការកំណត់របស់ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។ ផ្ទុយទៅវិញការត្រួតពិនិត្យតាមផ្លូវតុលាការមិនអាចដាក់ចំពោះអនីតិជនអាយុតិចជាង១៤ ឆ្នាំ ឡើយ។[106] កាតព្វកិច្ចសម្រាប់ជនត្រូវចោទត្រូវអនុវត្តសម្រាប់ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការត្រូវបានកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវធ្វើតាមទម្រង់នៃដីកាមួយដែលមានឈ្មោះថា **ដីកាបង្គាប់ឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។**[107] ដីកាសម្រេចនេះត្រូវចេញដោយចៅក្រមស៊ើបសួរតាមគំនិតផ្ដើមផ្ទាល់របស់ខ្លួន ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតទៅព្រះរាជអាជ្ញា និងជនត្រូវចោទដើម្បីប្រើសិទ្ធិតវ៉ាតាមច្បាប់កំណត់។ ដោយឡែកក្នុងករណីព្រះរាជអាជ្ញា ធ្វើសេចក្ដីសន្និដ្ឋានសុំចៅក្រមស៊ើបសួរឲ្យដាក់ខ្លួនជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តែចៅក្រមស៊ើបសួរមិនព្រមសម្រេចតាមការស្នើសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីទទួលបានការស្នើសុំ។ ហើយប្រសិនបើ ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។

### កថាខណ្ឌទី៣ ការបិទ និងមោឃភាពនៃការស៊ើបសួរ

### ១. ការបិទការស៊ើបសួរ

ច្បាប់មិនបានកំណត់ពីថិរវេលានៃការស៊ើបសួរនោះទេ ដំណាក់កាលនៃការស៊ើបសួរអាច ត្រូវចំណាយពេលវេលាខ្លី ឬវែង អាស្រ័យទៅតាមភាពស្មុគស្មាញនៃរឿងក្ដី។ ភាគីនៃរឿងក្ដីអាចធ្វើការស្នើសុំឲ្យបិទការស៊ើបសួរ ហើយការស៊ើបសួរអាចត្រូវបានបញ្ចប់តាមការស្នើសុំរបស់ភាគីនៃរឿងក្ដី ក្នុងករណីការស៊ើបសួរអូសបន្លាយវេលាយូរពេក ឬប្រសិនបើចៅក្រមស៊ើបសួរយល់ថាការស៊ើបសួរមានលក្ខណៈគ្រប់គ្រាន់អាចសម្រេចតាមផ្លូវច្បាប់សម្រាប់ការជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ ដូចនេះសម្រាប់ការបិទការស៊ើបសួរនេះ ដំបូង

-មាត្រា២២៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[106]

-មាត្រា២២៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[107]

ចៅក្រមស៊ើបសួរត្រូវចេញសេចក្តីសម្រេចបិទការស៊ើបសួរ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់គូភាគីបើមាន។ យ៉ាងយូរ ២ថ្ងៃក្រោយ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យក្នុងរយៈពេល១៥ ថ្ងៃ ក្នុងករណីជនត្រូវចោទត្រូវជាប់ឃុំ និងព្រះរាជអាជ្ញាពិនិត្យក្នុងរយៈពេល១ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ។ ចិរវេលានៃការពិនិត្យសំណុំរឿងដោយព្រះរាជអាជ្ញានេះ ត្រូវរាប់ចាប់ពីពេលព្រះរាជអាជ្ញាបានទទួលសំណុំរឿង បន្ទាប់មកព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ តាមទម្រង់នៃដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។ ក្នុងដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចប្តឹងសុំទៅចៅក្រមស៊ើបសួរឲ្យបញ្ជូនខ្លួនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។

ក្នុងចិរវេលានៃការពិនិត្យសំណុំរឿង ព្រះរាជអាជ្ញាត្រូវសិក្សាពីសំណុំរឿងឲ្យបានល្អិតល្អន់ ហើយប្រសិនបើព្រះរាជអាជ្ញាយល់ថា ការស៊ើបសួរនៅមានភាពខ្វះចន្លោះព្រះរាជអាជ្ញាអាចស្នើសុំទៅចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរនោះភ្លាម។ ចុងក្រោយបន្ទាប់ពីមានសេចក្តីសម្រេចបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងសេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ចៅក្រមអាចធ្វើការបិទការស៊ើបសួរជាស្ថាពរ តាមរយៈការសម្រេចចេញដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយមាន ២ ប្រភេទគឺដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់។

ចៅក្រមស៊ើបសួរអាចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់។ ផ្ទុយទៅវិញ ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងចោទប្រកាន់ ប្រសិនបើអំពើនោះមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ជនដែលប្រព្រឹត្តនៅតែមិនស្គាល់អត្តសញ្ញាណ និងគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាមិនចងជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរ ក្នុងការសម្រេចអំពីការចេញដីកាដំណោះស្រាយឡើយ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីដីកាដំណោះស្រាយ ក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញាជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអាចប្តឹងតវ៉ាពីសេចក្តីសម្រេចនេះបាន។

## ២.មោឃភាពនៃការស៊ើបសួរ

មានតែសភាស៊ើបសួរតែប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការពិនិត្យមោឃភាពនៃកិច្ចស៊ើបសួរ វិធាន និងទម្រង់ការដែលនាំឲ្យមានមោឃភាពមានចែងក្នុងមាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលមានដូចជាការបើកការស៊ើបសួរ(មាត្រា ១២២), សមត្ថកិច្ចដែនដី (មាត្រា ១២៣) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (កថាខណ្ឌទី ៣ នៃមាត្រា ១២៤), វិសាលភាពនៃការប្តឹង (កថាខណ្ឌទី ១ និងទី២ នៃមាត្រា ១២៥) និងជំនួយក្រឡាបញ្ជីមាត្រា១២៨)។ វិធានទម្រង់ការទាំងអស់នេះត្រូវតែគោរពឱ្យបានជាដាច់ខាត ដើម្បីធានាដល់ការ

គោរពសិទ្ធិការពារខ្លួន។[108] មោឃភាពនឹងកើតមានផងដែរ ប្រសិនបើវិធាន ឬទម្រង់ណាមួយបានប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី ដែលទទួលរងការបំពានធ្ងន់ធ្ងរ និងត្រូវបានយកមកអនុវត្តមិនស្របតាមការកំណត់ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[109]

ប្រសិនបើ ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថាមានលិខិតណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញា ឬសាមីជនទាំងនោះអាចធ្វើពាក្យសុំដោយមានសំអាងហេតុបញ្ជូនទៅសភាស៊ើបសួរ និងជូនព័ត៌មានទៅចៅក្រមស៊ើបសួរ។ ពាក្យសុំរបស់ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើបានដោយមេធាវីរបស់សាមីជន។ ក្រៅពីនេះ ចៅក្រមស៊ើបសួរក៏អាចធ្វើបណ្ដឹងទៅសភាស៊ើបសួរអំពីលិខិតនៃនីតិវិធី ដែលខ្លួនយល់ឃើញថាមានមោឃភាពដែរ។ ចៅក្រមស៊ើបសួរធ្វើបណ្ដឹងតាមដីកាដោយមានសំអាងហេតុ និងត្រូវជូនព័ត៌មានទៅព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

គ្មានមោឃភាពនៃនីតិវិធីមុនអាចលើកឡើងបានទៀតទេចំពោះមុខតុលាការជំនុំជម្រះ។[110]វាមានន័យថាក្រោយការដោះស្រាយនូវមោឃភាពពីមុនដោយសភាស៊ើបសួររួចរាល់ហើយ កិច្ចស៊ើបសួរត្រូវបានបិទដោយស្ថាពរដោយដីកាដំណោះស្រាយហើយ ដូចនេះកិច្ចស៊ើបសួរត្រូវបានបញ្ចប់សព្វគ្រប់ហើយគ្មានការលើកឡើងពីមោឃភាពណាមួយអាចធ្វើបានឡើយ។

## ផ្នែកទី៣ ស្ថាប័នអយ្យការក្នុងដំណើរការនៃការជំនុំជម្រះ

### កថាខណ្ឌទី១ នីតិវិធីមុនពេលកិច្ចពិភាក្សាដេញដោល

តុលាការនឹងត្រូវបានបើកការជំនុំជម្រះ តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬដីកាសម្រេចរបស់ចៅក្រមស៊ើបសួរឲ្យបញ្ជូនទៅជំនុំជម្រះ។ ហេតុដូចនេះ នៅមុនពេលរាល់សវនាការ ព្រះរាជអាជ្ញាមានតួនាទីជួយសម្រួលដល់ការបង្ហាញខ្លួនរបស់ជនជាប់ចោទ និងភាគីដែលពាក់ព័ន្ធ ព្រមទាំងត្រូវបំពេញលក្ខណៈសម្បត្តិរបស់ខ្លួនផងដែរ។

**ចំណុចទី១៖** នៅក្នុងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ជាការបង្ហាញខ្លួនរបស់ជនជាប់ចោទនៅមុខពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួនមុខតុលាការ។ ហេតុនេះហើយ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ជននោះ អំពីរឿងហេតុដែលចោទប្រកាន់ ឈ្មោះបទល្មើស និងទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ និងត្រូវធ្វើកំណត់ហេតុស្ដីអំពីការបង្គាប់ឱ្យចូលបង្គាប់ឲ្យចូលខ្លួនភ្លាម។ ក្រៅពីនេះ ព្រះរាជ

-មាត្រា២៥២, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[108]

-មាត្រា២៥២, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[109]

-មាត្រា២៥៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[110]

អាជ្ញាត្រូវប្រាប់ជនជាប់ចោទថា "**ខ្លួនមានសិទ្ធិសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។**"

**ចំណុចទី២៖** ព្រះរាជអាជ្ញាត្រូវបានកំណត់ឱ្យអនុវត្តកិច្ចការមួយចំនួន ដោយរៀបចំឯកសារសំណុំរឿងដើម្បីធ្វើការពិភាក្សាដេញដោល នៅចំពោះមុខតុលាការ។ ការរៀបចំឯកសារជាភស្តុតាងដាក់បន្ទុកដែលជាមូលដ្ឋាននៃការចោទប្រកាន់ និងដើម្បីការពារដល់ការចោទប្រកាន់។ លើសពីនេះ ព្រះរាជអាជ្ញាត្រូវគោរពផងដែរនូវពេលវេលាកំណត់សវនាការ និងគោរពលើឯកសណ្ឋានជាដើម។

### កថាខណ្ឌទី២ ការបញ្ចប់កិច្ចពិភាក្សាដេញដោល

នៅពេលដែលកិច្ចពិភាក្សាដេញដោល ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរដល់ជនជាប់ចោទគ្រប់ការលើកសំណួរទាំងអស់ត្រូវតែទទួលបានការអនុញ្ញាតពីប្រធានសវនាការជាមុនសិន។សិទ្ធិអំណាចព្រះរាជអាជ្ញាក៏អាចធ្វើចំពោះការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះសាក្សី និងអ្នកជំនាញផងដែរ។

ជាមួយគ្នានេះ ព្រះរាជអាជ្ញាអាចជំទាស់នឹងការស្តាប់សាក្សី ដែលខ្លួនយល់ឃើញថាចម្លើយ នេះគ្មានប្រយោជន៍អ្វីដល់ការសំដែងឲ្យឃើញការពិត។ ក្នុងករណីមានការតវ៉ាប្រធានសវនាការសម្រេចដោយឥស្សរភាពថា តើត្រូវស្តាប់ ឬមិនស្តាប់ចម្លើយសាក្សីនេះ? ការបញ្ចប់កិច្ចពិភាក្សាដេញដោល ព្រះរាជអាជ្ញា មានសិទ្ធិក្នុងការនិយាយស្តី ឬក៏ធ្វើការសន្និដ្ឋានសរុបឱ្យចោទប្រកាន់ ឬផ្តន្ទាទោសទៅលើជនជាប់ចោទ ទៅតាមសិទ្ធិអំណាច និងការយល់ឃើញឯករាជ្យរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចធ្វើការសន្និដ្ឋានប្តឹងសុំដោយផ្ទាល់មាត់បាន ប្រសិនបើយល់ឃើញថាសមស្រប។

## ផ្នែកទី៤ ដំណើរការនៃការអនុវត្តទោស

ក្រោយសេចក្តីសម្រេច ឬសាលក្រមរបស់តុលាការបានក្លាយទៅជាស្ថាពរហើយនោះ តំណាងអយ្យការត្រូវតែធ្វើការអនុវត្តទោស។ ចំពោះការអនុវត្តទោសនេះទៀតសោតព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអាចសុំកងកម្លាំងសាធារណៈដើម្បីធានារ៉ាប់រងក្នុងការអនុវត្តទោសចំពោះទណ្ឌិត។

ករណីដែលភាគីណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេច ឬសាលក្រមមិនទាន់ចូលជាស្ថាពរអាចធ្វើការប្តឹងឧទ្ធរណ៍បាន ។ បុគ្គលដែលអាចប្តឹងឧទ្ធរណ៍បានមានដូចជា៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។

រយៈពេលនៃការប្តឹងឧទ្ធរណ៍នេះ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចធ្វើការប្តឹងក្នុងរយៈពេល ១ ខែ គិតចាប់ពីពេលប្រកាសសាលក្រម ចំពោះសាលក្រមចំពោះមុខ និង ១ ខែ គិតពីពេលទទួលដំណឹងសាលក្រមចំពោះសាលក្រមចាត់ទុកជាចំពោះមុខ។ រីឯរយៈពេលនៃការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវតែធ្វើឡើងក្នុងរយៈពេល ១ខែ និងការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវតែធ្វើឡើងក្នុងរយៈពេល ៣ខែ ដោយគិតចាប់ពីពេលប្រកាសសាលក្រម។ ប៉ុន្តែប្រសិនបើភាគីណាមួយមិនបានធ្វើការប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ខែ ទេនោះ នាំឱ្យសាលក្រមនឹងចូលជាស្ថាពរ ហើយព្រះរាជអាជ្ញានឹងធ្វើការអនុវត្តទោសចំពោះទណ្ឌិត។ ចំពោះដំណើរការនៃការអនុវត្តទោសនេះ ត្រូវបានបែងចែកជា ៣ គឺ **វិធានទាក់ទងនឹងការឃុំខ្លួន ការដោះលែងដោយមានលក្ខខណ្ឌ** និង**ការបង្ខំដល់រូបរាងកាយ**។

### កថាខណ្ឌទី១ វិធានទាក់ទងនឹងឃុំខ្លួន

ជាគោលការណ៍ ការឃុំខ្លួនបុគ្គលណាម្នាក់ដាច់ខាតត្រូវតែមានលិខិតដែលចេញដោយ អាជ្ញាធរតុលាការ។ វាមានន័យថាមុននឹងទទួលយកជនជាប់ឃុំចូលពន្ធនាគារប្រធានពន្ធនាគារ ឬមន្ត្រីពន្ធនាគារដែលទទួលបានការចាត់តាំងត្រូវត្រួតពិនិត្យអត្តសញ្ញាណរបស់ជនជាប់ឃុំឲ្យបានត្រឹមត្រូវ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ។ ប្រសិនបើភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលទទួលឃុំបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការនោះទេ ត្រូវជាប់ពិរុទ្ធភាពពីបទបង្ខាំងមនុស្សដោយខុសច្បាប់។[111] យោងតាមមាត្រា ៥០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីថិរវេលានៃការដាក់ពន្ធនាគារដែរ ដោយទោសដាក់ពន្ធនាគារក្នុង ១ថ្ងៃ មានថិរវេលា ២៤ម៉ោង ទោសដាក់ពន្ធនាគារក្នុង១ខែ មានថិរវេលា ៣០ថ្ងៃ និងទោសដាក់ពន្ធនាគារលើសពី ១ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី១ ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត។ ចំណែកឯទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយត្រូវបានដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ព្រឹក ដល់ម៉ោង ១៨ ល្ងាច ។

#### ១. ការគ្រប់គ្រងពន្ធនាគារ

ការគ្រប់គ្រងជនជាប់ឃុំ គឺការអប់រំកែប្រែ និងស្តារនីតិសម្បទារបស់ជនជាប់ឃុំ ដែលជាស្នូលនៃក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ[112] ហើយក្នុងការដាក់វិន័យដល់ជនជាប់ឃុំ ត្រូវបានធ្វើឡើងក្នុងកម្រិតអប្បរមាដែលចាំបាច់ដើម្បីធ្វើការធានាសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ។ ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធី និងបទបញ្ជាផ្ទៃក្នុងនៅក្នុងពន្ធនាគារ។ "**ពន្ធនាគារនីមួយៗ ត្រូវមានបញ្ជី**

-មាត្រា៥០៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[111]

-មាត្រា៤២, ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១[112]

**ជនជាប់ឃុំដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ឃុំ ហើយចុះក្នុងទិដ្ឋាការដោយតំណាងអយ្យការនៅគ្រប់ទំព័រ។**"[113] ចំពោះជនជាប់ឃុំជាស្ត្រី និងជនជាប់ឃុំជាអនីតិជនត្រូវមានបញ្ជីដោយឡែក ហើយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីរប្រភេទនេះ។ យ៉ាងណាមិញ ចំពោះការត្រួតពិនិត្យបញ្ជីជនជាប់ឃុំ ត្រូវបានធ្វើឡើងដោយតំណាងអយ្យការ និងត្រូវបញ្ជូនទៅចៅក្រម ដើម្បីពិនិត្យមើលតាមការស្នើសុំ និងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបំពេញភារកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ។[114] លើសពីនេះទៅទៀត ការបញ្ជូនទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀតប្រធានពន្ធនាគារត្រូវតែ មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃព្រមទាំងជូនដំណឹងភ្លាមៗ ឬយ៉ាងយូរបំផុត ៣ថ្ងៃ ទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងសមត្ថកិច្ចខាងដែនដីដែលទទួលបន្ទុក។ ជាមួយគ្នានេះដែរនឹងការផ្ទេរជនជាប់ឃុំ ក្រៅពីទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ក៏តម្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬអគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្តី។ ក្នុងករណីចាំបាច់នៃការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបង្គាប់ឱ្យផ្ទេរបានតាមតម្រូវការនៃនីតិវិធី។[115]

ក្នុងករណីដែលគ្រប់ឧប្បត្តិហេតុធ្ងន់ធ្ងរ ឬស្ថានភាពអាសន្នណាមួយបានកើតឡើងដូចជា៖ ជនជាប់ឃុំលួចរត់គេចចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួន នោះប្រធានពន្ធនាគារ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការជូនដំណឹងអំពីរឿងនេះជាបន្ទាន់ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីខេត្ត និងទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាពិសេសត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដីដើម្បីឲ្យព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួនដោយអនុលោមតាមបញ្ញត្តិដែលចែងក្នុងមាត្រា១៩៦ (ដីកាបង្គាប់ឲ្យចាប់ខ្លួន) និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[116] ទន្ទឹមនឹងនេះផងដែរ ប្រធានពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាគណៈអភិបាលរាជធានីខេត្ត និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីព័ត៌មាន ឬឧប្បត្តិហេតុទាំងឡាយណាដែលគំរាមកំហែង ឬអាចគំរាមកំហែងដល់សន្តិសុខ និងសុវត្ថិភាពពន្ធនាគារ។

-មាត្រា២១, ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១[113]
-មាត្រា២២, ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១[114]
-មាត្រា៦២, ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១[115]
-មាត្រា៥១១, ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១[116]

## ២. ការធ្វើអធិការកិច្ចពន្ធនាគា

ចំណែកឯការធ្វើអធិការកិច្ចពន្ធនាគារវិញនោះ ដោយអនុលោមតាមមាត្រា៥០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំដោយយន្តការបង្ការថ្នាក់ជាតិត្រូវបានអនុញ្ញាតឱ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានាគ្រប់ពេលវេលា និងធ្វើការសម្ភាសន៍ជាសម្ងាត់ជាមួយនឹងជនជាប់ឃុំដើម្បីអាចត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អសំដៅបង្ការទារុណកម្ម អំពើឃោឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក។[117]

ការចុះត្រួតពិនិត្យពន្ធនាគារ ជនដែលអាចចូលក្នុងពន្ធនាគារបានមានដូចជា៖[118]

- តំណាងព្រះមហាក្សត្រ
- សមាជិករដ្ឋសភាជាតិ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ជនទាំងឡាយ ដែលអនុញ្ញាតពីក្រសួងមហាផ្ទៃ
- ចៅក្រម ឬព្រះរាជអាជ្ញា
- អភិបាលខេត្ត-ក្រុង
- ជនណាម្នាក់ ឬអង្គការណាមួយ ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានពន្ធនាគារ ។

## កថាខណ្ឌទី២ ការដោះលែងដោយមានលក្ខខណ្ឌ

យោងតាមច្បាប់ស្តីពីពន្ធនាគាបានចែងថាគ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ ត្រង់ចំណុចនេះបញ្ជាក់ឲ្យឃើញថា ការដោះលែងទណ្ឌិតនេះអាចប្រព្រឹត្តទៅបានលុះត្រាតែទណ្ឌិតដែលត្រូវទទួលទោសនោះ មានការកែប្រែចិត្តគំនិតអត្តចរិត ក៏ដូចជាគំនិតមារយាទដែលរាងចាលលែងប្រព្រឹត្តបទល្មើសផ្សេងៗតទៅទៀត។ លើសពីនេះទៅទៀត បន្ទាប់ពីប្រធានពន្ធនាគារទទួលបានលិខិតសម្រេចពីអាជ្ញាធរតុលាការរួចមក នោះប្រធានពន្ធនាគារត្រូវតែធ្វើការដោះលែងជនដែលជាប់។ ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបាន

-មាត្រា៥៤, ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១[117]

-ប្រការ៤ ចំណុចទី២៦(ក), ការគ្រប់គ្រងពន្ធនាគារ ឆ្នាំ២០១១[118]

បញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងៗទៀតដែលត្រូវបានកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តត្រូវតែធ្វើការដោះលែងឲ្យមានសេរីភាពវិញនៅមុនថ្ងៃដែលឈប់សម្រាកនោះ។

អ្នកទោសដែលត្រូវបានដោះលែងជាបន្ទាន់ ក្នុងកាលៈទេសៈដូចតទៅ៖

- នៅពេលផុតកំណត់ទោស នៅពេលអនុញ្ញាតឲ្យដាក់ប្រាក់ធានាឲ្យ នៅក្រៅឃុំដោះលែងដោយមានលក្ខខណ្ឌ ដោះលែងបណ្តោះអាសន្ន។
- នៅពេលនិរទេសខ្លួនទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចដោយមានការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់តុលាការមានសមត្ថកិច្ច។ នៅពេលលើកលែងទោសដោយព្រះមហាក្សត្រចំពោះទោសដែលនៅសេសសល់នៅពេលលើកលែងការចោទប្រកាន់។

## ១. លក្ខខណ្ឌផ្សេងៗក្នុងការដោះលែងទណ្ឌិត

ការដោះលែងទណ្ឌិតអាចធ្វើទៅបានលុះត្រាតែបានគោរពនូវលក្ខខណ្ឌមួយចំនួន ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ទើបទណ្ឌិតអាចត្រូវបានដោះលែងឲ្យមានសេរីភាពវិញ និងការដោះលែងទណ្ឌិតត្រូវមាន ២ លក្ខខណ្ឌដែលមានដូចជា៖

- លក្ខខណ្ឌទាក់ទងទៅនឹងគំនិតមារយាទ សំដៅលើគ្រប់ទណ្ឌិតដែលត្រូវបានទទួលទោសមួយ ឬច្រើនអាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថាទណ្ឌិតមានគំនិតមារយាទល្អ និងកែប្រែខ្លួន ក្នុងអំឡុងពេលជាប់ឃុំ ទណ្ឌិតនោះនឹងអាចត្រូវបានដោះលែងឱ្យមានសេរីភាព ដោយស្តារនីតិសម្បទាមករស់នៅក្នុងសង្គមវិញបាន។[119]
- លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចហើយ សម្រាប់លក្ខខណ្ឌនេះការដោះលែងអាចត្រូវបានផ្តល់ឱ្យដល់ទណ្ឌិតដែលទទួលរងទោសជាប់ពន្ធនាគារ៖ ចំនួនពាក់ពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬស្មើ ១ឆ្នាំចំនួនពីរភាគបីនៃទោស ក្នុងករណីផ្សេងទៀត។[120]

រីឯទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចត្រូវបានទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ ឆ្នាំ។ ហេតុដូចនេះ អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់ការដោះលែងដោយមានលក្ខខណ្ឌចំពោះទណ្ឌិត និងត្រូវបានផ្តល់ដោយប្រធានតុលាការជាន់ដំបូងនៃទីតាំងឃុំខ្លួនបន្ទាប់ពីប្រធានតុលាការសម្រេច និងស្របតាមយោបល់ពីគណៈកម្មការជាតិដែលបានប្រជុំនៅក្រសួងយុត្តិធម៌ផងដែរ។[121]

-ប្រការ៤ ចំណុចទី៤(ក), ការគ្រប់គ្រងពន្ធនាគារ ឆ្នាំ២០១១[119]
-មាត្រា៥១២, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[120]
-មាត្រា៥១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[121]

## ២. សេចក្តីសម្រេចទាក់ទងទៅនឹងការដោះលែងដោយមានលក្ខខណ្ឌ

ជាទូទៅ បន្ទាប់ពីការទទួលបានយោបល់ និងបានឯកភាពរួចមកពីគណៈកម្មការជាតិ ប្រធានតុលាការនឹងសម្រេចតាមដីកាដោយមានសំអាងហេតុ ហើយសេចក្តីសម្រេចរបស់ប្រធានតុលាការនេះ អាចត្រូវបានតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ៥ថ្ងៃ ។ ចំពោះបណ្តឹងតវ៉ា គឺមានតែអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃតុលាការសាមីតែប៉ុណ្ណោះដែលអាចធ្វើបណ្តឹងតវ៉ានេះបាន។ នៅពេលដែលសេចក្តីសម្រេចរបស់ប្រធានតុលាការជាន់ដំបូង បានបង្គាប់ឱ្យដោះលែងដោយមានលក្ខខណ្ឌចំពោះទណ្ឌិត នោះនាំឱ្យសេចក្តីសម្រេចនោះ គ្មានអានុភាពអនុវត្តទេ នៅអំឡុងពេល ៥ ថ្ងៃបន្ទាប់ពីចេញសេចក្តីសម្រេចនេះ។[122] នេះបញ្ជាក់ឱ្យឃើញថាប្រសិនបើគ្មានបណ្តឹងតវ៉ានោះទេ សេចក្តីសម្រេចមានអានុភាពចាប់ពីពេលផុតរយៈពេល ៥ ថ្ងៃនៃការប្តឹងតវ៉ា ប៉ុន្តែករណីមានការប្តឹងតវ៉ាទៅប្រធានសាលាឧទ្ធរណ៍លើសេចក្តីសម្រេចនេះ នោះសេចក្តីសម្រេចនេះគ្មានអនុភាពអនុវត្តឡើយ ហើយសេចក្តីសម្រេចនឹងមានអានុភាពវិញ នៅពេលមានដីការដោះស្រាយណាមួយរបស់ប្រធានសាលាឧទ្ធរណ៍។

ដូចនេះ ក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិរួចមក ប្រធានតុលាការត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ ទើបព្រះរាជអាជ្ញាអាចចេញដីកាមួយប្រភេទដែលត្រូវបានគេហៅថា **ដីកាដោះលែងទណ្ឌិត** ដើម្បីដោះលែងទណ្ឌិតឱ្យមានសេរីភាព។ ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមីអាចបង្គាប់ឲ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន ដោយព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ប្រធានតុលាការជាន់ដំបូងភ្លាម។

### កថាខណ្ឌទី៣ ការបង្ខំដល់រូបរាងកាយ

ការបង្ខំរូបកាយត្រូវអនុវត្តដោយពេញលក្ខខណ្ឌច្បាប់ ទៅលើបុគ្គលដែលផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ដែលមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធ នោះអង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង។ ក្រៅពីនេះទៀតព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិតដែលរយៈពេលនេះមិនអាចតិចជាង ១០ថ្ងៃទេ ដើម្បីបង់ប្រាក់នោះហើយត្រូវឲ្យដំណឹងថា ប្រសិនបើខ្លួនមិនបង់ទេនោះ សាមីខ្លួនត្រូវបង្ខំដល់រូបកាយ។ ការឲ្យជាដំណឹងនេះត្រូវតែធ្វើកំណត់ហេតុស្តីពីការឲ្យដំណឹង ហើយការឲ្យដំណឹងនេះទៀតសោតអាចធ្វើទៅបានតាមរយៈ៖

- ដោយផ្ទាល់មាត់ ឬ

-មាត្រា៥១៦, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[122]

- តាមផ្លូវរដ្ឋបាល ឬ
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់តាមរយៈពេលដែលបានកំណត់ទេនោះ ព្រះរាជអាជ្ញាអនុវត្តវិធានការតាមផ្លូវច្បាប់ ដោយមានចុះហត្ថលេខាដោយព្រះរាជអាជ្ញាផ្ទាល់ ក្នុងកំណត់ហេតុផងដែរ។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្ដីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាពរបស់ទណ្ឌិត។ ក្នុងការចុះអន្តរាគមន៍បែបនេះ ព្រះរាជអាជ្ញាអាចសុំឲ្យកម្លាំងសាធារណៈចាប់ និងឃុំខ្លួនទណ្ឌិត។

### ១. ថិរវេលានៃការបង្ខំដល់រូបរាងកាយ

យោងតាម ក្រមនីតិវិធីព្រហ្មទណ្ឌ ថិរវេលានៃការបង្ខំ ដែលរូបគេត្រូវបានកំណត់ដូចតទៅ៖

- ១០ (ដប់) ថ្ងៃ កាលណាទឹកប្រាក់ដែលបង់នោះមានចំនួនមិនលើសពី ២៥០.០០០ (ពីរសែនប្រាំម៉ឺន) រៀល ។
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នោះចំនួន ២៥០.០០១ (ពីរសែនប្រាំម៉ឺនមួយ) រៀល ដល់ ៥០០.០០០ (ប្រាំសែន) រៀល។
- ១ (មួយ) ខែ ប្រសិនបើទឹកប្រាក់ចំនួន ៥០០.០០១ (ប្រាំសែនមួយ) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល។
- ២ (ពីរ) ខែ ប្រសិនបើទឹកប្រាក់នេះចំនួន ១.០០០.០០១ (មួយលានមួយ) រៀល ដល់ ២.៥០០.០០០ (ពីរលានប្រាំសែន) រៀល។
- ៣ (បី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួន ២.៥០០.០០១ (ពីរលានប្រាំសែនមួយ) រៀល ដល់ ៥.០០០.០០០(ប្រាំលាន) រៀល។
- ៦ (ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួន ៥.០០០.០០១ (ប្រាំលានមួយ) រៀល ដល់ ១០.០០០០០០(ដប់លាន) រៀល។
- ១ (មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នោះមានចំនួន ១០.០០០.០០១ (ដប់លានមួយ) រៀល ដល់ ២០.៥០០.០០០ (ម្ភៃលានប្រាំសែន) រៀល។
- ១៨ (ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួន ២០.៥០០.០០១ (ម្ភៃលានប្រាំសែនមួយ) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល។

- ២ (ពីរ) ឆ្នាំ ប្រសិនបើទឹកប្រាក់នោះមានចំនួនលើសពី ៥០០.០០០.០០ (ហាសិបលាន) រៀល ។ កាលណាការបង្ខំលើរូបកាយ ការធានាឥណទេយ្យ ច្រើននោះថេរៈវេលានៃការបង្ខំនោះ ត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម។[123]

## ២. ការរួចផុតពីការបង្ខំដល់រូបរាងកាយ

ជាការពិតណាស់ ការបង្ខំដល់រូបកាយមិនអាចធ្វើទៅលើទណ្ឌិត ដែលជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ឆ្នាំឡើងទៅ និងទៅលើបុរសអាយុចាប់៧០ឆ្នាំឡើងទៅ។ មួយវិញទៀតនោះការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្ដី ប្រពន្ធបាននោះទេ ទោះបីជាការបង្ខំនេះធ្វើឡើងដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយៗ។[124]

-មាត្រា៥៣០, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[123]

-មាត្រា៥៣១, ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[124]

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ យើងឃើញថាចំពោះចំណាត់ការលើបណ្តឹងដោយព្រះរាជអាជ្ញា គឺមាននោះចំនួនពីរ ទី១- ព្រះរាជអាជ្ញានឹងសម្រេចមិនចោទប្រកាន់ដោយតម្កល់រឿងទុកឥតចាត់ការ ទី២-ការសម្រេចចោទប្រកាន់ដោយធ្វើតាមមាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧។ ចំពោះការតម្កល់ទុកឥតចាត់ការគឺមានសារៈ ប្រយោជន៍ដល់ការអភិវឌ្ឍសង្គមក្នុងស្ថានភាពមួយចំនួន នៅពេលដែលជួបមូលហេតុណាមួយនោះ ដែលនាំឱ្យព្រះរាជអាជ្ញាអាចមិនចោទប្រកាន់។ ក្នុងករណីខ្លះទៀត ការចោទប្រកាន់ចាំបាច់ត្រូវតែមានដើម្បីធានាការអនុវត្ត ច្បាប់លើកកម្ពស់វិស័យយុត្តិធម៌ និងទប់ស្កាត់ការរីករាលដាលនៃបទល្មើស ហើយការធានាទាំងនេះនឹងមិនធ្វើកើត បើមិនមានកិច្ចចោទប្រកាន់នោះទេ។ ដូចនេះស្ថាប័នអយ្យការ គឺចាំបាច់ត្រូវឈរលើការថ្លឹងថ្លែងមួយដែលប្រកប ដោយភាពសមហេតុផលនិងពិចារណាយ៉ាងខ្ពស់ចំពោះអង្គហេតុនីមួយៗ ដើម្បីធានាថាការថ្លឹងថ្លែង លើចំណាត់ការមិនខុសចាំបាច់សមត្ថភាព លើការអនុវត្តច្បាប់របស់ស្ថាប័នអយ្យការត្រូវមានកម្រិតខ្ពស់ និងមានបទពិសោធន៍យ៉ាងរឹងមាំទាំងវិស័យច្បាប់និងសង្គម។

ទោះយ៉ាងណាក៏ដោយដើម្បីឲ្យមានច្បាស់លាស់ ប្រាកដប្រជាក្នុងការចោទប្រកាន់របស់ស្ថាប័នអយ្យការព្រះរាជអាជ្ញា ត្រូវបើកការស៊ើបសួរចំពោះករណី បទល្មើសឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់ធ្ងរ ដើម្បីធានាបាននូវសណ្តាប់ធ្នាប់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថេរភាពសង្គម ជាពិសេសចូលរួមគ្នាមួយគឺការអភិវឌ្ឍសង្គមជាតិ ធានាការ អនុវត្តច្បាប់ និងទប់ស្កាត់ការរីករាលដាលនៃបទល្មើសព្រហ្មទណ្ឌ ការធានាទាំងនេះបើគ្រាន់តែពឹងលើស្ថាប័ន អយ្យការតែមួយគោលដៅ ដែលសង្គមជាតិចង់បាននោះ គឺមិនអាចកើតមានទេ។ ជាមួយគ្នានេះដែរ ការអនុវត្តច្បាប់តម្រូវឲ្យមាន តំណាងអយ្យការ និងកងកម្លាំងមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរយុត្តិធម៌ដែលមានអំណាច ចូលរួមក្នុងកិច្ចនីតិវិធីនានា ការស្វែងរកជនសង្ស័យ ការឃាត់ខ្លួន ការស៊ើបអង្កេត និងការប្រមូលភស្តុតាងជាដើម។ ការធ្វើបែបនេះជាភាពចាំបាច់ក្នុងការរួមចំនែកពីស្ថាប័នពាក់ពន្ធមួយចំនួនដូចជា នគរបាលយុត្តិធម៌ យុត្តាធិការស៊ើបសួរ ក្រឡាបញ្ជី យុត្តាធិការជំនុំជំរះ និងស្ថាប័នពាក់ពន្ធមួយចំនួនទៀត។ សរុបមកការពង្រឹងសមត្ថភាពក្នុងកិច្ចការអនុវត្តច្បាប់ គឺចាំបាច់ត្រូវតែប្រព្រឹត្តទៅដំណើរគ្នាជាមួយការពង្រឹងសមត្ថភាពរបស់ស្ថាប័នអយ្យការក្នុងការអនុវត្តច្បាប់។

ការបកស្រាយរបស់កថាខណ្ឌទាំងពីរខាងលើ គឺនិយាយតែពីការខិតខំអោយមានស្ថាប័នដែលអាចធានា ការអនុវត្តច្បាប់ព្រហ្មទណ្ឌអោយកាន់តែរឹងមាំ ក្នុងគោលដៅធ្វើការបង្ក្រាបបទល្មើស ចាប់ជនល្មើសនឹងដាក់ទណ្ឌកម្មជនល្មើសដោយការផ្តន្ទាទោសរបស់តុលាការប៉ុណ្ណោះ ទាំងអស់ត្រូវបានគេយល់ថានេះ ជាវិធានការមួយ ដែលអាចធ្វើការបំភ័យដល់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសពីមុនរួចហើយដែលកំពុងទទួល ការដាក់ទណ្ឌកម្មនិងបំភ័យដល់សាធារណៈជនមិនអោយជនទាំងនេះហ៊ានប្រព្រឹត្តបទល្មើសដូចជនល្មើសទៀត។

វិធានការនេះ ជាវិធានការដែលមានប្រសិទ្ធភាព ក្នុងការទប់ស្កាត់ការរីករាលដាលនៃបទល្មើស ដោយធ្វើការដាក់ទណ្ឌកម្មជនល្មើសក្នុងគោលដៅកាត់បន្ថយបទល្មើស។ តែអ្នកសិក្សាពីឧក្រិដ្ឋវិជ្ជាជាច្រើនអះអាងថា មានមូលហេតុធំៗចំនួនពីរដូចជា ១- មូលហេតុជីវសាស្ត្រនិងកត្តាចិត្តសាស្ត្រ ២- មូលហេតុសង្គម (កត្តាសង្គម ភាពក្រីក្រ កត្តាបក្សពួក កត្តាអំណាច កត្តាគ្រួសារ កត្តាអប់រំជាដើម) ដែលបណ្តាលអោយជនដែលធម្មតាមិនមានចារិកគ្រោះថ្នាក់ដល់សង្គម បែរក្លាយជាជនល្មើសដែលបំពានដល់សណ្តាប់ធ្នាប់សង្គមទៅវិញ ។

សរុបសេចក្តីមក ស្ថាប័នអយ្យការមានតួនាទីចោទប្រកាន់ ដោយយកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់មកអនុវត្ត ដោយគោលការណ៍នេះបានដើរតួយ៉ាងសំខាន់ ក្នុងការផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ឬសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះបទល្មើសព្រហ្មទណ្ឌ។ ស្ថាប័នអយ្យការមានតំណាងព្រះរាជអាជ្ញា ដើម្បីចូលរួម និងដំណើរការនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ បើគ្មានការចូលរួមក្នុងការចោទប្រកាន់ពីសំណាក់តំណាងព្រះរាជអាជ្ញា ក៏ពុំកើតមាននូវកិច្ចស៊ើបសួរ ក៏ដូចជាកិច្ចជំនុំជម្រះផងដែរ។

# អនុសាសន៍

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋសម្រាប់ដំណើរការបណ្តឹងសាធារណៈ ឬបណ្តឹងព្រហ្មទណ្ឌ ហើយមានតួនាទីក្នុងការការពារសណ្តាប់ធ្នាប់សារធារណៈ។ ស្ថាប័នអយ្យការមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ដើម្បីឱ្យមានតម្លាភាព និងប្រកបដោយភាពយុត្តិធម៌ តែរាល់សកម្មភាពទាំងនេះតម្រូវឱ្យមានៈ

១. ធ្វើការអប់រំបណ្តុះបណ្តាលចំណេះដឹងនូវក្រមនីតិវិធីព្រហ្មទណ្ឌ ទៅដល់មន្ត្រីទាំងឡាយឱ្យមានចំណេះដឹងទូលំទូលាយក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព និងត្រឹមត្រូវទៅតាមច្បាប់កំណត់ដែលមានចែងក្នុងក្រមនេះ ជាពិសេស គឺផ្តល់នូវពុទ្ធិដល់មន្ត្រីជំនាញដើម្បីបំពេញភារកិច្ចក្នុងរឿងក្តីព្រហ្មទណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត ការអបរំការផ្សព្វផ្សាយបណ្តុះបណ្តាល ក្នុងគោលបំណងជៀសវាងកុំមានវិវាទសមត្ថកិច្ចក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ។

២. ធ្វើការបង្កើនធនធានមនុស្សដែលមានចំណេះជំនាញលើប្រព័ន្ធយុត្តិធម៌ដូចជា ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌បន្ថែម តាមរយៈការប្រឡងជ្រើសរើស និងបណ្តុះបណ្តាល ប្រកបដោយវិជ្ជាជីវៈ និងដើម្បីជួយសម្រួលដល់កិច្ចជំនុំជម្រះរឿងក្តីដែលមានភាពយឺតយ៉ាវ ដោយសារការខ្វះខាតនៅធនធានមនុស្សដែលមានវិជ្ជាជីវៈក្នុងការអនុវត្តលើកិច្ចដំណើររឿងក្តីព្រហ្មទណ្ឌនេះ។

៣. ដើម្បីលើកទឹកចិត្តដល់មន្ត្រីដែលមានតួនាទី និងភារកិច្ចក្នុងប្រព័ន្ធយុត្តិធម៌ តាមការរយៈការតំឡើងប្រាក់បៀវត្ស ឱ្យបានសមរម្យដោយគិតពីជីវភាពរស់នៅសព្វថ្ងៃរបស់ពួកគាត់ ឬសេវាថែទាំសុខភាព និងសេវាផ្សេងៗទៀតដែលជាប្រយោជន៍សម្រាប់ពួកគាត់ និងដើម្បីចៀសវាងកុំឱ្យមាន សកម្មភាពអំពើពុករលួយកើតមានឡើងក្នុងប្រព័ន្ធតុលាការដោយសារតែកង្វះខាតការយកចិត្តចំពោះប្រាក់បៀវត្សរបស់មន្ត្រី។ ជាមួយគ្នានេះដែរ ការចោទចំពោះអំពើណាមួយ ដែលព្រះរាជអាជ្ញាយល់ឃើញថាដោយគ្មានប្រយោជន៍ អាចលើកលែងបាន។ ទន្ទឹមនឹងនេះ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ក៏កើតមានជាវិបាកផងដែរ ដែលអាចនាំឱ្យបទល្មើស ដែលមានកម្រិតគ្រោះថ្នាក់តូចតាច នោះកើតមានឡើងក្នុងសង្គមឥតឈប់ឈរជាអាទិ៍។

សរុបសេចក្តីមក ជម្រើសនៃការចោទប្រកាន់របស់អង្គការអយ្យការតាមរយៈការប្រកាន់ យកនូវគោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់នេះបានដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ឬ សម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះ បទល្មើសព្រហ្មទណ្ឌ។ បើគ្មានការចូលរួមក្នុងការចោទប្រកាន់ពីសំណាក់ ព្រះរាជអាជ្ញា ក៏ពុំកើតមាននូវកិច្ចស៊ើបសួរ ក៏ដូចជាកិច្ចជំនុំជម្រះផងដែរ។

## ឯកសារយោង

### ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១១០៩/០២២,ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៨០៧/០២៤,ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧
- ច្បាប់ ស្តីពី ការរៀបចំអង្គការតុលាការ ,លេខ នស/រកម/០៧១៤/០១៥,ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា,លេខ នស/រកម/០៧១៤/០១៦,ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤
- ច្បាប់ស្តីពីការទប់ស្កាត់គ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥
- ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១

### ២. សៀវភៅមេរៀន

- សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧, សហប្រតិបត្តិបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ និងរាជបណ្ឌិតវិជ្ជាជីវៈតុលាការ។
- សៀវភៅមេរៀនដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយ ឧត្តមសេនីយ៍ត្រី អាន សូវីដា បោះពុម្ពលើកទី២ ឆ្នាំ២០២១។
- សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និង លោក ខាន់ សុខា

### ៣. ឯកសារផ្សេងទៀត

- អត្ថបទជំនួយស្មារតី ស្ថាប័នអយ្យការ រៀបរៀងដោយនីតិកោសល
- ទូរទស្សន៍ជាតិកម្ពុជា (ទ.ទ.ក) កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៨
- គោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា, អនុម័តដោយ សមាជអង្គការសហប្រជាជាតិលើកទី ៨ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា, នៅថ្ងៃទី ២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០

- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីសុខ អាន, ជ.គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ប្រធាន សំ សុខផល, "សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ" , រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, បោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី, បោះពុម្ពលើកទី១,ឆ្នាំ២០១១,ទំព័រទី៧០ ។

- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីសុខ អាន, ជ.គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ប្រធាន សំ សុខផល, " សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ", រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, បោះផ្សាយដោយទីស្ដីការគណៈរដ្ឋមន្ត្រី, បោះពុម្ពលើកទី១,ឆ្នាំ២០១១,ទំព័រ៦២៖ សវនាការ = ការបើកកិច្ចជំនុំជម្រះដែលក្នុងឱកាសនោះ ចៅក្រមសួរដេញដោល និងស្ដាប់ការចោទប្រកាន់របស់ក្រុមអយ្យការ ហើយវិនិច្ឆ័យសេចក្ដី ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

✦✦✦✦✦

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខៈ .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឲ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឲ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

អយ្យការ
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កំណត់ហេតុទទួលវត្ថុតាង

ឆ្នាំពីរពាន់ដប់បី ខែ ... ថ្ងៃទី ពីរ វេលាម៉ោង ដប់ និង សូន្យ នាទី ។
យើង ...ក្រឡាបញ្ជីនៃអយ្យការ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។
លោក ... ជាមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តបន្ទាយមានជ័យ
ជាអ្នកប្រគល់រួមជាមួយនិងឈ្មោះ ....ឈ្មោះ ....ឈ្មោះ ...ពីបទៈជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន

បានពិនិត្យភិនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ឃើញដូចខាងក្រោមៈ

១-កញ្ចប់ពណ៌សបិទជិតមានស្នាមមេដៃឈ្មោះ ....ឈ្មោះ ...និងហត្ថលេខាលោក ...លោក ...និងលោក ... ។

២-ទូរស័ព្ទចំនួន ០៦ គ្រឿង មួយគ្រឿងម៉ាក់ SAMSUNG ពណ៌ខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់NOKIA E99I ពណខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់ NOKIA X1 ពណ៌ខ្មៅ(ចិន) .មួយគ្រឿងទៀតម៉ាក់ NOKIA ចុចពិលពណ៌ផ្កាឈូកលាយពណ៌ស (ចាស់) .មួយគ្រឿងម៉ាក់ NOKIA ចុចពិលពណ៌ខ្មៅបិទស្ទិគពណ៌ទឹកប្រាក់ និងមួយគ្រឿងទៀតម៉ាក់ HUAWEI ពណ៌ខ្មៅលាយពណ៌ស។

៣-កាបូបលុយចំនួនមួយពណ៌ខៀវ(គ្មានលុយ).ដែកកេះចំនួនពីរ.កាបូបស្ពាយតូចចំនួនមួយពណ៌ប្រផេះ.សំបកប្រអប់ស្រោមអនាម័យOKចំនួនមួយ.ថង់តូចពណ៌សមួយចំនួន.បំពុងទុយយចំនួនពីរ.កំរបដបទឹកចោះដាក់ទុយយមួយ។

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួនពីរ.មួយមានលេខៈ...របស់ឈ្មោះ...និងមួយទៀតមានលេខៈ... របស់ឈ្មោះ ...។

៥-លុយខ្មែរចំនួន ៥០០០០ រៀល និងលុយដុល្លារចំនួន ១០ ដុល្លារ។

៦-ម៉ូតូមួយគ្រឿងម៉ាក់ VIVA ពណ៌ខ្មៅសេរីឆ្នាំ ២០១០ គ្មានកញ្ចក់ .គ្មានកន្ត្រក ពាក់ផ្លាក់លេខៈ ...លេខម៉ាស៊ីន ...។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោង ដប់និងសែសិប នាទី នាថ្ងៃ ខែឆ្នាំដដែល ។

| អ្នកប្រគល់ | ក្រឡាបញ្ជី | ជនជាប់សង្ស័យ |
| --- | --- | --- |

បានឃើញ
បន្ទាយមានជ័យ.ថ្ងៃទី ... ខែ ...ឆ្នាំ ២០១៣
**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
*សំណុំរឿងព្រហ្មទណ្ឌ*
*លេខ............*
*ចុះថ្ងៃទី ... ខែ... ឆ្នាំ២០១៦*

# កំណាត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីពីរ វេលាម៉ោង ដប់ និងសូន្យ នាទី។

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោកជាក្រឡាបញ្ជី ។

យើងបានស្តាប់ចម្លើយឈ្មោះ...ជាជនសង្ស័យដោយមានលោក...ជាមេធាវីការពរ។

បានមកបង្ហាញខ្លួន នៅចំពោះមុខយើង ដែលមានអត្តសញ្ញាដូចខាងក្រោម:

នាមត្រកូល ៖ ... នាមខ្លួន ៖ ...

ភេទ: ប្រុស

កើតថ្ងៃទី ៖ អាយុ ... ឆ្នាំ

ទីកន្លែងកំណើត ៖ភូមិ...ខេត្តពោធិ៍សាត់

អាសយដ្ឋាន ៖ភូមិ...ខេត្តពោធិ៍សាត់

មុខរបរ ៖ ...

សាសនា: ព្រះពុទ្ធ

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ... "រ" ម្តាយឈ្មោះ ៖ ... "រ"

អនីតិជន ☐ ឬ នីតិជន ☐

ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន

ជននេះ ៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ

**សួរ-ឆ្លើយ**៖ នៅថ្ងៃទី... ខែ... ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២១ជាង មិត្តភក្តិរបស់ខ្ញុំមានគ្នាបីនាក់ ១.ឈ្មោះ ...២.... ៣.ឈ្មោះ ... ជិះម៉ូតូ០២គ្រឿងមកបបួលខ្ញុំនៅផ្ទះ

នៅភូមិ...ខេត្តពោធិ៍សាត់ ថាទៅដុតត្រីហុប ពេលនោះខ្ញុំនិងមិត្តភក្តិរៀបចេញដំណើរ ស្រាប់តែសមត្ថកិច្ចមកដល់ ហើយបានហៅពួកខ្ញុំទាំងបួននាក់ មកអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ សមត្ថកិច្ចបានឆែកឆេរក្នុងម៉ូតូ របស់ខ្ញុំ ឃើញមានក្រដាសអាលុយមីញ៉ូម ហើយទុយយូមួយដើម និងពិនិត្យទឹកនោមខ្ញុំ ឃើញមានសារធាតុញៀន ។

**សួរ.ឆ្លើយ៖** ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀន ហើយប្រើប្រាស់លើកចុងក្រោយមុនថ្ងៃចាប់ខ្លួនពីរឬបីថ្ងៃ ប្រើម្នាក់ឯងក្នុងផ្ទះរបស់ខ្ញុំ។ថ្នាំញៀនដែលខ្ញុំប្រើប្រាស់នេះ ទិញពីឈ្មោះ ... ណាត់យកមកឲ្យនៅផ្លូវ...ខេត្តពោធិ៍សាត់ ទិញតំលៃ៣ម៉ឺនរៀល។

**សួរ.ឆ្លើយ៖** ពួកម៉ាកបីនាក់ទៀត សមត្ថកិច្ចបានឆែកឆេរអត់ឃើញមានអីពាក់ ពន្ធ័បានឲ្យទៅផ្ទះវិញ ។

**សួរ.ឆ្លើយ៖** ខ្ញុំមិនដែលរកស៊ីជួញដូរ និងចែកចាយថ្នាំញៀនទេ។

**សួរ.ឆ្លើយ៖** នៅក្នុងថ្ងៃខែមិនចាំ ក្នុងឆ្នាំ... ពេលយប់មិនចាំម៉ោង ខ្ញុំបានជិះម៉ូតូម៉ាកស៊ីរូស អត់មានផ្លាកលេខ ចេញពីផ្ទះដើម្បីទៅទិញមីនិងបារីជក់ ពេលជិះមកដល់ស្ពានដែក (ផ្លូវរថភ្លើង) តាមផ្លូវមាត់ស្ទឹង ស្រាប់តែមានរថយន្តតូចមួយគ្រឿង បានជិះមកគៀរម៉ូតូរបស់ខ្ញុំបណ្តាលឲ្យដួល ហើយឃើញគេចុះពីលើឡានរួចស្រែកឲ្យខ្ញុំឈប់ ឃើញដូច្នេះខ្ញុំក៏រត់ចោលម៉ូតូ មកដេកផ្ទះ ។

**សួរ.ឆ្លើយ៖** ពេលបាត់ម៉ូតូខ្ញុំមិនបានប្តឹងសមត្ថកិច្ចទេ ក្រោយមកលឺដំណឹងថាម៉ូតូរបស់ខ្ញុំ នៅប៉េអឹមហើយពាក់ពន្ធ័និងថ្នាំញៀន លឺដូចឆ្នេះខ្ញុំមិនហ៊ានទៅសុំម៉ូតូវិញទេ ព្រោះខ្លាចគេចោទ ថាជួញដូរថ្នាំញៀន ។

**សួរ.ឆ្លើយ៖** ពេលខ្ញុំរត់ចោលម៉ូតូ ខ្ញុំមិនមានថ្នាំញៀនទេហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ខ្ញុំមិនដឹងថាជារបស់អ្នកណាឡើយ ។

*បញ្ចប់កំណត់ហេតុវេលាម៉ោង ដប់ និង សែសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល។*

យើងបានប្រាប់ជននេះឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ផ្តិតម្រាមដៃលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជននេះមិនមានបដិសេធចំណុចណាទេ និង ចុះហត្ថលេខា ឬ ផ្តិតម្រាម ដៃជាមួយយើង ។

| | | |
|---|---|---|
| **អ្នកឆ្លើយ** | **ក្រឡាបញ្ជី** | **ព្រះរាជអាជ្ញារង** |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

កំណត់ហេតុស្រុះស្រួល

ឆ្នាំពីរពាន់ដប់ពីរ ខែ មេសា ថ្ងៃទី ពីរ វេលាម៉ោង ពីរ និង ដប់ នាទី នៅអយ្យការអម សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានធ្វើការស្រុះស្រួលរវាងដើមចោទ និងជនជាប់សង្ស័យ ដូចតទៅ:

-ភាគីដើមចោទឈ្មោះ ... ភេទ ប្រុស អាយុ ... នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានប្តឹងឈ្មោះ ... ភេទ ... ឲ្យប្រគល់ដី ស្រែចំនួន កន្លះហិចតា ឲ្យមកខ្លួនវិញ។

-ជនជាប់សង្ស័យឈ្មោះ ... ភេទ ... អាយុ ... ឆ្នាំ រស់នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានស្រុះស្រួលជាមួយដើមបណ្តឹងដោយយល់ព្រមប្រគល់ដីស្រែចំនួន កន្លះ ហិចតា នេះស្ថិតនៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ ឲ្យដើមបណ្តឹងឈ្មោះ ... ដើម្បីគ្រប់គ្រង និងបានយល់ព្រមសងស្រូវទៅដើមបណ្តឹងវិញចំនួន ០៦ បាវ។

ការស្រុះស្រួលគ្នានេះ ដើមបណ្តឹងឈ្មោះ ... សុខចិត្តដកពាក្យបណ្តឹងឈប់ប្តឹងពីជនជាប់សង្ស័យឈ្មោះ ... វិញហើយ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ពីរ និងហាសិប នាទី នាថ្ងៃ ខែ ឆ្នាំដដែល រួច បានអានឲ្យស្តាប់ ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃ និងចុះហត្ថលេខាទុកចំណាំ។

ដើមបណ្តឹង ជនជាប់សង្ស័យ

បានឃើញ

ថ្ងៃទី ខែ ... ឆ្នាំ ២០១២

ព្រះរាជអាជ្ញា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូង ខេត្តពោធិ៍សាត់**
*សំណុំរឿងព្រហ្មទណ្ឌលេខ ...*
*ចុះថ្ងៃទី ... ខែ ... ឆ្នាំ...*

**ដីកាកោះ**

*យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*បង្គាប់មកឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ ជាសាក្សី ។*

*ទីលំនៅបច្ចុប្បន្ននៅភូមិ...ខេត្តពោធិ៍សាត់ ។*

*ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*នៅវេលាម៉ោង២០០ រសៀល ថ្ងៃទី ... ខែ... ឆ្នាំ... ។*

*ដើម្បី **សួរយកចម្លើយ***

*ពីដំណើររឿង **បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី ... ខែ... ឆ្នាំ ... នៅ***

***ចំណុច...ភូមិ...ខេត្តពោធិ៍សាត់។***

*សាមី*

*ខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។*

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ... ឆ្នាំ ...*

**ព្រះរាជអាជ្ញារង**

យើង.....................................................................បានប្រគល់ដីកាកោះនេះដល់

ឈ្មោះ...................................ទីលំនៅបច្ចុប្បន្ននៅភូមិ................... ឃុំ/សង្កាត់ ........................................... ស្រុក/ខណ្ឌ...............ខេត្ត/ក្រុង..........................នៅថ្ងៃទី .........ខែ..................ឆ្នាំ.....................................ហើយយើងបានប្រាប់ថា ឱ្យយកចុង ដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលា ដំបូងខេត្តពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៛៣

អយ្យការអម
សាលាដំបូងខេត្ត
*បន្ទាយមានជ័យ*
*លេខ៖*

## ដីកាផ្ទេរសមត្ថកិច្ច

✦✦✦✦✦

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

